Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

# បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា




## ការអភិវឌ្ឍន៍សេដ្ឋកិច្ចនាពេលថ្មីៗ និងទស្សនវិស័យ

អត្ថបទជម្រើសៈ

តើកម្ពុជាអាចក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ ២០៥០ ដែរឬទេ?

ខែ តុលា ឆ្នាំ ២០១៨

ក្រុមធនាគារពិភពលោក

# បច្ចុប្បន្នភាព
# សេដ្ឋកិច្ច
# កម្ពុជា

ខែ តុលា ឆ្នាំ ២០១៨

## ការអភិវឌ្ឍន៍សេដ្ឋកិច្ច
## នាពេលថ្មីៗ
## និងទស្សនវិស័យ

ក្រុមធនាគារពិភពលោក



# មាតិកា


**សេចក្តីថ្លែងអំណរគុណ** ........ ១

**ពាក្យកាត់** ........ ២

**ខ្លឹមសារសង្ខេប** ........ ៣

**ផ្នែកទី 1 ៖ ការអភិវឌ្ឍសេដ្ឋកិច្ចថ្មីៗ និងទស្សនវិស័យ** ........ ៩

- ការអភិវឌ្ឍសេដ្ឋកិច្ចថ្មីៗ ........ ៩
  - កម្ពុជានៅតែមានកំណើនសេដ្ឋកិច្ចរឹងមាំ ........ ៩
  - មានកំណើនលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស ........ ១២
  - លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសនៅពេលបច្ចុប្បន្ន កើនឡើងនៅក្នុងឧស្សាហកម្មកម្មន្តសាល ជាពិសេសឧស្សាហកម្មកាត់ដេរ ........ ១២
  - ឧស្សាហកម្មទេសចរណ៍កំពុងរីកចម្រើន ខណៈដែលចំនួនភ្ញៀវទេសចរចូលមកកម្ពុជាកើនឡើងដល់ 3 លាននាក់ ឬស្មើនឹងអត្រាកំណើន 13.6 ភាគរយ (ក្នុងមួយឆ្នាំ) នៅពាក់កណ្តាលឆ្នាំ 2018 ........ ១៣
  - យ៉ាងណាក៏ដោយ កម្ពុជានៅលំដាប់ក្រោមឆ្ងាយពីប្រទេសថៃ និងវៀតណាម នៅក្នុងការទាក់ទាញភ្ញៀវទេសចរបរទេស ........ ១៤
  - ភ្ញៀវទេសចរចូលមកប្រទេសវៀតណាមមានតែ 5 ភាគរយ និងភ្ញៀវចូលមកប្រទេសថៃមានតែ 13.5 ភាគរយប៉ុណ្ណោះ ដែលបន្តដំណើរទេសចរណ៍មកកាន់ប្រទេសកម្ពុជា ........ ១៤
  - ពិពិធកម្មកសិកម្ម រួមទាំង ការធ្វើឲ្យមានគុណភាពដោយឡែក នឹងជួយឲ្យវិស័យកសិកម្មឆ្លើយតបនឹងការប្រែប្រួលតម្រូវការទាំងក្នុង និងក្រៅប្រទេស ........ ១៥
  - លទ្ធភាពទទួលបានទឹកស្អាតសម្រាប់គ្រួសារជនបទ នៅតែជាបញ្ហាប្រឈម ........ ១៦
  - កំណើនតម្រូវការក្នុងស្រុកត្រូវបានបំពេញដោយកំណើននៃការនាំចូល ........ ១៧
  - កម្ពុជាទទួលបានជោគជ័យល្អនៅក្នុងការទាក់ទាញលំហូរការវិនិយោគផ្ទាល់ពីបរទេស ដោយសារគោលនយោបាយវិនិយោគ និងពាណិជ្ជកម្មសេរីរបស់ខ្លួន ........ ២១
  - ទំនុកចិត្តលើប្រព័ន្ធធនាគារបន្តគាំទ្រការដាក់ប្រាក់បញ្ញើជារូបិយវត្ថុបរទេស ........ ២២
  - គិតជាចំណែកនៃ ផសស ឥណទានរបស់វិស័យធនាគារនៅកម្ពុជាមានកម្រិតខ្ពស់ជាងឥណទានរបស់វិស័យធនាគារនៅឥណ្ឌូនេស៊ី និងហ្វីលីពីន ........ ២៥
  - ការពង្រីកសារពើពន្ធបានជំរុញតម្រូវការក្នុងស្រុក ការប្រើប្រាស់ និងការនាំចូល ........ ២៧
  - ស្ថានភាពប្រាក់ចំណូលនៅឆ្នាំនេះនៅតែរឹងមាំ និងត្រូវបានព្យាករណ៍ថានឹងឆ្លើយតប ឬលើសគោលដៅថវិកាឆ្នាំ 2018 ........ ២៧
  - ប្រទេសចិនគឺជាអ្នកផ្តល់ឥណទានធំជាងគេ ដែលមានចំណែកជិតពាក់កណ្តាលនៃបំណុលរបស់កម្ពុជាដែលមិនទាន់សង ........ ២៩
  - ដោយសារដំណើរការនាំចេញដែលល្អជាងការរំពឹងទុក កំណើនការប្រើប្រាស់ និងសុទិដ្ឋិនិយមរបស់វិនិយោគិន ទស្សនវិស័យកំណើនត្រូវបានកែសម្រួលឡើងវិញ ........ ២៩
  - មានហានិភ័យកាន់តែច្រើនដោយសារតែឥណទានក្នុងស្រុកបន្តហូរចូលទៅលើវិស័យសំណង់ និងអចលនទ្រព្យ ........ ៣០
  - ឥទ្ធិពលដែលអាចកើតមានពីជម្លោះពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក និងប្រទេសចិនលើសេដ្ឋកិច្ចកម្ពុជា ........ ៣១
  - ការគាំពារសុខភាពនៃវិស័យហិរញ្ញវត្ថុគឺជាអាទិភាពខ្ពស់បំផុត ........ ៣១
  - កម្ពុជាត្រូវការការជំរុញការវិនិយោគបន្ថែមទៀតច្រើន ដើម្បីសម្រេចបានគោលដៅក្នុងការក្លាយជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ ........ ៣២

**ផ្នែកទី 2 ៖ អត្ថបទជម្រើស ៖ តើកម្ពុជាអាចក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ 2030 និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ 2050 ដែរឬទេ?** ........ ៣៥

- I. សេចក្តីផ្តើម ........ ៣៥
- II. ការផ្លាស់ប្តូររចនាសម្ព័ន្ធ ........ ៣៦
- III. ការវាយតម្លៃទៅលើសក្តានុពលកំណើនរយៈពេលវែងរបស់កម្ពុជា ........ ៣៨
- IV. ជម្រើសគោលនយោបាយ ........ ៤៩

**ឧបសម្ព័ន្ធ ៖ ការពិពណ៌នាអំពីលំនាំកំណើនរយៈពេលវែង** ........ ៥២

**ប្រទេសកម្ពុជា ៖ សូចនាករសំខាន់ៗ** ........ ៥៤

**ឯកសារយោង** ........ ៥៦

# សេចក្តីថ្លែងអំណរគុណ

ការរៀបចំរបាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជាឆ្នាំ ២០១៨ នៅកម្ពុជា (CEU) ស្ថិតក្រោមការដឹកនាំរបស់លោក លី សូដេត ដោយមានការរួមចំណែកពីលោក Miguel Eduardo Sánchez Martín។ អត្ថបទជម្រើស គឺ "តើកម្ពុជាអាចក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ ២០៥០ ដែរឬទេ?" ដែលត្រូវបានរៀបចំឡើងដោយ Steven Michael Pennings ដោយមានការរួមចំណែកពី Jorge Luis Guzman Correa និង Norman V. Loayza ព្រមទាំងទទួលបានយោបល់ពីលោក លី សូដេត និងលោក ភឹម រុនស៊ីណារិទ្ធ។ លោកស្រី គី លីនណា គឺជាជំនួយការផ្នែកស្រាវជ្រាវ។ លោក តុង គឹមស៊ុន បានផ្តល់ធាតុចូលផ្នែកភាពក្រីក្រ។ លោក ប៊ូ សារឿន បានជួយក្នុងការចេញផ្សាយព័ត៌មាន ការបង្ហាញគេហទំព័រ និងការផ្សព្វផ្សាយព្រឹត្តការណ៍នានា។

ក្រុមការងារនេះបានធ្វើការក្រោមការដឹកនាំរបស់ លោក Deepak Mishra ជាអ្នកគ្រប់គ្រងលើផ្នែកស្តីពីការអនុវត្តម៉ាក្រូសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការវិនិយោគលើពិភពលោក។ ក្រុមការងារសូមថ្លែងអំណរគុណចំពោះដំបូន្មាន និងយោបល់របស់លោកស្រី Ellen A. Goldstein នាយកប្រចាំប្រទេសភូមា កម្ពុជា និងឡាវ និងលោកស្រី Inguna Dobraja នាយកប្រចាំប្រទេសកម្ពុជា។ សហសេវិករបស់ធនាគារពិភពលោកមួយចំនួន រួមមាន Bronwyn Grieve, Ekaterine Vashakmadze, Ergys Islamaj, Francesca de Nicola, Lan Van Nguyen, Phyrum Kov, Ratchada Anantavrasilpa, Sinem Celik, Sudhir Shetty និង Ulla Heher បានផ្តល់យោបល់លើសេចក្តីព្រាងនៃរបាយការណ៍នេះ។

ក្រុមការងារសូមអរគុណដល់អាជ្ញាធរកម្ពុជា ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា សម្រាប់កិច្ចសហប្រតិបត្តិការ និងការគាំទ្ររបស់ពួកគាត់។ របាយការណ៍ក៏ទទួលបានផលប្រយោជន៍ពីដំបូន្មាន យោបល់ និងទស្សនៈរបស់អ្នកពាក់ព័ន្ធនានានៅក្នុងប្រទេសកម្ពុជា រួមទាំងអ្នកអាន និងអ្នករិះគន់ផងដែរ។

របាយការណ៍នេះត្រូវបានផលិតពីរដងក្នុងមួយឆ្នាំ ផ្តល់ព័ត៌មានបច្ចុប្បន្នភាពស្តីពីការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា។ ឯកសារនេះត្រូវបានចែកចាយ និងពិភាក្សាយ៉ាងទូលំទូលាយ រួមទាំងក្នុងចំណោមអាជ្ញាធរកម្ពុជា ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ស្ថាប័នស្រាវជ្រាវ និងផ្តល់យោបល់ អង្គការសង្គមស៊ីវិល និងសាកលវិទ្យាល័យនានា។

សម្រាប់ព័ត៌មានអំពីធនាគារពិភពលោក និងសកម្មភាពរបស់ធនាគារពិភពលោកនៅកម្ពុជា សូមមើលគេហទំព័ររបស់យើងតាមរយៈអាស័យដ្ឋាន: www.worldbank.org/cambodia ។

ដើម្បីបញ្ចូលនៅក្នុងបញ្ជីចែកចាយអ៊ីមែល CEU និងការបោះពុម្ពផ្សាយដែលពាក់ព័ន្ធសូមទាក់ទង លោកស្រី អាត សុជាតិ (sath@worldbank.org)។ សម្រាប់សំណួរអំពីខ្លឹមសារនៃអត្ថបទនេះសូមទាក់ទងលោក ប៊ូ សារឿន (sbou@worldbank.org)។

# ពាក្យកាត់

| | |
|---|---|
| **ABSD** | ពន្ធប្រថាប់ត្រាបន្ថែមសម្រាប់អ្នកទិញ |
| **AFTA** | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន |
| **ASEAN** | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| **bbl** | ធុង |
| **BOT** | ធនាគារប្រទេសថៃ |
| **CDC** | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| **CEU** | បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា |
| **CR** | ប្រាក់រៀល |
| **DP** | ដៃគូអភិវឌ្ឍន៍ |
| **EAP** | អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក |
| **EBA** | អ្វីគ្រប់យ៉ាង លើកលែងតែអាវុធ |
| **EMDEs** | ទីផ្សារដែលងើបឡើង និងប្រទេសកំពុងអភិវឌ្ឍន៍ |
| **EOP** | ចុងគ្រា |
| **EU** | សហភាពអឺរ៉ុប |
| **FCD** | ប្រាក់បញ្ញើរូបិយវត្ថុបរទេស |
| **FDI** | វិនិយោគដោយផ្ទាល់ពីបរទេស |
| **GDCE** | អគ្គនាយកដ្ឋានគយ និងរដ្ឋាករ |
| **GDP** | ផលិតផលក្នុងស្រុកសរុប |
| **GMAC** | សមាគមរោងចក្រកាត់ដេរនៅកម្ពុជា |
| **GNI** | ចំណូលជាតិសរុប |
| **GTAP** | គម្រោងវិភាគពាណិជ្ជកម្មសកល |
| **GVC** | សង្វាក់តម្លៃសកល |
| **ICOR** | ផលធៀបនៃទុន និងផល កើនឡើង |
| **IDP** | គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម |
| **IMF** | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| **LPCO** | ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា |
| **LTGM** | លំនាំកំណើនរយៈពេលវែង |
| **LTV** | ឥណទានធៀបនឹងតម្លៃ |
| **MA** | មធ្យមភាគប្រែប្រួល |
| **MAFF** | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| **MDI** | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលបញ្ញើ |
| **MEF** | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **MFI** | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ |
| **MOEYS** | ក្រសួងអប់រំ យុវជន និងកីឡា |
| **MOP** | ក្រសួងផែនការ |
| **MPK** | កំណើនផលនៃមូលធន |
| **NCD** | វិញ្ញាបនប័ត្របញ្ញើដែលអាចជួញដូរបាន |
| **NIS** | វិទ្យាស្ថានជាតិស្ថិតិ |
| **NPL** | កម្ចីមិនដំណើរការ |
| **NSDP** | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| **PC** | សម្រាប់មនុស្សម្នាក់ៗ |
| **PDR** | សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិត |
| **PFM** | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| **ppts** | ភាគរយពិន្ទុ |
| **RGC** | រាជរដ្ឋាភិបាលកម្ពុជា |
| **RMS** | យុទ្ធសាស្ត្រប្រមូលចំណូល |
| **RS** | យុទ្ធសាស្ត្រចតុកោណ |
| **SDR** | សិទ្ធិដកប្រាក់ពិសេស |
| **SEA** | អាស៊ីអាគ្នេយ៍ |
| **SME** | សហគ្រាសធុនតូចនិងមធ្យម |
| **TVET** | ការអប់រំ និង បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| **UMI** | ប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ |
| **US$** | ដុល្លារអាមេរិក |
| **VAT** | ពន្ធលើតម្លៃបន្ថែម |
| **WBG** | ក្រុមធនាគារពិភពលោក |
| **YTD** | ពីដើមឆ្នាំដល់បច្ចុប្បន្ន |
| **y/y or yoy** | ធៀបនឹងឆ្នាំមុន |





# ខ្លឹមសារសង្ខេប

## ការអភិវឌ្ឍថ្មីៗ

**កំណើនសេដ្ឋកិច្ចនៅតែមានភាពរឹងមាំ ដែលជាបឋមជំរុញដោយកំណើននៃការប្រើប្រាស់ និងការនាំចេញដ៏រឹងមាំ។** តម្រូវការក្នុងស្រុកបានកើនឡើងដោយសារតែកំណើនប្រាក់ឈ្នួលខ្ពស់ និងការវិនិយោគសាធារណៈច្រើនជាងមុន និងជំរុញដោយកំណើនថវិកាជាតិ។ ការចំណាយសាធារណៈត្រូវបានបង្កើនថវិការហូតដល់ 24.6 ភាគរយនៃ ផសស ក្នុងឆ្នាំ 2018 កើនឡើងពី 23.1 ភាគរយនៃ ផសស ក្នុងឆ្នាំ 2017។ ក្នុងពេលជាមួយគ្នានេះដែរ តម្រូវការខាងក្រៅប្រទេសដ៏រឹងមាំបានបង្កើនការនាំចេញផលិតផលសម្លៀកបំពាក់ និងស្បែកជើង ដោយកើនឡើង 16.1 ភាគរយ (ធៀបនឹងឆ្នាំមុន) ក្នុងអំឡុងឆមាសទីមួយក្នុងឆ្នាំ 2018 ដែលជាអត្រាកំណើនខ្ពស់សម្រាប់ពីរឆ្នាំកន្លងទៅ កើនពី 8.3 ភាគរយ នៅបំណាច់ឆ្នាំ 2017។ ចំនួនភ្ញៀវទេសចរបានកើនដល់ 3 លាននាក់នៅក្នុងអំឡុងឆមាសទីមួយក្នុងឆ្នាំ 2018 ក្នុងអត្រាកំណើន 13.6 ភាគរយ (ធៀបនឹងឆ្នាំមុន) កើនពី 11.8 ភាគរយ ក្នុងឆ្នាំ 2017។ កំណើននេះត្រូវបានជំរុញដោយកំណើនភ្ញៀវទេសចរដែលធ្វើដំណើរតាមផ្លូវអាកាសពីប្រទេសចិន។

**លំហូរមូលធន ដែលភាគច្រើនជាការវិនិយោគផ្ទាល់ពីបរទេស នៅតែបន្តកើនឡើង និងជួយឲ្យវិស័យក្រៅប្រទេសរបស់កម្ពុជាមានស្ថិរភាព។** ទិន្នន័យផ្លូវការបង្ហាញពីការកើនឡើងនៃការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យកម្មន្តសាល ជាពិសេសឧស្សាហកម្មវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងការកែច្នៃផលិតផលកសិកម្ម។ សកម្មភាពសំណង់ដ៏សកម្ម នៅតែបន្តទទួលហិរញ្ញប្បទានពីកំណើនលំហូរការវិនិយោគផ្ទាល់ពីបរទេស និងឥណទានក្នុងស្រុក។ ការវិនិយោគផ្ទាល់ពីបរទេសត្រូវបានប៉ាន់ស្មានថាកើនឡើង 14.3 ភាគរយ (ធៀបនឹងឆ្នាំមុន) ក្នុងអំឡុងឆមាសទី 1 ក្នុងឆ្នាំ 2018។ ប្រហែលជា 90 ភាគរយ នៃលំហូរការវិនិយោគនេះ (មិនរាប់បញ្ចូលលំហូរ ក្នុងវិស័យហិរញ្ញវត្ថុ) មានប្រភពមកពីប្រទេសចិន ហើយផ្តោតទៅវិស័យសំណង់ និងអចលនទ្រព្យ កសិកម្ម និងការកែច្នៃផលិតផលកសិកម្ម និងវិស័យកាត់ដេរ។ ចំណែកដែលកើនឡើងមួយនៃការវិនិយោគផ្ទាល់ពីបរទេសត្រូវបានវិនិយោគក្នុងវិស័យផលិតភាព គឺមានផ្នែកកម្មន្តសាល និងកសិកម្ម បើទោះបីជាចំណែកនេះនៅតែមានចំនួនតិចប្រហែល 20 ភាគរយនៃលំហូរសរុប។

**ការកើនឡើងនៃប្រាក់ចំណូលសម្រាប់ប្រើប្រាស់ នៅតែជាកត្តាជំរុញតម្រូវការក្នុងស្រុក និងបង្កើនសកម្មភាពសេដ្ឋកិច្ច។** កំណើនប្រាក់ឈ្នួលយ៉ាងលឿនក្នុងវិស័យឯកជន និងវិស័យសាធារណៈ បានបង្កើនតម្រូវការក្នុងស្រុកដ៏រឹងមាំ ដែលត្រូវបានបំពេញដោយកំណើននៃការនាំចូល។ ការនាំចូលយានយន្ត និងដែក ដែលបង្ហាញពីការប្រើប្រាស់ក្នុងស្រុក និងតម្រូវការក្នុងវិស័យសំណង់ បានកើនឡើងខ្លាំង ប្រមាណ 81.4 ភាគរយសម្រាប់យានយន្ត និង 50 ភាគរយសម្រាប់ដែក នៅខែ មិថុនា ឆ្នាំ 2018 ជាហេតុធ្វើឲ្យឱនភាពគណនីចរន្តកើនឡើងបន្តិចនៅឆមាសទីមួយក្នុងឆ្នាំ 2018 ប៉ុន្តែនៅតែទទួលបានហិរញ្ញប្បទានទាំងស្រុងពីលំហូរវិនិយោគផ្ទាល់ពីបរទេស។

**កំណើនឥណទាននៅតែមានសន្ទុះ បើទោះបីជាមានកំណើនយឺតជាងមុនក្ដី។** កំណើនឥណទាននៅតែថយចុះបន្តិចក្ដី ប៉ុន្តែផលធៀបឥណទាន និង ផសស របស់ធនាគារ (និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ) កើនដល់កម្រិតខ្ពស់បំផុត គឺ 73 ភាគរយ (និង 20 ភាគរយ) នៅចុងខែ មិថុនា ឆ្នាំ 2018 ដោយកើនពី 31.4 ភាគរយ (និង 3.8 ភាគរយ) នៅឆ្នាំ 2010។ មកទល់ពេលនេះ ប្រព័ន្ធធនាគារនៅតែទទួលបានទំនុកចិត្តខ្លាំង ហើយប្រាក់បញ្ញើក្នុងវិស័យឯកជន (ភាគច្រើនជាប្រាក់ដុល្លារអាមេរិក) បានកើនឡើង 22.4 ភាគរយ (ធៀបនឹងឆ្នាំមុន) នៅខែ មិថុនា ឆ្នាំ 2018។ ប្រាក់បម្រុងអន្តរជាតិដុលបានកើនឡើងដល់ 9 ពាន់លានដុល្លារ ឬស្មើនឹង 6 ខែ នៃការនាំចូលនាពេលអនាគត។ ប្រាក់រៀលកម្ពុជាដែលផ្សារភ្ជាប់ជាមួយប្រាក់ដុល្លារអាមេរិក ដោយសារតែសេដ្ឋកិច្ចកម្ពុជាមានកម្រិតដុល្លាររូបនីយកម្មខ្ពស់នោះ បានចុះថ្លៃបន្តិច ដោយមានអត្រាប្ដូរប្រាក់ 4.082 រៀល/ដុល្លារ នៅចុងខែ កញ្ញា ឆ្នាំ 2018 ធៀបនឹង 4.037 រៀល/ដុល្លារ នៅចុងខែ ធ្នូ ឆ្នាំ 2017។ ការកើនឡើងថ្លៃម្ហូបអាហារ (និងទឹកភ្លើង) បានធ្វើឲ្យអតិផរណាកើនឡើងដល់ 2.9 ភាគរយ (ធៀបនឹងឆ្នាំមុន) នៅខែ មិថុនា ឆ្នាំ 2018 កើនពី 2.2 ភាគរយនៅខែ ធ្នូ ឆ្នាំ 2017។ ជាលទ្ធផល អត្រាប្ដូរប្រាក់ពិតបន្តកើនឡើង។

**ការពង្រីកសារពើពន្ធយ៉ាងលឿនបានជំរុញការប្រើប្រាស់ និងកំណើន។** ឱនភាពសារពើពន្ធទូទៅ (រួមទាំងជំនួយឥតសំណង) ត្រូវបានរំពឹងថាធំជាងមុនគឺ 4.2 ភាគរយនៅឆ្នាំ 2018 កើនពី 1.6 ភាគរយនៅឆ្នាំ 2017។ យ៉ាងណាក៏ដោយ កម្រិតបំណុលរបស់កម្ពុជានៅតែមានកម្រិតទាបនៅឡើយបើផ្អែកលើការវិភាគអំពីនិរន្តរភាពបំណុលរបស់ធនាគារពិភពលោក/មូលនិធិរូបិយវត្ថុអន្តរជាតិនៅឆ្នាំ 2018 ដោយហេតុថា អាជ្ញាធរកម្ពុជាទទួលបំណុលពីខាងក្រៅដែលមានសម្បទានតែប៉ុណ្ណោះ។ លើសពីនេះទៀត បន្ទាប់ពីការពង្រឹងសារពើពន្ធ និងការងារប្រមូលប្រាក់ចំណូលដ៏រឹងមាំ ក្នុងរយៈពេលជាច្រើនឆ្នាំមក អាជ្ញាធរកម្ពុជាបានបង្កើនសារពើពន្ធក្នុងទម្រង់ជាប្រាក់បញ្ញើរដ្ឋាភិបាល ដែលមានចំនួនប្រមាណ 13 ភាគរយនៃ ផសស នៅត្រឹមពាក់កណ្ដាលឆ្នាំ 2018។

## ទស្សនវិស័យអនាគត និងហានិភ័យ

**បន្ទាប់ពីឥទ្ធិពលនៃការជំរុញសារពើពន្ធបានបញ្ចប់នៅក្រោយឆ្នាំ 2018 កំណើនរបស់ប្រទេសកម្ពុជាត្រូវបានរំពឹងថានឹងត្រឡប់ទៅមានល្បឿនតាមសក្ដានុពលរយៈពេលវែង។** កំណើនសេដ្ឋកិច្ចរបស់កម្ពុជា ដែលមាននិន្នាការថយចុះជាលំដាប់តាំងពីឆ្នាំ 2013 មក ត្រូវបានរំពឹងថានឹងបន្តកើនឡើងបន្តិច ដោយមានកំណើន 7.1 ភាគរយនៅឆ្នាំ 2018 ដោយសារតែតម្រូវការក្នុងស្រុក និងតម្រូវការខាងក្រៅច្រើន។ ដោយសារតែកំណើនសេដ្ឋកិច្ចនាពេលថ្មីៗនេះត្រូវបានជំរុញមួយផ្នែកដោយការពង្រីកសារពើពន្ធយ៉ាងច្រើន ទស្សនវិស័យកំណើនរបស់កម្ពុជាត្រូវបានព្យាករថានឹងថយចុះបន្តិចមកនៅត្រឹម 6.8 ភាគរយនៅក្នុងរយៈពេលពីរឆ្នាំខាងមុខនេះ។ ទស្សនវិស័យល្អរយៈពេលវែងនេះគឺដោយសារតែកំណើនលំហូរការវិនិយោគផ្ទាល់ពីបរទេសទៅវិស័យកម្មន្តសាល និងកសិកម្ម និងទំនាក់ទំនងកាន់តែល្អជាមួយនឹងសង្វាក់ផ្គត់ផ្គង់រវាងការវិនិយោគផ្ទាល់ពីបរទេស និងក្រុមហ៊ុនកម្ពុជា។ អាជ្ញាធរកម្ពុជាបានចាប់ផ្ដើមការផ្ដួចផ្ដើមថ្មីៗមួយចំនួន ក្នុងការជំរុញសហគ្រាសខ្នាតតូច និងមធ្យម រួមទាំងការពង្រឹងទំនាក់ទំនងជាមួយវិស័យការវិនិយោគផ្ទាល់ពីបរទេស (សូមមើលប្រអប់ 2)។ កំណើនសេដ្ឋកិច្ចរឹងមាំត្រូវបានរំពឹងថា នឹងបន្តកាត់បន្ថយភាពក្រីក្រតទៅទៀត។

**ហានិភ័យវិស័យហិរញ្ញវត្ថុនៅតែបន្តកើនឡើង ដោយទាក់ទិនកាន់តែខ្លាំងឡើងជាមួយវិស័យសំណង់ និងអចលនទ្រព្យ។** កំណើនឥណទានក្នុងស្រុកនៅកម្ពុជាមានសន្ទុះលឿនជាងប្រទេសផ្សេងទៀតក្នុងអាស៊ីបូព៌ា ដោយកើនឡើង 9 ដងក្នុងរយៈពេល 12 ឆ្នាំកន្លងទៅ។ ដោយសារតែវិស័យសំណង់ និងអចលនទ្រព្យងាយឈានចូលវដ្ដនៃកំណើន និងការធ្លាក់ចុះ កំណើនហិរញ្ញប្បទានឥណទានក្នុងស្រុកសម្រាប់វិស័យសំណង់នេះ បានធ្វើឲ្យវិស័យហិរញ្ញវត្ថុកាន់តែងាយរងគ្រោះ។ លើសពីនេះទៀត វិស័យសំណង់មានកំណើនរយៈពេលវែង តាំងពីពេលដែលវិបត្តិហិរញ្ញវត្ថុសកលនៅឆ្នាំ 2008 និង 2009 បានបញ្ចប់។

**ហានិភ័យខាងក្រៅក៏កើនឡើងដែរ ព្រោះតែលទ្ធភាពនៃការដកការអនុគ្រោះពន្ធ "អ្វីគ្រប់យ៉ាង លើកលែងតែអាវុធ (EBA)" សម្រាប់កម្ពុជា ជម្លោះផ្នែកពាណិជ្ជកម្មរវាងមហាអំណាចពាណិជ្ជកម្មទាំងពីរប្រទេស និងការបន្តការកើនថ្លៃប្រាក់ដុល្លារអាមេរិកធៀបនឹងរូបិយវត្ថុសកលភាគច្រើន។** ទីផ្សារសហភាពអឺរ៉ុបស្មើនឹងជាងមួយភាគបីនៃការនាំចេញសំខាន់ៗរបស់កម្ពុជា។ ដូច្នេះ ការបាត់បង់ការអនុគ្រោះពន្ធ ដែលបច្ចុប្បន្នផ្ដល់លទ្ធភាពឲ្យកម្ពុជានាំផលិតផលគ្រប់យ៉ាង លើកលែងតែអាវុធ ទៅទីផ្សារសហភាពអឺរ៉ុបដោយមិនបង់ពន្ធ អាចនឹងធ្វើឲ្យការនាំចេញរបស់កម្ពុជាមានកំណើនយឺតជាងមុន និងធ្វើឲ្យប៉ះពាល់ដល់ទីផ្សារការងារនៅកម្ពុជាក្នុងរយៈពេលខ្លី។ ជម្លោះពាណិជ្ជកម្មរវាងប្រទេសមានជាងគេក្នុងសកលលោក ជាពិសេស សហរដ្ឋអាមេរិក និងប្រទេសចិន នឹងជះផលអវិជ្ជមានលើពាណិជ្ជកម្មសកលលោក និងរាំងស្ទះដល់សង្វាក់តម្លៃតំបន់ និងសកល ដែលធ្វើឲ្យមានឥទ្ធិពលមិនច្បាស់លាស់មកលើកម្ពុជា។ ដោយសារតែការវិនិយោគផ្ទាល់ពីបរទេស វិស័យទេសចរណ៍ និងជំនួយអភិវឌ្ឍន៍ផ្លូវការរបស់កម្ពុជា ពឹងផ្អែកកាន់តែខ្លាំងលើប្រទេសចិន ការធ្លាក់ចុះលឿននៃសេដ្ឋកិច្ចប្រទេសចិននឹងធ្វើឲ្យទស្សនវិស័យកំណើនរបស់កម្ពុជាមានការថយចុះក្នុងរយៈពេលខ្លី និងមធ្យម។ ស្ថានភាពកាន់តែតឹងត្បិតនៃរូបិយវត្ថុសកល និងការឡើងថ្លៃនៃប្រាក់ដុល្លារ

អាមេរិក អាចកាត់បន្ថយភាពប្រកួតប្រជែងក្នុងការនាំចេញ ដោយសារតែកម្ពុជាមានកម្រិតដុល្លាររូបនីយកម្មខ្ពស់។

## សារគន្លឹះ និងជម្រើសគោលនយោបាយ

**ដោយសារតែកំណើនរយៈពេលវែងក្នុងវិស័យសំណង់ អ្វីដែលជាចំណុចអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា គឺការរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុក្នុងរយៈពេលខ្លី។** ថ្មីៗនេះ វិស័យអចលនទ្រព្យបានក្លាយជាការទិញ/លក់ប្រថុយប្រថាន ដើម្បីបានប្រាក់ចំណេញពីសកម្មភាពទិញ/លក់ដីធ្លីកើនឡើងជាមួយនឹងប្រាក់ចំណេញមិនសូវច្បាស់។ កំណើនយ៉ាងលឿននៃការវិនិយោគផ្ទាល់ពីបរទេសបានបិទបាំងភាពងាយរងគ្រោះនៃវិស័យហិរញ្ញវត្ថុ បង្កដោយកំណើនឥណទានយ៉ាងរហ័សរយៈពេលយូរ។ ដូច្នេះ ចាំបាច់ត្រូវបង្កើត គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ប្រយ័ត្នប្រយែង រួមទាំង វិធានការហិរញ្ញវត្ថុ និងសារពើពន្ធ ដើម្បីកាត់បន្ថយ សកម្មភាពទិញ/លក់ប្រថុយប្រថានដែលទទួលបានហិរញ្ញប្បទានពីវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ។ ជាការសំខាន់ផងដែរក្នុងការបង្កើតគោលការណ៍ណែនាំស្តីពីការផ្តល់កម្ចី រួមទាំង កម្រិតកំណត់សម្រាប់ផលធៀបតម្លៃ និងឥណទាន និងការពិចារណាទៅលើការកំណត់ពន្ធបន្ថែមលើការទិញ/លក់ទ្រព្យសម្បត្តិ ជាពិសេស ដីធ្លី ក្នុងគោលបំណងវិនិយោគ (ដែលមានភាពប្រថុយប្រថាន)។ ដូចគ្នានេះដែរ ត្រូវពិនិត្យឡើងវិញទៅលើចំណាត់ថ្នាក់ឥណទានដែលមិនដំណើរការ។ លើសពីនេះទៀត ត្រូវពិចារណាទៅលើវិធានការប្រុងប្រយ័ត្នផ្សេងទៀត ដូចជា ផលធៀបឥណទាន និងប្រាក់ចំណូល ការបង្កើនអត្រាប្រាក់បង់ដំបូង និងកត្តាផ្សេងៗទៀត។

**ដើម្បីស្រូបយកកំណើនលំហូរវិនិយោគផ្ទាល់ពីបរទេសលើវិស័យកម្មន្តសាល និងការកែច្នៃផលិតផលកសិកម្ម ត្រូវដោះស្រាយបញ្ហាខ្វះខាតផ្នែកហេដ្ឋារចនាសម្ព័ន្ធ។** បើទោះជាកំពុងតែមានកំណើនក្តី ការវិនិយោគបន្ថែមដើម្បីកែលម្អ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ត្រូវតែជាអាទិភាពក្នុងការធ្វើឲ្យកម្ពុជាធ្វើសមាហរណកម្មល្អទៅក្នុងសង្វាក់តម្លៃតំបន់ (និងសកល)។ ដើម្បីសម្រួលដល់ការពង្រីកពាណិជ្ជកម្ម ការភ្ជាប់ទំនាក់ទំនង ដូចជា ការកែលម្អមធ្យោបាយដឹកជញ្ជូន និងឡូជីស្ទីក ត្រូវបានកំណត់ឃើញនៅក្នុងការរៀបចំផែនការជាតិស្តីពីឡូជីស្ទីក និងការបង្កើតក្រុមប្រឹក្សាជាតិសម្រាប់ឡូជីស្ទីក។ ចំពោះសមត្ថភាពឡូជីស្ទីក កម្ពុជាស្ថិតនៅលំដាប់លេខ 98 ក្នុងចំណោមប្រទេស 160 ក្នុងសន្ទស្សន៍ស្តីពីប្រតិបត្តិការឡូជីស្ទីកឆ្នាំ 2018 ដោយបានថយចុះពីលំដាប់ទី 73 ក្នុងឆ្នាំ 2016។ ជាមធ្យម ប្រទេសនាំចេញគ្រឿងអេឡិចត្រូនិកជោគជ័យ ដូចជា ថៃ និងម៉ាឡេស៊ីឈរនៅលំដាប់លើសគេទី 40។

**ការបង្កើនប្រាក់សន្សំក្នុងស្រុកជាកត្តាសំខាន់បំផុតក្នុងការជំរុញការវិនិយោគរយៈពេលមធ្យម។** ដូចបានពិភាក្សានៅក្នុងអត្ថបទជម្រើស “តើកម្ពុជាអាចក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ 2030 និងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ 2050 ឬទេ?” ប្រាក់សន្សំក្នុងស្រុកដុលរបស់កម្ពុជា ដែលនៅក្រោម 20 ភាគរយនៃ ផសស មានអត្រាទាបបំផុតក្នុងតំបន់។ ដូច្នេះ កម្ពុជាត្រូវពឹងផ្អែកយ៉ាងខ្លាំងលើប្រាក់សន្សំបរទេសក្នុងទម្រង់ជាការវិនិយោគផ្ទាល់ពីបរទេស ដែលមិនត្រឹមតែមានភាពប្រែប្រួលប៉ុណ្ណោះទេ ថែមទាំងមិនស្ថិតស្ថេរក្នុងរយៈពេលវែងទៀតផង។ ដូច្នេះ ជាការចាំបាច់ត្រូវចាប់ផ្តើមបង្កើតធនធានក្នុងស្រុកបន្ថែម ដើម្បីផ្តល់ហិរញ្ញប្បទានការវិនិយោគប្រកបដោយផលិតភាព នៅពេលដែលកម្ពុជាកំពុងខិតខំឲ្យក្លាយជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ក្នុងរយៈពេល 4 ទសវត្សរ៍ខាងមុខនោះ។ ដូច្នេះ ចាំបាច់ត្រូវមានគោលនយោបាយគាំទ្រដល់ការសន្សំប្រាក់ ដែលស្រដៀងគ្នានឹងគោលនយោបាយរបស់ប្រទេសនានាក្នុងតំបន់ (សូមមើលប្រអប់ S2) ដើម្បីជំរុញឲ្យគ្រួសារសន្សំប្រាក់ និងជំរុញឲ្យអាជីវកម្មវិនិយោគបន្ថែមទៀត។ ការពង្រីកក្របខណ្ឌនិយ័តកម្ម និងត្រួតពិនិត្យ ការកែលម្អប្រព័ន្ធរាយការណ៍ហិរញ្ញវត្ថុ ការបង្កើតការអនុវត្តល្អក្នុងការគ្រប់គ្រងសាជីវកម្ម និងការបង្កើតប្រព័ន្ធការពារហិរញ្ញវត្ថុ នឹងជួយជំរុញការសន្សំប្រាក់បន្ថែមទៀត។



# រូប ES. 1 ៖ ទិដ្ឋភាពរួមស្តីពីសេដ្ឋកិច្ចកម្ពុជា

### កំណើនពិតកំពុងកើនឡើង...

កំណើនពិត (ភាគរយ)




### ...នៅពេលដែលការនាំចេញសំខាន់ៗកើនឡើង

ការនាំចេញសម្លៀកបំពាក់ (ភាគរយប្រែប្រួល ធៀបនឹងឆ្នាំមុន)




### ...វិស័យកសិកម្មងើបឡើងវិញ...

ផលិតផលស្រូវវស្សាកើនឡើង (គិតជាលានតោន)




### ...គាំទ្រដោយកំណើនលំហូរវិនិយោគផ្ទាល់ពីបរទេស

(ទ្រព្យសកម្មនៃការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត, ភាគរយនៃ ផសស)




### កំណើនឥណទានថយចុះ ប៉ុន្តែកម្ចីសម្រាប់វិស័យសំណង់បានកើនឡើង

ចំណែកនៃការផ្តល់កម្ចីក្នុងវិស័យសំណង់
និងវិស័យអចលនទ្រព្យនៃកំណើនឥណទាន (ភាគរយពិន្ទុ)




### ការពង្រីកសារពើពន្ធបានជំរុញតម្រូវការក្នុងស្រុក

ចំណាយទូទៅរបស់រដ្ឋាភិបាល (ភាគរយ ផសស)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មាន និងការព្យាកររបស់បុគ្គលិកធនាគារពិភពលោក
*សម្គាល់* ៖ pre= បឋម, p=ការព្យាករ, RHS= ខាងស្តាំ





ផ្នែកទី 1

# ការអភិវឌ្ឍសេដ្ឋកិច្ចថ្មីៗ និងទស្សនវិស័យ

# ផ្នែកទី 1 ៖ ការអភិវឌ្ឍសេដ្ឋកិច្ចថ្មីៗ និងទស្សនវិស័យ

## ការអភិវឌ្ឍសេដ្ឋកិច្ចថ្មីៗ

### កម្ពុជានៅតែមានកំណើនសេដ្ឋកិច្ចរឹងមាំ

**ជារួម សកម្មភាពសេដ្ឋកិច្ចរបស់កម្ពុជានៅតែមានភាពរឹងមាំ ដែលជំរុញដោយការប្រើប្រាស់ក្នុងស្រុក និងការនាំចេញ។** ក្នុងបរិបទដែលមានកំណើននៃការប្រើប្រាស់ ដំណើរការនាំចេញមានភាពប្រសើរជាងការរំពឹងទុក និងសុទិដ្ឋិនិយមរបស់វិនិយោគិន ទស្សនវិស័យនៃកំណើនត្រូវបានកែប្រែដោយបង្កើនឡើងបន្តិចក្នុងរយៈពេលខ្លី និងរយៈពេលមធ្យម។ កំណើនសេដ្ឋកិច្ចរបស់កម្ពុជាត្រូវបានរំពឹងថានឹងកើនឡើងដល់ 7.1 ភាគរយនៅឆ្នាំ 2018 (ធៀបនឹងតួលេខកំណើនផ្លូវការដែលត្រូវបានកែថ្មី 7 ភាគរយនៅឆ្នាំ 2017) (រូប 1)។

**កម្ពុជាស្ថិតក្នុងចំណោមប្រទេសមួយចំនួនតូចក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ដែលត្រូវបានរំពឹងថានឹងមានភាពប្រសើរបន្តិចផ្នែកកំណើន។** កំណើនរបស់ប្រទេសជឿនលឿននៅតែលើសពីកម្រិតសក្តានុពល បើទោះបីជាមានសញ្ញាអំពីការថយចុះបន្តិចក្តី[១]។ នៅសហរដ្ឋអាមេរិក ការជំរុញដ៏សំខាន់ផ្នែកសារពើពន្ធ នឹងជួយសកម្មភាពរយៈពេលខ្លីខាងមុខ។ កំណើនសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិកបានកើនដល់ 2.3 ភាគរយក្នុងឆ្នាំ 2017 ដែលមានការគាំទ្រដោយតម្រូវការក្នុងស្រុកខ្ពស់ ជាពិសេសការវិនិយោគ។ សេដ្ឋកិច្ចរបស់ប្រទេសដែលចាយប្រាក់អឺរ៉ូ បានកើនឡើង 2.4 ភាគរយក្នុងឆ្នាំ 2017 ជាកំណើនលឿនបំផុតចាប់តាំងពីមានវិបត្តិហិរញ្ញវត្ថុ ដែលឆ្លុះបញ្ចាំងពីភាពរឹងមាំនៃការប្រើប្រាស់ ការវិនិយោគ និងការនាំចេញ។ កំណើនសេដ្ឋកិច្ចរបស់ប្រទេសរីកចម្រើនត្រូវបានព្យាករណ៍ថាមានចំនួន 2.2 ភាគរយនៅឆ្នាំ 2018 ដែលថយចុះបន្តិចធៀបនឹងឆ្នាំមុន (ព្រោះថា ជាមួយសារពើពន្ធបន្ថែមនៅសហរដ្ឋអាមេរិកបានប៉ះប៉ូវដោយការថយចុះបន្តិចនៃកំណើនក្នុងប្រទេសរីកចម្រើនផ្សេងៗទៀត) ខណៈពេលដែលទំនុកចិត្តរបស់អ្នកប្រើប្រាស់នៅតែខ្ពស់ និងមានការបង្កើតការងារថ្មីៗជាបន្ត (សូមមើលប្រអប់ 1 ស្តីពីទស្សនវិស័យសេដ្ឋកិច្ចសកល និងតំបន់)។

**បន្ទាប់ពីការងើបឡើងវិញបន្តិចម្តងៗនៅក្នុងឆមាសទីពីរក្នុងឆ្នាំ 2017 មក ការនាំចេញរបស់កម្ពុជាបានកើនឡើងខ្លាំងដោយសារតែកំណើនតម្រូវការនៅសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប។** ការនាំចេញសរុបនៃផលិតផលវាយនភណ្ឌ សម្លៀកបំពាក់ និងស្បែកជើង មានចំនួន 74 ភាគរយនៃការនាំចេញទំនិញសរុបរបស់កម្ពុជា និងមានកំណើនពីរខ្ទង់ក្នុងអត្រាខ្ពស់បំផុតចំនួន 16.1 ភាគរយនៅឆមាសទីមួយក្នុងឆ្នាំ 2018 ដោយកើនពី 8.3 ភាគរយនៅចុងឆ្នាំ 2017 (រូប 2)។

**រូប 1 ៖ ការរួមចំណែកដល់កំណើនពិត**

(ភាគរយពិន្ទុ)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

*សម្គាល់* ៖ pre= បឋម p= ការព្យាករ

**រូប 2 ៖ កំណើននៃការនាំចេញសម្លៀកបំពាក់ និងស្បែកជើង**

(ពាន់លានដុល្លា ពីដើមឆ្នាំដល់បច្ចុប្បន្ន)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

*សម្គាល់* ៖ RHS= ខាងស្តាំ

[១] ទស្សនវិស័យសេដ្ឋកិច្ចសកល ខែ មិថុនា ឆ្នាំ 2018 ក្រុមធនាគារពិភពលោក រដ្ឋធានីវ៉ាស៊ីនតោន DC។

## ប្រអប់ 1

### ទស្សនវិស័យសេដ្ឋកិច្ចតំបន់ និងសកល[១]

**កំណើនសេដ្ឋកិច្ចសកលកំពុងបន្ថយល្បឿន ព្រោះថា ការងើបឡើងវិញនៃវិស័យពាណិជ្ជកម្ម និងកម្មន្តសាលបានថយចុះបន្តិច។** កំណើននេះត្រូវបានព្យាករណ៍ថានឹងថយចុះពី 3 ភាគរយក្នុងឆ្នាំ 2018 មកនៅត្រឹម 2.9 ភាគរយនៅឆ្នាំ 2019 នៅពេលដែលសេដ្ឋកិច្ចថយចុះ ហើយធនាគារជាតិធំៗបន្តលុបការសម្រួលគោលនយោបាយ ហើយកំណើនផ្នែកពាណិជ្ជកម្ម និងការវិនិយោគសកល កាន់តែថយចុះថែមទៀត (រូប B1.1)[២]។ កំណើនសេដ្ឋកិច្ចក្នុងប្រទេសរីកចម្រើនត្រូវបានព្យាករណ៍ថានឹងថយចុះបន្តិចពីអត្រា 2.2 ភាគរយនៅឆ្នាំ 2018 មកនៅត្រឹម 2 ភាគរយនៅឆ្នាំ 2019 និងបន្តថយចុះបន្ទៀតដល់ 1.6 ភាគរយនៅឆ្នាំ 2020 នៅពេលដែលបញ្ហាសមត្ថភាពក្លាយជាបញ្ហាចោទ។

**លក្ខខណ្ឌខាងក្រៅ ដែលមានភាពអវិជ្ជមានជាបន្តនៅឆ្នាំ 2018 ត្រូវបានរំពឹងថានឹងកាន់តែមិនសូវអំណោយផលសម្រាប់ទីផ្សារដែលងើបឡើង និងប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងអំឡុងពេលព្យាករណ៍នេះ។** ស្ថានភាពនេះឆ្លុះបញ្ចាំងពីកំណើនសេដ្ឋកិច្ចថយចុះបន្តិចនៅប្រទេសជឿនលឿន ការថយចុះបន្តិចនៃពាណិជ្ជកម្ម និងការវិនិយោគសកល ការបន្តឹងលក្ខខណ្ឌហិរញ្ញប្បទាន និងកំណើនភាពតានតឹងផ្នែកពាណិជ្ជកម្ម។ កំណើននៃទីផ្សារ និងប្រទេសកំពុងអភិវឌ្ឍន៍ដែលងើបឡើង ដែលនៅថេរក្នុងចំនួន 4.2 ភាគរយក្នុងឆ្នាំ 2018 ដោយសារតែប្រទេសមួយចំនួនជួបមានសម្ពាធហិរញ្ញវត្ថុ ត្រូវបានរំពឹងថានឹងកើនឡើងតែបន្តិចចំនួន 4.3 ភាគរយនៅឆ្នាំ 2019។ ពាណិជ្ជកម្មសកល ដែលកើនឡើងយ៉ាងខ្លាំងនៅឆ្នាំ 2017 ដោយសារតែវដ្តនៃកម្មន្តសាលសកល ត្រូវបានរំពឹងថានឹងមានសន្ទុះយឺតជាងការរំពឹងទុកនៅឆ្នាំ 2018 ហើយនឹងថយចុះបន្តិចបន្ថែមទៀតនៅអំឡុងឆ្នាំ 2019 និង 2020។ ភាពមិនប្រាកដប្រជានៃគោលនយោបាយពាណិជ្ជកម្មបានកើនឡើង ដែលធ្វើឲ្យមានសម្ពាធលើទស្សនវិស័យនៃការវិនិយោគ និងពាណិជ្ជកម្មសកល។ ជាទូទៅ ការចំណាយលើកម្ចីនៅទីផ្សារ និងប្រទេសកំពុងអភិវឌ្ឍន៍ដែលងើបឡើង បានថយចុះ បន្ទាប់ពីមានការឡើងថ្លៃនៃប្រាក់ដុល្លារអាមេរិក ការទប់ស្កាត់ហានិភ័យរបស់វិនិយោគិន និងការផ្តោតកាន់តែច្រើនលើភាពងាយរងគ្រោះតាមប្រទេស។ ចាប់តាំងពីការចាប់ផ្តើមឡើងថ្លៃប្រាក់ដុល្លារអាមេរិកសាជាថ្មីនៅខែ មេសា ឆ្នាំ 2018 តម្លៃរូបិយវត្ថុនៃទីផ្សារ និងប្រទេសកំពុងអភិវឌ្ឍន៍ដែលងើបឡើង បានធ្លាក់ចុះជាមធ្យមប្រមាណ 11 ភាគរយ។ បរិមាណគម្រោងវិនិយោគសរុបពីទីផ្សារ និងប្រទេសកំពុងអភិវឌ្ឍន៍ដែលងើបឡើង មានចំនួនច្រើនជាងគម្រោងវិនិយោគដែលមានបន្ទាប់ពីកំណើន Taper Tantrum នៅឆ្នាំ 2013 ដែលឆ្លុះបញ្ចាំងពីការលក់ចេញយ៉ាងច្រើនទាំងមូលនិធិសមធម៌ និងប័ណ្ណបំណុល។ ខណៈដែលវិបត្តិទីផ្សារហិរញ្ញវត្ថុកើតមាននៅប្រទេសទួរគី និងអាហ្សង់ទីនទីផ្សារ និងប្រទេសកំពុងអភិវឌ្ឍន៍ដែលងើបឡើងជាច្រើនផ្សេងទៀតក៏មានការបង្កើនការទប់ស្កាត់ហានិភ័យ។ ប្រទេសដែលមានតម្រូវការហិរញ្ញប្បទានខាងក្រៅយ៉ាងច្រើន និងគោលនយោបាយមិនច្បាស់លាស់ រងការប៉ះពាល់ខ្លាំងជាងគេ ដែលបង្ហាញថា វិនិយោគិនផ្តោតសំខាន់លើភាពងាយរងគ្រោះខាងក្រៅ និងទស្សនវិស័យកំណើន។ ស្ថានភាពហិរញ្ញប្បទានខាងក្រៅត្រូវបានរំពឹងថានឹងបន្តថយចុះនៅឆ្នាំ 2019 ដោយសារលែងមានការសម្រួលគោលនយោបាយរូបិយវត្ថុក្នុងប្រទេសជឿនលឿន ហើយផ្ទុយទៅវិញ មានវិធានការដែលកាន់តែមិនអំណោយផល។

**កំណើនសេដ្ឋកិច្ចក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិកត្រូវបានរំពឹងថានឹងបន្ថយល្បឿនជាបណ្តើរៗពីអត្រា 6.3 ភាគរយនៅឆ្នាំ 2018 មកត្រឹម 6 ភាគរយនៅឆ្នាំ 2019 និង 2020 (រូប B1.2)។** ការថយចុះកំណើនសេដ្ឋកិច្ចក្នុងតំបន់ឆ្លុះបញ្ចាំងពីការថយចុះជារចនាសម្ព័ន្ធ និងការថយចុះនៃការនាំចេញនៅខណៈពេលដែលការកើនឡើងភាពតានតឹងផ្នែកពាណិជ្ជកម្ម រវាងប្រទេសចិន និងសហរដ្ឋអាមេរិក។ សកម្មភាពក្នុងបណ្តាប្រទេសផ្សេងទៀត ក្នុងតំបន់ត្រូវបានរំពឹងថានឹងនៅទ្រឹងត្រឹមកម្រិតសក្តានុពលនៅឆ្នាំ 2019 ប៉ុន្តែមានហានិភ័យច្រើនចំពោះទស្សនវិស័យនេះ។ ស្ថានភាពនេះបង្ហាញពីស្ថានភាពប្រជាសាស្ត្រមិនល្អ និងការព្យាករពីសន្ទុះយឺតនៃកំណើនមូលធន ដែលជាការចាំបាច់ដើម្បីធ្វើឲ្យមានកំណើនផលិតភាព។ ស្ថានភាពហិរញ្ញប្បទានសកលដែលកាន់តែតឹង ការចំណាយខ្ពស់លើកម្ចី ការថយចុះនៃលំហូរមូលធន និងគោល

**រូប B1.1 ៖ កំណើន ផសស ពិត**

(ភាគរយ)




*ប្រភព* ៖ ហិរញ្ញវត្ថុអភិវឌ្ឍន៍សកល ខែមករា ឆ្នាំ 2019 (នឹងផ្សព្វផ្សាយឆាប់ៗនេះ)

**រូប B1.2 ៖ កំណើន ផសស ពិត**

(ភាគរយ)




*ប្រភព* ៖ ហិរញ្ញវត្ថុអភិវឌ្ឍន៍សកល ខែមករា ឆ្នាំ 2019 (នឹងផ្សព្វផ្សាយឆាប់ៗនេះ)

---

១ រៀបរៀងដោយ Ekaterinek T. Vashakmadze សេដ្ឋវិទូជាន់ខ្ពស់ប្រចាំប្រទេស ធនាគារពិភពលោក។

២ ចំណុចទាំងនេះជាការសន្មត ដែលនឹងត្រូវសម្រេចចុងក្រោយ និងផ្សព្វផ្សាយនៅក្នុងឯកសារស្តីពីទស្សនវិស័យសេដ្ឋកិច្ចសកល ខែ មករា ឆ្នាំ 2019 របស់ធនាគារពិភពលោក។

នយោបាយមិនច្បាស់លាស់ អាចរាំងស្ទះដល់កំណើនវិនិយោគនៅប៉ុន្មានឆ្នាំខាងមុខ ដែលនឹងកាន់តែធ្វើឲ្យប៉ះពាល់ដល់សក្តានុពលកំណើនថែមទៀត។

**តម្លៃទំនិញផ្សេងៗប្រែប្រួលក្នុងរយៈពេល 6 ខែចុងក្រោយនេះ។** បើទោះជាតម្លៃប្រេងបានកើនឡើងតាំងពីពាក់កណ្តាលឆ្នាំ 2018 មក តម្លៃទំនិញផ្សេងៗទៀតបានថយចុះ នៅខណៈដែលភាពតានតឹងផ្នែកពាណិជ្ជកម្មមានកាន់តែខ្លាំងឡើង (រូប B1.3)។ បន្ទាប់ពីការកើនថ្លៃគួរឲ្យកត់សម្គាល់នៅក្នុងឆមាសទីមួយឆ្នាំមុន តម្លៃលោហៈធាតុបានធ្លាក់ចុះយ៉ាងខ្លាំងនៅឆមាសទីពីរ បន្ទាប់ពីសហរដ្ឋអាមេរិកដាក់ពន្ធយ៉ាងច្រើនលើទំនិញនាំចូលពីប្រទេសចិន និងការព្រួយបារម្ភក្នុងទីផ្សារស្តីពីការថយចុះពាណិជ្ជកម្មសកល។ តម្លៃប្រេងត្រូវបានរំពឹងទុកថាមានតម្លៃជាមធ្យម 73 ដុល្លារ/ធុង នៅឆ្នាំ 2019 មុនពេលចុះមកត្រឹម 71 ដុល្លារ/ធុង នៅឆ្នាំ 2020 ដែលឡើង 4 ដុល្លារ/ធុង និង 2 ដុល្លារ/ធុង ដែលនេះជាការព្យាករនៅខែ មិថុនា (តម្លៃលោហៈធាតុត្រូវបានរំពឹងថានឹងថយចុះនៅអំឡុងឆ្នាំ 2019 និង 2020 ដោយសារការថយចុះតម្រូវការ)។ តម្លៃផលិតផលកសិកម្មត្រូវបានព្យាករណ៍ថានឹងនៅទ្រឹងនៅឆ្នាំ 2019 និង 2020 ដោយសារការផ្គត់ផ្គង់យ៉ាងច្រើន។

**តុល្យភាពនៃហានិភ័យចំពោះទស្សនវិស័យសកលមានភាពអវិជ្ជមាន។**

## រូប B1.3 ៖ ការព្យាករតម្លៃទំនិញសកល

(អត្រាប្តូរប្រាក់ដុល្លាណូមីណាល ឆ្នាំ 2010=100)




*ប្រភព* ៖ ហិរញ្ញវត្ថុអភិវឌ្ឍន៍សកល ខែមករា ឆ្នាំ 2019 (នឹងផ្សព្វផ្សាយឆាប់ៗនេះ)

ការវិវត្តន៍នៃទីផ្សារហិរញ្ញវត្ថុក្រៅផ្លូវការ អាចរីករាលដាលនៅក្នុងទីផ្សារ និងប្រទេសកំពុងអភិវឌ្ឍន៍ដែលងើបឡើង ជាមួយនឹងកំណើននៃភាពរងគ្រោះនៅក្នុងប្រទេសជាច្រើន។ លទ្ធភាពនៃកំណើនការរឹតត្បិតផ្នែកពាណិជ្ជកម្មនៅតែបន្តកើនឡើង ដែលអាចបង្កបញ្ហាធំធេងលើសង្វាក់តម្លៃសកល។ ម៉្យាងវិញទៀត គោលនយោបាយមិនច្បាស់លាស់ និងហានិភ័យភូមិសាស្ត្រនយោបាយ នៅតែកើនឡើង និងអាចប៉ះពាល់ជាអវិជ្ជមានលើទំនុកចិត្ត និងការវិនិយោគ ទាំងនៅក្នុងប្រទេសដែលរងផលប៉ះពាល់ និងលើសកលលោក។

**ហានិភ័យចំពោះទស្សនវិស័យក្នុងតំបន់ក៏កាន់តែមានទំនោរអវិជ្ជមាន និងកាន់តែកើនឡើង។** ការកើនឡើងនៃនិន្នាការការពារនិយម នៅតែបន្តបង្កើតភាពមិនប្រាកដប្រជាអំពីអនាគតនៃទំនាក់ទំនងពាណិជ្ជកម្មរឹងមាំ។ ការរឹតត្បិតផ្នែកពាណិជ្ជកម្មដោយប្រទេសជឿនលឿន នឹងធ្វើឲ្យប៉ះពាល់ក្នុងកម្រិតខុសៗគ្នាទៅលើប្រទេសដែលមានសេដ្ឋកិច្ចទីផ្សារសេរីក្នុងតំបន់។ តំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិកមានការធ្វើសមាហរណកម្មក្នុងតំបន់ និងសកលច្រើន ដែលធ្វើឲ្យតំបន់នេះងាយរងគ្រោះទៅនឹងការប្រែប្រួលលឿនផ្នែកពាណិជ្ជកម្ម។ តំបន់នេះ ពឹងផ្អែកខ្លាំងលើប្រាក់ចំណូលបរទេសពីការនាំចេញ និងប្រភពពីបរទេសផ្សេងៗទៀត (ធនាគារពិភពលោក ខែ តុលា ឆ្នាំ 2018 បច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក)។ លើសពីនេះទៀត ស្ថានភាពហិរញ្ញប្បទានសកលដែលមានការលំបាកជាងការរំពឹងទុក និងបញ្ហាហិរញ្ញប្បទានដែលពាក់ព័ន្ធដែលកើតចេញពី ឧទាហរណ៍ ការប្រែប្រួលនៃក្តីរំពឹងទុកផ្នែកទីផ្សារនៃគោលនយោបាយរូបិយវត្ថុរបស់ប្រទេសជឿនលឿន ឬកំណើនការទប់ស្កាត់ហានិភ័យ អាចធ្វើឲ្យមានលំហូរមូលធនកាន់តែតិចថែមទៀត បង្កើនការប្រែប្រួលនៃទីផ្សារហិរញ្ញវត្ថុ និងដាក់សម្ពាធលើអត្រាប្តូរប្រាក់ក្នុងតំបន់ និងតម្លៃទ្រព្យ។ ការកើនឡើងនៃការចំណាយលើកម្ចីអាចបង្កើនបន្ទុកកាន់តែខ្លាំងលើការបង់ប្រាក់បំណុល ដែលអាចគ្រប់គ្រងបានក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះដោយសារតែអត្រាការប្រាក់ទាបជាសកល និងផលចំណេញលើសហានិភ័យ។ ប្រសិនបើមានហានិភ័យអវិជ្ជមានទាំងអស់ វាអាចធ្វើឲ្យកំណើនសេដ្ឋកិច្ចក្នុងតំបន់ថយចុះលឿនជាង ការរំពឹងទុក។ ភាពងាយរងគ្រោះក្នុងស្រុក ដែលរួមមាន កំណើនបំណុលក្នុងស្រុក និងតម្រូវការហិរញ្ញប្បទានខាងក្រៅក្នុងបណ្តាប្រទេសមួយចំនួន នឹងបង្កើនការប៉ះពាល់នៃការប្រែប្រួលខាងក្រៅ និងប៉ះពាល់ដល់កំណើន ជាពិសេសនៅពេលមិនសូវមានគោលនយោបាយទប់ស្កាត់។



ស្ថានភាពនេះមានកម្រិតខ្ពស់រយៈពេលពីរឆ្នាំកន្លះកន្លងមក។ គួរឲ្យកត់សម្គាល់ថា ការនាំចេញទៅកាន់ទីផ្សារអឺរ៉ុប (មិនគិតចក្រភពអង់គ្លេស) ដែលមានចំណែកទីផ្សារ 34.0 ភាគរយ (រូប 3) និងការនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក ដែលមានចំណែកទីផ្សារ 26.0 ភាគរយ បានកើនឡើងយ៉ាងលឿន រហូតដល់ 15.5ភាគរយ និង 26.3ភាគរយ សម្រាប់ទីផ្សារទាំងពីរនេះ។ ខណៈដែលទីផ្សារទាំងពីរនេះដំណើរការល្អប្រសើរ ទីផ្សារនាំចេញផ្សេងៗទៀតរបស់កម្ពុជា គឺ ចក្រភពអង់គ្លេស ជប៉ុន និងទីផ្សារផ្សេងៗទៀត មានកំណើននាំចេញទាប។ ស្របទៅនឹងកំណើននៃការនាំចេញវាយនភណ្ឌ និងសម្លៀកបំពាក់ ការនាំចេញក្រណាត់ដែលត្រូវបានប្រើប្រាស់ភាគច្រើនជាវត្ថុធាតុដើមសម្រាប់ការ ផលិតសម្លៀកបំពាក់ បានកើនឡើងយ៉ាងខ្លាំងរហូតដល់ 37.1 ភាគរយនៅក្នុងឆមាសទីមួយក្នុងឆ្នាំ 2018 ដែលជាកំណើនខ្ពស់ក្នុងរយៈពេលបីឆ្នាំកន្លងមក។

**ទិន្នន័យផ្លូវការបង្ហាញថា កំណើនការវិនិយោគលើឧស្សាហកម្មវាយនភណ្ឌ សម្លៀកបំពាក់ កាបូប និងស្បែកជើង បានកើនឡើងដោយមានការបើករោងចក្រថ្មីៗជាច្រើននៅក្នុងឆមាសទីមួយក្នុងឆ្នាំ 2018[២]។** ផ្ទុយទៅនឹងការថយចុះចំនួនរោងចក្រសរុបចំនួន 48 ដែលបានបិទទ្វារនៅឆ្នាំ 2017 រោងចក្រថ្មីចំនួន 44 បានចាប់ផ្តើមដំណើរការ (រោងចក្រ 31 ស្ថិតក្នុងឧស្សាហកម្មវាយនភណ្ឌ និងសម្លៀកបំពាក់) នៅឆមាសទីមួយក្នុងឆ្នាំ 2018 ដោយសរុបមានរោងចក្រចំនួន 1,075។ ឧស្សាហកម្មកម្មន្តសាលផ្សេងៗទៀត ដូចជា គីមី កៅស៊ូ ផ្លាស្ទិក គ្រឿងអគ្គិសនី និងគ្រឿងបន្លាស់យានយន្ត ក៏ទទួលបានការវិនិយោគបន្ថែមផងដែរ ដោយមានកំណើន 17 រោងចក្រ ចំណែករោងចក្រមួយចំនួនផ្សេងទៀតបានពង្រីកប្រតិបត្តិការរបស់ខ្លួននៅឆមាសទីមួយក្នុងឆ្នាំ 2018។ របាយការណ៍បង្ហាញថា ការងារថ្មីៗសរុបចំនួន 33 000 ត្រូវបានបង្កើតឡើង ធ្វើឲ្យកម្លាំងពលកម្មសរុបមានចំនួន 1.015 លាននាក់ ឬស្មើនឹងអត្រាកំណើន 3.4 ភាគរយ។

**រូប 3 ៖ ការនាំចេញវាយនភណ្ឌ សម្លៀកបំពាក់ និងស្បែកជើងតាមគោលដៅនាំចេញសំខាន់ៗ** (ចំណែកភាគរយ)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

*សម្គាល់* ៖ ទីផ្សារសហភាពអឺរ៉ុបនៅឆ្នាំ 2014 រួមទាំងចក្រភពអង់គ្លេស។

## មានកំណើនលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស

**លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស និងវិនិយោគិនបរទេសដែលមកដល់ប្រទេសកម្ពុជា កំពុងកើនឡើង។** វិនិយោគិនអន្តរជាតិដែលបានចូលមកក្នុងប្រទេសកម្ពុជាដើម្បីធ្វើពាណិជ្ជកម្ម បានកើនឡើងជិត 9 ភាគរយនៅឆ្នាំ 2018 ធៀបនឹងកំណើន 4.4 ភាគរយនៅឆ្នាំ 2013។ បរិមាណការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត (ទ្រព្យសកម្មថេរ) បានកើនឡើងយ៉ាងលឿនរហូតដល់ 38.4 ភាគរយ ឬស្មើនឹង 2.4 ពាន់លានដុល្លារនៅឆមាសទីមួយក្នុងឆ្នាំ 2018 (រូប 4)[៣]។ បច្ចុប្បន្ន ប្រភពលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសភាគច្រើនមកពីប្រទេសចិន។ គិតជាចំណែកនៃតម្លៃគម្រោងការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត ការវិនិយោគផ្ទាល់ពីបរទេសរបស់ប្រទេសចិននៅឆ្នាំ ២០១៧ មានចំនួន 60 ភាគរយនៃគម្រោងសរុបដែលទទួលបានហិរញ្ញប្បទានពីការវិនិយោគផ្ទាល់ពីបរទេស (មិនរាប់បញ្ចូលការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យហិរញ្ញវត្ថុទេ)។ ក្នុងឆ្នាំ 2018 ចំណែកនេះបានកើនឡើងបន្ថែមទៀត រហូតដល់ 90 ភាគរយនៅក្នុងរយៈពេល ៦ ខែដំបូង។

## លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសនៅពេលបច្ចុប្បន្នកើនឡើងនៅក្នុងឧស្សាហកម្មកម្មន្តសាល ជាពិសេសឧស្សាហកម្មកាត់ដេរ

**ខុសពីរយៈពេលប៉ុន្មានឆ្នាំមុនដែលមានចំណែកនៃការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យកាត់ដេរថយចុះ លំហូរចូលនៃការវិនិយោគបច្ចុប្បន្ននេះ បានកើនឡើងក្នុងឧស្សាហកម្មកម្មន្តសាលជាពិសេសឧស្សាហកម្មកាត់ដេរ និងការកែច្នៃផលិតផល**

**រូប 4 ៖ កំណើនការវិនិយោគផ្ទាល់ពីបរទេស**




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

*សម្គាល់* ៖ RHS=ខាងស្តាំដៃ

---

២ ទិន្នន័យរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

៣ ទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**កសិកម្ម។** ក្នុងឆមាសទីមួយក្នុងឆ្នាំ 2018 ឧស្សាហកម្មកម្មន្តសាលទទួលបាន 120 លានដុល្លារ ឬស្មើនឹងកំណើន 90 ភាគរយ (ធៀបនឹងឆ្នាំមុន)។ ប្រហាក់ប្រហែលគ្នាដែរ លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យកសិកម្ម រួមទាំង ការកែច្នៃផលិតផលកសិកម្ម ក៏បានកើនឡើងផងដែរ ដោយកើនដល់ 167 លានដុល្លារនៅក្នុងឆមាសទីមួយក្នុងឆ្នាំ 2018 ឬកំណើន 26.5 ភាគរយ។ យ៉ាងណាក៏ដោយ ការវិនិយោគផ្ទាល់ពីបរទេសនៅតែបន្តភាគច្រើនជាគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត រួមទាំងគម្រោងអភិវឌ្ឍន៍អចលនទ្រព្យសម្រាប់លំនៅដ្ឋាន និងពាណិជ្ជកម្ម ដែលបានជួយឲ្យវិស័យសំណង់បន្តមានសកម្មភាពច្រើន។

**ទីតាំងកំណើនសំណង់សំខាន់ថ្មីៗនាពេលបច្ចុប្បន្នបានរីកទៅដល់តំបន់ទីក្រុងមាត់សមុទ្រ និងទីប្រជុំជនតាមព្រំដែន។** ខេត្តព្រះសីហនុតែមួយគត់បានទទួលទឹកប្រាក់វិនិយោគផ្ទាល់ពីបរទេសដែលបានអនុម័តប្រមាណ 126 លានដុល្លារនៅខែ មិថុនា ឆ្នាំ 2018។ គម្រោងអភិវឌ្ឍន៍សរុបដែលបានអនុម័តសម្រាប់លំនៅដ្ឋាន និងពាណិជ្ជកម្ម មានចំនួន 1,600 គម្រោង មានតម្លៃ 2.1 ពាន់លានដុល្លារ នៅក្នុងអំឡុងឆមាសទីមួយក្នុងឆ្នាំ 2018 ដែលបង្ហាញពីចំណាប់អារម្មណ៍ខ្លាំងនៃការវិនិយោគនៅក្នុងវិស័យនេះ។ យ៉ាងណាក៏ដោយ តម្លៃគិតជាម៉ែត្រការ៉េនៃការវិនិយោគក្នុងវិស័យសំណង់ដែលបានអនុម័ត បានថយចុះ ដែលបង្ហាញពីការងាកទៅគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដែលមានតម្លៃទាបជាងដែលផ្តោតលើចំណែកទីផ្សារដែលមិនសូវថ្លៃ។ ចំណុចនេះស៊ីសង្វាក់គ្នានឹងការពង្រីកគម្រោងលំនៅដ្ឋានដែលមានតម្លៃថោកជាងមុននៅតំបន់ជាយក្រុងភ្នំពេញ និងតំបន់ទីប្រជុំជនផ្សេងៗទៀត។

**គម្រោងអភិវឌ្ឍន៍ថ្មីៗហាក់ដូចជាមួយផ្នែកឆ្លើយតបទៅនឹងការរីកចម្រើននៃឧស្សាហកម្មទេសចរណ៍ ដោយសារតែចំនួនភ្ញៀវទេសចរបានកើនឡើងរហូតដល់ 3 លាននាក់ ឬមានកំណើន 13.6 ភាគរយ (ធៀបនឹងឆ្នាំមុន) នៅពាក់កណ្តាលឆ្នាំ 2018** បើធៀបនឹងអត្រាកំណើន 11.8 ភាគរយនៅចុងឆ្នាំ 2017 (រូប 5)។ ការពង្រីកសកម្មភាពសាងសង់នៅតំបន់មាត់សមុទ្រ ជាពិសេសខេត្តព្រះសីហនុ អាចជាការឆ្លើយតបទៅនឹងការកើនឡើងនៃតម្រូវការវិស័យទេសចរណ៍នៅទីនោះ។ ខណៈដែលតំបន់ឆ្នេរមានប្រជាប្រិយភាពកាន់តែខ្លាំង ចំនួនភ្ញៀវទេសចរមានចំនួន 13.6 នៃចំនួនភ្ញៀវទេសចរសរុបដែលមកកម្ពុជានៅឆ្នាំ 2018 (ធៀបនឹងអត្រាត្រឹមតែ 5.5 ភាគរយនៅឆ្នាំ 2010 នោះ)។

**ដូច្នេះ ការថយចុះល្បឿននៃការវិនិយោគផ្ទាល់ពីបរទេសពីប្រទេសចិន ដោយសារការប្រែប្រួលទំនុកចិត្តរបស់វិនិយោគិនចិន គឺជាហានិភ័យមួយ។** កត្តានេះអាចមានផលអវិជ្ជមានលើការវិនិយោគ និងកំណើន។ បញ្ហាប្រឈមក្នុងការធ្វើពាណិជ្ជកម្មនៅតែបន្តមាន ដោយកម្ពុជាបច្ចុប្បន្នឈរនៅចំណាត់ថ្នាក់ទី 138 ក្នុងចំណោម 190 ប្រទេស នៅក្នុងចំណាត់ថ្នាក់នៃរបាយការណ៍ស្តីពីការធ្វើធុរកិច្ចនៅឆ្នាំ 2019 ដែលថយចំណាត់ថ្នាក់ពី135 នៅឆ្នាំ 2018 និង 131 នៅឆ្នាំ 2017។ ចំណាត់ថ្នាក់របស់កម្ពុជាល្អជាងឡាវ ដែលឈរនៅលំដាប់ទី 154 ប៉ុន្តែ មានគម្លាតឆ្ងាយពីប្រទេសជាច្រើនផ្សេងទៀតក្នុងតំបន់ ដូចជា ឥណ្ឌូនេស៊ី ដែលនៅទី 73 វៀតណាម នៅទី 69 និងថៃ នៅទី 27[៤]។ នៅក្នុងការវាយតម្លៃថ្មីមួយស្តីពីបរិយាកាសវិនិយោគ (សូមមើលប្រអប់ 2) បើទោះជាមានការទទួលស្គាល់ថា កម្ពុជាមានវឌ្ឍនភាពសំខាន់ៗ ប៉ុន្តែការវាយតម្លៃនេះសន្និដ្ឋានថា បរិយាកាសវិនិយោគបច្ចុប្បន្នបានរាំងស្ទះដល់ការបង្កើនផលិតភាព ពិពិធកម្ម និងការអភិវឌ្ឍវិស័យឯកជនក្នុងស្រុកដ៏រស់រវើក។

**ឧស្សាហកម្មទេសចរណ៍កំពុងរីកចម្រើន ខណៈដែលចំនួនភ្ញៀវទេសចរចូលមកកម្ពុជាកើនឡើងដល់ 3 លាននាក់ ឬស្មើនឹងអត្រាកំណើន 13.6 ភាគរយ (ក្នុងមួយឆ្នាំ) នៅពាក់កណ្តាលឆ្នាំ 2018**

**រូប 5 ៖ ការមកដល់នៃភ្ញៀវទេសចរក្នុងប្រទេសកម្ពុជា ថៃ និងវៀតណាម** (ធៀបនឹងឆ្នាំមុន, ការប្រែប្រួលភាគរយ)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា។ ក្រសួងទេសចរណ៍ និងកីឡាប្រទេសថៃ និងក្រសួងវប្បធម៌ កីឡា និងទេសចរណ៍ប្រទេសវៀតណាម

**រូប 6 ៖ ការមកដល់នៃភ្ញៀវទេសចរតាមផ្លូវអាកាសនៅប្រទេសកម្ពុជា ថៃ និងវៀតណាម** (ភាគរយនៃចំនួនភ្ញៀវទេសចរសរុប)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា។ ក្រសួងទេសចរណ៍ និងកីឡាប្រទេសថៃ និងក្រសួងវប្បធម៌ កីឡា និងទេសចរណ៍ប្រទេសវៀតណាម

៤ http://www.doingbusiness.org/content/dam/doingBusiness/country/c/cambodia/KHM.pdf.

**កិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរកម្ពុជាក្នុងការទាក់ទាញភ្ញៀវទេសចរចិន ទទួលបានផល។** ភ្ញៀវទេសចរចិនឈរនៅលំដាប់ទីមួយ (លំដាប់បន្ទាប់ៗគឺភ្ញៀវទេសចរមកពីវៀតណាម ឡាវ និងសាធារណរដ្ឋកូរ៉េ) ហើយចំនួនភ្ញៀវចិនមានកំណើនខ្ពស់ប្រមាណ 80 ភាគរយ បើធៀបនឹងឆ្នាំមុន និងស្មើនឹង 30 ភាគរយនៃចំនួនភ្ញៀវទេសចរសរុប (ខ្ពស់ជាងនៅប្រទេសថៃដែលភ្ញៀវទេសចរចិនមាន 27 ភាគរយនៃចំនួនភ្ញៀវទេសចរសរុប) ។ ការធ្វើដំណើរតាមផ្លូវអាកាសមានចំនួនជិត 70 ភាគរយនៃចំនួនភ្ញៀវទេសចរសរុប ដែលកើនឡើងពីអត្រាប្រមាណតែ 50 ភាគរយកាលពីប៉ុន្មានឆ្នាំមុននេះ (រូប 6)។ បើទោះជាព្រលានយន្តហោះអន្តរជាតិខេត្តសៀម រាបនៅតែបន្តទទួលបានចំណែកខ្ពស់ជាងគេ ដោយទទួលបាន 51 ភាគរយនៃការធ្វើដំណើរសរុបតាមផ្លូវអាកាស ការធ្វើដំណើរតាមព្រលានយន្តហោះអន្តរជាតិភ្នំពេញក៏កើនឡើងខ្លាំងដែរ ដោយកើនដល់ 40 ភាគរយធៀបនឹងឆ្នាំមុន គិតត្រឹមពាក់កណ្តាលឆ្នាំ 2018 និងមានចំនួន 45 ភាគរយនៃការធ្វើដំណើរតាមផ្លូវអាកាស។

### យ៉ាងណាក៏ដោយ កម្ពុជានៅលំដាប់ក្រោមឆ្ងាយពីប្រទេសថៃ និងវៀតណាម នៅក្នុងការទាក់ទាញភ្ញៀវទេសចរបរទេស

**នៅឆ្នាំ 2017 កម្ពុជាទាក់ទាញភ្ញៀវទេសចរបរទេសតែ 5.6 លាននាក់ប៉ុណ្ណោះ ខណៈដែលប្រទេសថៃទាក់ទាញភ្ញៀវទេសចរបាន 35.4 លាននាក់ ហើយវៀតណាមបាន 12.9 លាននាក់។** ចំពោះចំនួនសរុបនៃទីផ្សារទេសចរណ៍ក្នុងប្រទេសជិតខាងទាំងពីរនេះ កម្ពុជាទទួលបានចំណែកតូចមួយប៉ុណ្ណោះ (ចំណែកនេះថយចុះទៀតផង)។ ជាចំណែក កម្ពុជាទទួលបានត្រឹមតែ 10 ភាគរយប៉ុណ្ណោះនៅឆ្នាំ 2017 នៃចំនួនភ្ញៀវទេសចរសរុបនៃប្រទេសទាំងពីរនេះ ចុះពីចំនួន 12 ភាគរយនៅឆ្នាំ 2014។ ចំនួននេះឆ្លុះបញ្ចាំងពី ការមិនបានប្រើប្រាស់សក្តានុពលយ៉ាងច្រើន ដោយសារតែកម្ពុជាមិនទាន់សម្រេចបានជោគជ័យក្នុងការទាក់ទាញភ្ញៀវទេសចរដែលមកប្រទេសជិតខាងនោះ ឲ្យចូលមកកម្ពុជានៅឡើយទេ។

**ភ្ញៀវទេសចរបរទេសមកកាន់កម្ពុជាជាង 80 ភាគរយជាភ្ញៀវទេសចរដែលមកលើកទីមួយ។** ដោយសារតែមិនសូវមានទីកន្លែងទេសចរណ៍ច្រើន និងផលិតផលសំបូរបែប ភ្ញៀវទេសចរបរទេសដែលមកកាន់កម្ពុជា មានតែ 16.5 ភាគរយប៉ុណ្ណោះ ត្រឡប់មកលេងកម្ពុជាម្តងទៀត ប្រៀបធៀបជាមួយប្រទេសថៃ អត្រានេះមានចំនួនជាង 50 ភាគរយនោះ។ ការសិក្សាមួយបង្ហាញថា ការត្រឡប់មកទៀតអាចដោយសារកត្តាមួយចំនួន ដូចជា ការពេញចិត្តនឹងកន្លែងស្នាក់នៅ ទីផ្សារ ភោជនីយដ្ឋាន និងអាហារ និងឥរិយាបថរបស់ប្រជាជនមូលដ្ឋាន ដែលបានផ្តល់ភាពសុខស្រួល និងការកំសាន្ត[៥]។ មេរៀនពីប្រទេសវៀតណាមអាចយកមកអនុវត្តក្នុងប្រទេសកម្ពុជាបាន។ វៀតណាមធ្វើបានយ៉ាងល្អ ព្រោះថាចាប់តាំងពីឆ្នាំ 2016 មក ចំនួនភ្ញៀវទេសចរបានកើនឡើងជិត 30 ភាគរយ ធៀបនឹងឆ្នាំមុន។ កត្តាសំខាន់ៗ ដូចជា កំណែទម្រង់ទូលំទូលាយ រួមទាំង ការអនុវត្តច្បាប់ស្តីពីទេសចរណ៍ គោលនយោបាយអនុគ្រោះដែលជំរុញឲ្យមានការវិនិយោគលើវិស័យទេសចរណ៍ ការកំណត់អាទិភាពលើមូលធនសម្រាប់ការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យទេសចរណ៍ និងការពង្រីកការផ្សព្វផ្សាយទេសចរណ៍ គឺជាវិធានការគោលនយោបាយសំខាន់ដែលជួយជំរុញវិស័យទេសចរណ៍វៀតណាមទៅមុខ។

### ភ្ញៀវទេសចរចូលមកប្រទេសវៀតណាមមានតែ 5 ភាគរយ និងភ្ញៀវចូលមកប្រទេសថៃមានតែ 13.5 ភាគរយប៉ុណ្ណោះដែលបន្តដំណើរទេសចរណ៍មកកាន់ប្រទេសកម្ពុជា[៦]

**ចំពោះបញ្ហានេះ ជាការសំខាន់ត្រូវមានគោលនយោបាយចូលទៅទីផ្សារទេសចរណ៍ដែលកំពុងកើនឡើងនៅកម្ពុជា។** គោលនយោបាយនេះអាចមានការពិនិត្យមើលតម្រូវការផ្សេងៗក្រៅពីអ្វីដែលប្រទេសថៃ និងវៀតណាមកំពុងផ្តល់ឲ្យ។ ទីផ្សារជាសក្តានុពល អាចមានទេសចរណ៍ធម្មជាតិ ជាពិសេសឧទ្យានទស្សនាសត្វព្រៃ និងដើរកំសាន្តក្នុងព្រៃ ព្រោះកម្ពុជាមានឧទ្យានជាតិ និងតំបន់អភិរក្សជាច្រើនដែលសំបូរជីវៈចម្រុះ។ បន្ទាប់មក កម្ពុជាអាចបង្កើតយុទ្ធសាស្ត្រដើម្បីឆ្លើយតបទៅនឹងតម្រូវការទាំងនោះ និងភ្ជាប់ទំនាក់ទំនងទៅតំបន់ទាក់ទាញភ្ញៀវទេសចរសំខាន់ៗក្នុងប្រទេសថៃ និងវៀតណាម[៧]។

**លក្ខខណ្ឌអាកាសធាតុល្អ បានរួមចំណែកដល់កំណើនផលិតផលកសិកម្មនៅឆ្នាំនេះ។** ក្នុងឆ្នាំ 2017 ផលស្រូវបានកើនដល់ 10.4 លានតោន កើន 4.4 ភាគរយធៀបនឹងឆ្នាំមុន (រូប 7)។ ការរួមចំណែករបស់ដីដាំដុះ (នៅពេលដែលផ្ទៃដីដាំដុះកើនឡើង) គឺ 230.000 តោន ហើយការរួមចំណែករបស់ទិន្នផលដល់កំណើនផលកសិកម្មនេះ គឺ 180.000 តោន។ ខណៈពេលដែលមានកំណើនអតិរេក និងការនាំចេញអង្ករ អង្ករផ្កាម្លិះដែលជាអង្ករក្រអូបដ៏ល្បីល្បាញរបស់កម្ពុជា ទទួលបានការពេញនិយមកាន់តែខ្លាំង។ អង្ករផ្កាម្លិះកម្ពុជាឈ្នះពានរង្វាន់អង្ករល្អផ្តាច់គេក្នុងពិភពលោកជាថ្មីម្តងទៀតនៅឆ្នាំ 2018 នៅក្នុងការប្រកួតអង្ករល្អផ្តាច់គេក្នុងពិភពលោក ដែលរៀបចំឡើងរាល់ឆ្នាំដោយ The Rice Trader[៨]។ តាំងពីឆ្នាំ 2009 មក អង្ករផ្កាម្លិះរបស់

---

៥ “កត្តាដែលធ្វើឲ្យភ្ញៀវទេសចរអន្តរជាតិត្រឡប់មកទីក្រុងបាងកក ប្រទេសថៃជាថ្មីទៀត” រៀបរៀងដោយ Tun Thimsak និង Athapol Ruangkanjanase។ http://www.joebm.com/vol4/394-E00008.pdf.

៦ របាយការណ៍ប្រចាំឆ្នាំ 2017 របស់ក្រសួងទេសចរណ៍បង្ហាញថា ភ្ញៀវទេសចរចំនួន 34.7 ភាគរយ និង 31.2 ភាគរយ ដែលមកប្រទេសថៃ និងវៀតណាម បានមកធ្វើទេសចរណ៍នៅកម្ពុជា។

៧ សូមមើល ផ្នែកអត្ថបទជម្រើសដែលមានចំណងជើងថា “ការទាក់ទាញរបស់ប្រទេសកម្ពុជា ៖ អតិបរមាកម្មសក្តានុពលនៃវិស័យទេសចរណ៍” ខែ តុលា ឆ្នាំ 2017 “បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា” សម្រាប់ការវិភាគស៊ីជម្រៅក្នុងវិស័យទេសចរណ៍។

៨ https://thericetrader.com/conferences/2018-WRC-Hanoi/worlds-bestrice/.

កម្ពុជាមានភាពប្រកួតប្រជែងជាសកល ជាពិសេសជាមួយនឹងអង្ករផ្កាម្លិះប្រទេសថៃ ក្នុងការដណ្តើមពានរង្វាន់ប្រចាំឆ្នាំជាអង្ករល្អផ្តាច់គេក្នុងពិភពលោក។ កន្លងមក កម្ពុជាបានឈ្នះពានរង្វាន់ 4 ដង (2012 2013 2014 2018) ចំណែកអង្ករថៃឈ្នះពានរង្វាន់ 5 ដង អង្ករអាមេរិក និងអង្ករមីយ៉ាន់ម៉ា ទទួលបានពានរង្វាន់មួយម្នាក់។

**ការងើបឡើងវិញបន្តិចម្តងៗនៃតម្លៃផលិតផលកសិកម្ម បានជួយដល់កំណើនផលិតកម្មកសិកម្ម។** យ៉ាងណាក៏ដោយ កំណើនវិស័យកសិកម្មនៅអំឡុងឆ្នាំ 2016 និង 2017 នៅតែទាបខ្លាំងជាងកំណើននៅអំឡុងពេលមុនឆ្នាំ 2013 (រូប 8) ដោយសារការពង្រីកដីដាំដុះ ដែលជាចលករសំខាន់ក្នុងការជំរុញដំណើរការផលិតកម្មកសិកម្មដែលរឹងមាំ អាចមានកម្រិតខ្ពស់បំផុតរួចទៅហើយ។ ដើម្បីបង្កើនទិន្នផលកសិកម្ម ត្រូវមានការកែលម្អដី និងផលិតភាពកម្លាំងពលកម្ម ខណៈដែលការធ្វើពិពិធកម្ម ប្រពលវប្បកម្ម និងគ្រាប់ពូជល្អ នឹងជួយបង្កើនផលិតភាពដី។ ដោយសារកម្ពុជាស្ថិតនៅក្បែរប្រទេសជិតខាង (ថៃ និងវៀតណាម) ដែលផលិតផលិតផលច្រើនខ្លាំង ជាយុទ្ធសាស្ត្រកម្ពុជាត្រូវផ្តោតលើការសម្រេចបានគុណភាពដោយឡែក (អង្ករម្រេច) ចំណុចខ្លាំងផ្នែកនិរន្តរភាព ("បរិស្ថាន") និងការបង្កើនសុវត្ថិភាពអាហារ ("ស្អាត") និងកែលម្អការកែច្នៃផលិតផលកសិកម្ម (ស្វាយចន្ទី ដំណាំម្សៅ)។

## ពិពិធកម្មកសិកម្ម រួមទាំង ការធ្វើឲ្យមានគុណភាពដោយឡែក នឹងជួយឲ្យវិស័យកសិកម្មឆ្លើយតបនឹងការប្រែប្រួលតម្រូវការទាំងក្នុង និងក្រៅប្រទេស

**នៅក្នុងស្រុក ការកើនប្រាក់ចំណូល និងការកើនតំបន់ទីប្រជុំជន និងការរីកចម្រើនលឿននៃវិស័យទេសចរណ៍ កំពុងផ្លាស់ប្តូរការហូបចុកក្នុងគ្រួសារ ជាពិសេសការបរិភោគផលិតផលពីសត្វ។** ផលិតផលនេះក៏ល្អសម្រាប់ការនាំចេញផងដែរ ព្រោះថាកំណើនប្រជាជនដែលមានជីវភាពកម្រិតមធ្យមនៅអាស៊ី ជាពិសេសនៅប្រទេសចិន។ យ៉ាងណាក៏ដោយ ក្នុងរយៈពេលមួយទសវត្សរ៍កន្លងទៅនេះ ការធ្វើពិពិធកម្មទៅការផលិតផលិតផលពីសត្វ និង

**រូប 7 ៖ ការរួមចំណែកដល់កំណើនផលិតផលស្រូវវស្សាប្រចាំឆ្នាំ** (លានតោន)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

**រូប 8 ៖ កំណើន ផសស កសិកម្ម ងើបឡើងវិញ ប៉ុន្តែនៅស្ថិតក្រោមកម្រិតមុនឆ្នាំ 2003**




*ប្រភព* ៖ អាជ្ញាធរកម្ពុជា និងក្រុមធនាគារពិភពលោក

**រូប 9 ៖ តម្លៃត្រី និងអាហារសមុទ្រកើនថ្លៃ ប៉ុន្តែការធ្វើពិពិធកម្មទៅផលិតកម្មជលផលមិនទាន់សម្រេចបាននៅឡើយ**




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

*សម្គាល់* ៖ RHS=ខាងស្តាំ

**រូប 10 ៖ គោលនយោបាយស្រូវអង្ករឆ្នាំ 2010 បានជួយបង្កើនចំណែកនៃការនាំចេញអង្ករ និងឥណទានក្នុងស្រុកសម្រាប់វិស័យកសិកម្ម** (ភាគរយ)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

ផលផល នៅមិនទាន់មានភាពជោគជ័យនៅឡើយទេ បើទោះបីជាមានកំណើនតម្រូវការ និងតម្លៃក្តី (រូប 9)។

**ដូច្នេះ យុទ្ធសាស្ត្រជាតិក្នុងការជំរុញពិពិធកម្មកសិកម្មអាចមានតួនាទីយ៉ាងសំខាន់។** ដូចវិស័យស្រូវអង្ករដែរ គោលនយោបាយផលិតកម្មស្រូវ និងជំរុញការនាំចេញអង្ករនៅឆ្នាំ 2010 មានចំណុចជាច្រើនដែលផ្តោតលើការជំរុញការវិនិយោគក្នុងវិស័យឯកជន និងសាធារណៈ និងការបង្កើតបរិស្ថានគ្រប់គ្រងពាណិជ្ជកម្ម និងការនាំចេញ ដែលជួយដល់ការពង្រីកផលិតកម្ម និងការនាំចេញអង្ករ (រូប 10)។

**ការងើបឡើងវិញនៃផលិតកម្មកសិកម្មបានបង្កើនការងារ និងពាណិជ្ជកម្មពាក់ព័ន្ធនឹងកសិកម្ម បើទោះជានៅតែមានការបន្ថយចុះការងារកសិកម្មប្រភេទទីមួយ។** ការងើបឡើងវិញនៃផលិតកម្មកសិកម្មក្នុងឆ្នាំ 2016 និង 2017 រួមជាមួយនឹងភាពប្រសើរឡើងនៃទស្សនវិស័យសេដ្ឋកិច្ចនៅទីជនបទ បានចូលរួមចំណែកធ្វើឲ្យពលករមួយចំនួនវិលត្រឡប់មកវិញ ជាពិសេសពលករនៅប្រទេសថៃ ដែលបង្ហាញតាមរយៈការថយចុះនៃប្រាក់បញ្ញើមកផ្ទះ (រូប 11)។ ក្នុងស្ថានភាពនេះ នឹងមានការកាត់បន្ថយភាពក្រីក្របន្ថែមទៀតនៅតំបន់ជនបទ។

**ស្របទៅនឹងការថយចុះនៃភាពក្រីក្រ លទ្ធភាពទទួលបានលំនៅដ្ឋាន និងទីជម្រក ក៏មានភាពប្រសើរដែរ។** នៅឆ្នាំ 2016 គ្រួសារនៅកម្ពុជាជិត 95 ភាគរយ មានផ្ទះសម្បែង ធៀបនឹងអត្រា 93 ភាគរយក្នុងឆ្នាំ 2010[៩]។ នៅទីជនបទ គ្រួសារ 96 ភាគរយ មានផ្ទះសម្បែង (ជាមធ្យម ទំហំ 50 ម៉ែត្រការ៉េ/គ្រួសារ) បើទោះជាគុណភាពលំនៅដ្ឋានរបស់ពួកគេមានកម្រិតទាបជាងលំនៅដ្ឋាននៅទីប្រជុំជនក្តី (82.7 ភាគរយ មានកម្រាលទន់ និងជាគ្រឿងបណ្តោះអាសន្ន ហើយ 65 ភាគរយ មានបន្ទប់តែមួយ)។

## លទ្ធភាពទទួលបានទឹកស្អាតសម្រាប់គ្រួសារជនបទ នៅតែជាបញ្ហាប្រឈម

**47 ភាគរយនៃគ្រួសារជនបទ (ចុះពី 64 ភាគរយនៅឆ្នាំ 2010) នៅតែប្រើប្រាស់ប្រភពទឹកមិនស្អាត** (ដូចជាអណ្តូងទឹកគ្មានការការពារ ស្រះទឹក ទន្លេ បឹងបួរ និងការយកទឹកភ្លៀងមិនបានល្អ)។ លទ្ធភាពក្នុងការទទួលបានបរិក្ខារអនាម័យល្អ បានកើនឡើង ប៉ុន្តែ នៅតែមានកម្រិតទាប ប្រមាណ 67 ភាគរយនៃគ្រួសារជនបទ កើនពី 29 ភាគរយនៅឆ្នាំ 2010[១០]។

**ការកែប្រែរចនាសម្ព័ន្ធនៅតែបន្តមាន ហើយទីផ្សារការងារកាន់តែចង្អៀត។** វិស័យកសិកម្មផ្តល់ការងារចំនួន 344,000 នៅឆ្នាំ 2016 (រូប 12) បើទោះជាវិស័យនេះមានដំណើរការល្អជាងមុនក្តី។ យ៉ាងណាក៏ដោយ វិស័យសេវាកម្មផ្តល់ការងារជិត 0.5 លាន ដែលជួយប៉ះប៉ូវការបាត់បង់ការងារក្នុងវិស័យកសិកម្ម ដែលធ្វើឲ្យការបង្កើតការងារសរុបស្មើនឹង 250,000 (ខ្ពស់ជាងការងារ 116,000 នៅឆ្នាំ 2015)។ ការបង្កើតការងារសរុបនេះ អាចជួយស្រូបយកប្រជាជនគ្រប់អាយុធ្វើការដែលកំពុងកើនឡើងនៅកម្ពុជា (អាយុ 15-64 ឆ្នាំ)។ ជារៀងរាល់ឆ្នាំ មានកម្លាំងពលកម្មថ្មីចំនួន 164,000 នាក់។

**ការកើនឡើងនៃលំហូរការវិនិយោគផ្ទាល់ពីបរទេសនឹងនៅតែបន្តត្រូវការកម្លាំងពលកម្មច្រើនថែមទៀត ជាពិសេសកម្លាំងពលកម្មជំនាញ។** ក្នុងស្ថានភាពនេះ កម្លាំងពលកម្មជំនាញក្នុងស្រុកហាក់ដូចជាមិនទាន់គ្រប់គ្រាន់ ដូច្នេះ ចំពោះឧស្សាហកម្មមួយចំនួនរួមទាំង សំណង់ ការជួលកម្លាំងពលកម្មជំនាញពីបរទេសគឺជាការចាំបាច់។ ឧបសគ្គដែលបង្កឡើងដោយកម្លាំងពលកម្មកម្ពុជាដែលមានកម្រិតអប់រំទាប ត្រូវបានកំណត់ថាជាឧបសគ្គធ្ងន់ធ្ងរទីពីរចំពោះដំណើរការសហគ្រាសកម្មន្តសាល (ការអង្កេតសហគ្រាសឆ្នាំ 2016 របស់ក្រុមធនាគារពិភពលោក)។

**ជំរុញដោយតម្រូវការខាងក្រៅច្រើន ការនាំចេញទំនិញបានកើនឡើងយ៉ាងលឿននៅឆ្នាំនេះ។** ក្រៅពីកំណើនការនាំចេញ

**រូប 11 ៖ និន្នាការតម្លៃកៅស៊ូ និងអង្ករ និងប្រាក់បញ្ញើ**




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

*សម្គាល់* ៖ RHS=ខាងស្តាំ

**រូប 12 ៖ ការរួមចំណែកដល់ការបង្កើតការងារ** (គិតជាពាន់)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

៩ ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជាឆ្នាំ 2010 និង 2016 វិទ្យាស្ថានជាតិស្ថិតិ។

១០ ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជាឆ្នាំ 2010 និង 2016 វិទ្យាស្ថានជាតិស្ថិតិ។

ផលិតផលវាយនភណ្ឌ សម្លៀកបំពាក់ និងស្បែកជើង ដែលបានលើកឡើងខាងលើ ភាពជោគជ័យនៃការធ្វើពិពិធកម្មដំបូងបានជំរុញឲ្យមានការនាំចេញផលិតផលកម្មន្តសាលថ្មីៗ។ ដោយទទួលបានការអនុគ្រោះពន្ធដែលមានឈ្មោះថា "អ្វីៗគ្រប់យ៉ាងលើកលែងតែអាវុធ (EBA)" របស់សហភាពអឺរ៉ុប កម្ពុជាបានក្លាយជាអ្នកផ្គត់ផ្គង់កង់ច្រើនជាងគេ ទៅទីផ្សារសហភាពអឺរ៉ុប។ កម្ពុជាបាននាំមុខប្រទេសតៃវ៉ាន់ដែលធ្លាប់ជាប្រទេសនាំចេញកង់ច្រើនជាងគេទៅកាន់សហភាពអឺរ៉ុបអស់រយៈពេល 20 ឆ្នាំមកហើយ[៩៩]។ ក្នុងឆ្នាំ 2007 កម្ពុជាបាននាំចេញកង់ធម្មតាជាង 1.4 លានគ្រឿង ឬមានអត្រាកំណើន 9 ភាគរយបើធៀបនឹងឆ្នាំមុនទៅកាន់សហភាពអឺរ៉ុប បន្ទាប់មកមានប្រទេសតៃវ៉ាន់ និងប្រទេសចិន (1.3 លានគ្រឿង) និងហ្វីលីពីន (0.8 លានគ្រឿង)។ តម្លៃនៃការនាំចេញកង់សរុបរបស់កម្ពុជាមានទំហំទឹកប្រាក់ 335 លានដុល្លារនៅឆ្នាំ 2017។ នៅអំឡុងឆមាសទីមួយក្នុងឆ្នាំ 2018 ការនាំចេញកង់របស់កម្ពុជាកើនឡើងចំនួន 16.7 ភាគរយ។ ផលិតផលនាំចេញថ្មីផ្សេងទៀត រួមមាន យានយន្ត និងគ្រឿងអគ្គិសនី ដែលមានតម្លៃសរុបប្រមាណ 400 លានដុល្លារ។

### កំណើនតម្រូវការក្នុងស្រុកត្រូវបានបំពេញដោយកំណើននៃការនាំចូល

**ថ្មីៗនេះ កម្ពុជាមានកំណើននៃការនាំចូល ដែលឆ្លុះបញ្ចាំងពីទំនុកចិត្តរបស់អ្នកប្រើប្រាស់។** ការនាំចូលយានយន្ត និងដែក ដែលបង្ហាញពីការប្រើប្រាស់ក្នុងស្រុក និងតម្រូវការផ្នែកសំណង់ បានកើនឡើងយ៉ាងខ្លាំង។ ការនាំចូលយានយន្ត រួមទាំង រថយន្តដឹកអ្នកដំណើរធំៗ និងម៉ូតូ មានការកើនឡើងខ្លាំងរហូតដល់ 81.4 ភាគរយនៅឆមាសទីមួយក្នុងឆ្នាំ 2018 (រូប 13)។ សកម្មភាពសំណង់ដ៏មមាញឹកតម្រូវឲ្យមានការនាំចូលសម្ភារសំណង់ច្រើនជាងមុន ខណៈដែលវិនិយោគិននៅតែបន្តមានទំនុកចិត្តខ្លាំង។ មានការកើនឡើងនៃការនាំចូលសម្ភារសំណង់សំខាន់ៗ រួមទាំងដែក (50.9 ភាគរយ) ស៊ីម៉ង់ (21.1 ភាគរយ) និងបរិក្ខារធ្វើឲ្យត្រជាក់ (86.7 ភាគរយ) (រូប 14)។ ការនាំចូលគ្រឿងឧបភោគបរិភោគ ភេសជ្ជៈ និងឱសថ រួមបញ្ចូលគ្នាមានទំហំទឹកប្រាក់ 700 លានដុល្លារ ដែលកើនឡើងចំនួន 31.1 ភាគរយ ធៀបនឹងឆ្នាំមុនក្នុងឆមាសទីមួយក្នុងឆ្នាំ 2018។

**យ៉ាងណាក៏ដោយ ជំហរខាងក្រៅរបស់កម្ពុជានៅតែមានស្ថិរភាព ព្រោះថាកំណើននៃការនាំចេញបានប៉ះប៉ូវមួយកម្រិតជាមួយតម្រូវការការនាំចូល ហើយឱនភាពគណនីចរន្តដែលទទួលហិរញ្ញប្បទានពេញពីលំហូរវិនិយោគផ្ទាល់ពីបរទេស។** ទោះបីជាធំជាងមុនបន្តិចក្តី ឱនភាពគណនីចរន្តត្រូវបានរំពឹងថានឹងនៅតែមានស្ថិរភាពល្មមនៅឆ្នាំ 2018 ក្នុងកម្រិតប្រមាណ 10.3 ភាគរយនៃ ផសស និងទទួលបានហិរញ្ញប្បទានទាំងស្រុងពីលំហូរវិនិយោគផ្ទាល់ពីបរទេស។ យ៉ាងណាក៏ដោយ ចំណែកមិនសមាមាត្រនៃការវិនិយោគផ្ទាល់ពីបរទេសកាន់តែផ្អែកលើប្រទេសមួយ អាចជាបញ្ហាដែលត្រូវបារម្ភ។ លើសពីនេះទៀត កំណើនតម្រូវការនាំចូលបានបន្ថយល្បឿនកំណើនប្រាក់បម្រុងអន្តរជាតិដុល ដោយកើនត្រឹម 15 ភាគរយធៀបនឹងឆ្នាំមុន នៅខែ មិថុនា ឆ្នាំ 2018 ពីអត្រា 30 ភាគរយនៅខែ ធ្នូ ឆ្នាំ 2017 ហើយនេះគឺជាអត្រាកំណើនលឿនបំផុតក្រោយការបញ្ចប់វិបត្តិហិរញ្ញវត្ថុសកល (សូមអានការពិភាក្សាបន្ថែមស្តីពីផលប៉ះពាល់នៃកំណើនតម្រូវការនាំចូលលើអត្រាប្តូរប្រាក់ ក្នុងផ្នែកស្តីពីវិស័យរូបិយវត្ថុខាងក្រោម)។ ប្រាក់បម្រុងអន្តរជាតិដុលកើនដល់ 9.08 ពាន់លានដុល្លារគិតត្រឹមខែ មិថុនា ឆ្នាំ 2018 ឬស្មើនឹងរយៈពេល 6 ខែនៃការនាំចូលនាពេលអនាគត។

**រូប 13 ៖ កំណើនការនាំចូលយានយន្ត**

(ពីដើមឆ្នាំមកដល់បច្ចុប្បន្ន ការប្រែប្រួលជាភាគរយ)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

**រូប 14 ៖ ការនាំចូលសម្ភារសំណង់ និងដែក**

(ធៀបនឹងឆ្នាំមុន ការប្រែប្រួលជាភាគរយ)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

៩៩ https://www.bike-eu.com/sales-trends/nieuws/2018/06/cambodia-noweus-leading-bicycle-supplier-10134013?vakmedianet-approve-cookies=1&_ga=2.250830918.1923186902.1532411510-374096326.1532411510.

**ប្រអប់ 2**

## ការវាយតម្លៃទៅលើបរិយាកាសវិនិយោគនៅកម្ពុជា ៖ មេរៀនសម្រាប់ភាពប្រកួតប្រជែងនៅថ្ងៃអនាគត[១]

កម្ពុជាមានកំណើនសេដ្ឋកិច្ចរឹងមាំ ក្នុងរយៈពេលជាងពីរទសវត្សរ៍មកហើយ និងបានក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាបនៅឆ្នាំ 2017។ សមិទ្ធផលទាំងនេះធ្វើឲ្យមានការកោតសរសើរ និងបានធ្វើឲ្យប្រជាជនកម្ពុជាជាច្រើនរួចផុតបន្ទាត់នៃភាពក្រីក្រ[២]។ ដើម្បីកំណត់មេរៀនសម្រាប់ថ្ងៃអនាគត យើងពិនិត្យទៅលើរបៀបសម្រេចបានកំណើនខ្ពស់នេះ។

កំណើនសេដ្ឋកិច្ចរបស់កម្ពុជាត្រូវបានជំរុញដោយការវិនិយោគផ្ទាល់ពីបរទេសលើការនាំចេញ និងវិស័យទេសចរណ៍។ ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ កម្ពុជាស្ថិតក្នុងចំណោមប្រទេសដែលបានទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសច្រើនបំផុត បើគិតពីទំហំកម្ពុជានៅក្នុងពិភពលោក[៣]។ វិស័យកាត់ដេររបស់កម្ពុជាមានចំនួន 84 ភាគរយនៃតម្លៃបន្ថែមសរុបនៃការនាំចេញទំនិញកម្មន្តសាល ហើយកំណើនលឿនក្នុងវិស័យទេសចរណ៍នាំចូលប្រាក់ពីបរទេសមកកម្ពុជា។ ជំនួយអភិវឌ្ឍន៍ផ្លូវការបានជួយឲ្យមានវឌ្ឍនភាពនៃសេវាសាធារណៈជាច្រើន ដូចជាហេដ្ឋារចនាសម្ព័ន្ធ សុខាភិបាល និងអប់រំ។ ជារួម កំណើនសេដ្ឋកិច្ចនេះត្រូវបានជំរុញដោយការទាក់ទាញធនធានហិរញ្ញវត្ថុពីបរទេសតាមវិធីផ្សេងៗ ដែលមិនប៉ះពាល់អ្វីឡើយ។

យ៉ាងណាក៏ដោយ ចំណុចសំខាន់ដែលអ្នកតាក់តែងគោលនយោបាយគួរពិចារណានោះគឺថា ធនធានពីបរទេសទាំងនេះត្រូវបានស្រូបមកតាមរយៈសកម្មភាពដែលមានការចំណាយទាប និងតម្លៃទាប ដោយសមិទ្ធផលជាក់ស្តែងក្នុងផ្នែកផលិតភាព និងភាពប្រកួតប្រជែង នៅមានកម្រិតទាបនៅឡើយ[4]។ វិនិយោគិនបរទេសនៅតែបន្តលើកឡើងថា កម្លាំងពលកម្មថោក ការលើកទឹកចិត្តផ្នែកពន្ធ និងការអនុគ្រោះពន្ធនាំចូល និងការអនុគ្រោះពន្ធនៅទីផ្សារនាំចេញ គឺជាមូលហេតុសំខាន់ៗចំពោះការវិនិយោគរបស់ពួកគេនៅកម្ពុជា។ ដោយសារតែមានការរីកចម្រើន ប្រាក់ឈ្នួលកំពុងកើនឡើង ដោយសារតែកម្លាំងពលកម្មមានឱកាសកាន់តែច្រើន។ ជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប កម្ពុជាអាចនឹងលែងទទួលបានការអនុគ្រោះពន្ធ និងការថយចុះនៃហិរញ្ញប្បទានសម្បទាននៅក្នុងរយៈពេលមួយទសវត្សរ៍ខាងមុខ។ ការងើបឡើងនៃប្រទេសមីយ៉ាន់ម៉ា និងប្រទេសដែលមានផលិតកម្មតម្លៃទាបផ្សេងៗទៀត នឹងជាការពិនិត្យទៅលើលទ្ធភាពរបស់កម្ពុជាក្នុងការរក្សា និងបន្តទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសក្នុងកម្រិតខ្ពស់ ដើម្បីរក្សាបានកំណើនសេដ្ឋកិច្ចរឹងមាំ និងការបង្កើតការងារ។ បញ្ហាទាំងនេះគឺជាផលវិបាកនៃវឌ្ឍនភាព មិនមែនជាការអភិវឌ្ឍមិនល្អនោះទេ ប៉ុន្តែផលវិបាកទាំងនេះនឹងប៉ះពាល់ដល់ដំណើរនៃកំណើននាថ្ងៃអនាគត។

ការវាយតម្លៃថ្មីមួយរបស់ក្រុមធនាគារពិភពលោក[៥] ពិនិត្យលើផ្នែកសំខាន់ៗបំផុតនៃបរិយាកាសវិនិយោគ ដែលមានឥទ្ធិពលលើអត្ថប្រយោជន៍ដែលការវិនិយោគផ្ទាល់ពីបរទេស ពាណិជ្ជកម្ម និងការអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យម មានទៅលើកំណើននៅថ្ងៃអនាគត។ បរិយាកាសវិនិយោគអំណោយផលនឹងផ្តល់ឱកាស និងការលើកទឹកចិត្តដល់សហគ្រាសឯកជន (ទាំងបរទេស និងក្នុងស្រុក) ឲ្យវិនិយោគ បង្កើតការងារ និងពង្រីកខ្លួន ដែលជួយពង្រឹងមូលដ្ឋានឧស្សាហកម្មកម្ពុជា និងភាពប្រកួតប្រជែងរបស់ក្រុមហ៊ុនក្នុងទីផ្សារអន្តរជាតិ។ ទន្ទឹមនឹងវឌ្ឍនភាពគួរជាទីកត់សម្គាល់ ការវាយតម្លៃសន្និដ្ឋានថា បរិយាកាសវិនិយោគបច្ចុប្បន្នបានរាំងស្ទះដល់ការបង្កើនផលិតភាព ពិពិធកម្ម និងការអភិវឌ្ឍវិស័យឯកជនក្នុងស្រុកដ៏រស់រវើក ដោយសារហេតុផលខាងក្រោម ៖

ទីមួយ ចំណាយលើការធ្វើអាជីវកម្មនៅកម្ពុជាមិនលើកទឹកចិត្តឲ្យមានការវិនិយោគក្នុងស្រុក និងសហគ្រិនភាពទេ។ ការកើតឡើងនៃ "ផ្នែកកណ្តាលដែលត្រូវបានទុកចោល[៦]" នៃក្រុមហ៊ុនជាច្រើន មានចំនួនច្រើននៅកម្ពុជាជាងនៅក្នុងបណ្តាប្រទេសដែលមានប្រាក់ចំណូលទាប។ តាមពិតទៅ កម្រមានសហគ្រាសខ្នាតតូចដែលបានចុះបញ្ជីជាផ្លូវការណាស់។ អត្រាដង់ស៊ីតេនៃការបង្កើតអាជីវកម្មប្រចាំឆ្នាំ តិចជាង 1 ភាគ 3 នៃមធ្យមភាគនៅប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាបទាប (រូប B2.1)។

**រូប B2.1 ៖ ដង់ស៊ីតេនៃការបង្កើតសហគ្រាសនៅកម្ពុជាធៀបនឹងបណ្តាប្រទេសដែលមានចំណាត់ថ្នាក់ប្រាក់ចំណូលខុសៗគ្នា**




កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសនានា លើពិភពលោកដែលមានការលំបាកបំផុតក្នុងការចុះបញ្ជីអាជីវកម្ម។ នៅឆ្នាំ 2018 របាយការណ៍ស្តីពីការធ្វើធុរកិច្ចបង្ហាញថា ការចាប់ផ្តើមអាជីវកម្មនៅទីក្រុងភ្នំពេញតម្រូវឲ្យមាននីតិវិធីចំនួន ៩ ដែលចំណាយពេលជាមធ្យម 99 ថ្ងៃ និងចំណាយប្រាក់ 51.3 ភាគរយនៃប្រាក់ចំណូលសម្រាប់មនុស្សម្នាក់នៅកម្ពុជា។ កម្រិតដើមទុនអប្បបរមាដែលត្រូវបង់ប្រមាណ 82.5 ភាគរយនៃប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ ក៏ជាជាការចាំបាច់ផងដែរ។ កម្ពុជាឈរនៅលំដាប់ទី 183 ក្នុងចំណោមប្រទេស 190 នៅលើពិភពលោកចំពោះភាពងាយស្រួលក្នុងការបង្កើតអាជីវកម្ម និងស្ថិតនៅក្រោមគេក្នុងចំណោមប្រទេស 25 នៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក។ ហេតុនេះ សហគ្រិនជាច្រើនមិនបានចុះបញ្ជីអាជីវកម្មរបស់ខ្លួន និងគេចវេសមិនបង់ពន្ធ។ ការដំណើរការងារមិនផ្លូវការនេះ ដោយគ្មានការចាត់វិធានការអ្វីនោះ

---

១ រៀបរៀងដោយ Ulla Heher អ្នកឯកទេសផ្នែកវិស័យឯកជន ផ្នែកអនុវត្តស្តីពីម៉ាក្រូសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការវិនិយោគ។

២ យោងតាមការប៉ាន់ស្មានជាផ្លូវការ អត្រាភាពក្រីក្រនៅឆ្នាំ 2014 មានចំនួន 13.5 ភាគរយ ធៀបនឹងអត្រា 47.8 ភាគរយនៅឆ្នាំ 2007។

៣ ជាមធ្យម លំហូរការវិនិយោគផ្ទាល់ពីបរទេស មាន 7.8 ភាគរយនៃ ផសស នៅអំឡុងឆ្នាំ 2000 និង 2016។

៤ សន្ទស្សន៍ស្តីពីភាពប្រកួតប្រជែងជាសកលនៅក្នុងវេទិការសេដ្ឋកិច្ចពិភពលោក បានផ្តល់ចំណាត់ថ្នាក់កម្ពុជានៅលំដាប់ទី 110 ក្នុងចំណោមប្រទេស 125 នៅឆ្នាំ 2006 និងលំដាប់ទី 94 ក្នុងចំណោមប្រទេស 137 នៅឆ្នាំ 2017។ ចំណាត់ថ្នាក់ទាំងនេះទាបជាងប្រទេសជិតខាងទាំងអស់ និងទាបខ្លាំងជាងមធ្យមភាគនៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក។

៥ របាយការណ៍លម្អិតនឹងត្រូវផ្សព្វផ្សាយនៅឆមាសទីមួយក្នុងឆ្នាំ 2019។

៦ កម្ពុជាមានដង់ស៊ីតេនៃក្រុមហ៊ុនដែលស្ថិតក្នុងផ្នែកតូច និងមធ្យម តិចជាងប្រទេសដែលមានកម្រិតប្រហាក់ប្រហែលគ្នា។

ធ្វើឲ្យការចូលរួមផ្នែកពាណិជ្ជកម្ម ឬការភ្ជាប់ទំនាក់ទំនងទៅនឹងក្រុមហ៊ុនដែលជាការវិនិយោគផ្ទាល់ពីបរទេស កាន់តែលំបាក ដែលបង្កផលវិបាកធ្ងន់ធ្ងរលើទស្សនវិស័យអាជីវកម្ម និងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ច។

ទីពីរ ការចំណាយផ្នែកពាណិជ្ជកម្ម ជាផ្នែកសំខាន់នៃរចនាសម្ព័ន្ធនាំចេញ និងប្រតិបត្តិការរបស់ក្រុមហ៊ុននាំចេញ។ សម្រាប់កម្ពុជាដែលជាប្រទេសតូចមួយ ទីផ្សារសកលគឺជាប្រភពធានាជួយឲ្យមានកំណើន និងការអភិវឌ្ឍដ៏សំខាន់។ ចំណាយផ្នែកពាណិជ្ជកម្មគឺជាចំណែកដ៏សំខាន់នកៃារចំណាយលីប្រតិបត្តិការសរុបសម្រាប់ក្រុមហ៊ុននាំចេញ និងក្រុមហ៊ុននាំចូលនៅកម្ពុជា ជាពិសេសសម្រាប់ការវិនិយោគផ្ទាល់ពីបរទេស ព្រោះក្រុមហ៊ុនភាគច្រើនផ្តោតលើការនាំចេញ។ ការដឹកជញ្ជូន និងឡូជីស្ទីក ធៀបទៅនឹងតម្លៃបន្ថែមនៃការនាំចេញសរុបពីកម្ពុជា មានចំនួន 14 ភាគរយ[៧]។ អត្រានេះ លើសពីរដងបើធៀបនឹងការចំណាយលើផ្នែកនេះនៅប្រទេសថៃ និង 3.5 ដងនៅប្រទេសម៉ាឡេស៊ី ឬវៀតណាម[៨]។ ការកាត់បន្ថយការចំណាយផ្នែកពាណិជ្ជកម្មនឹងជួយបង្កើនភាពប្រកួតប្រជែងនៃការចំណាយរបស់ក្រុមហ៊ុននាំចេញបច្ចុប្បន្ន ក៏ដូចជាជួយទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសកាន់តែច្រើនមកកាន់ប្រទេសកម្ពុជា។ ចំណុចនេះជាកត្តាសំខាន់ណាស់ ព្រោះក្រុមហ៊ុននាំចេញ និងក្រុមហ៊ុនបរទេសនៅកម្ពុជា មានផលិតភាព 25-40 ភាគរយលើសពីក្រុមហ៊ុនដែលមិនធ្វើការនាំចេញ និងក្រុមហ៊ុនក្នុងស្រុក[៩]។

ទីបី ភាពសាំញ៉ាំនៃសេដ្ឋកិច្ចកម្ពុជា និងការចំណាយផ្នែកពាណិជ្ជកម្ម បង្ហាញពីលទ្ធភាពរបស់កម្ពុជាក្នុងការចូលរួមក្នុងសង្វាក់តម្លៃសកល និងតំបន់។ បច្ចុប្បន្ន កម្ពុជាត្រូវបានបញ្ចូលទៅក្នុងសង្វាក់តម្លៃសកលសាមញ្ញបំផុត ក្នុងទម្រង់ដែលសាមញ្ញតិចបំផុត (សម្លៀកបំពាក់ជាអ្នកបញ្ជាទិញ) និងមានជំនាញលើផលិតផលដែលងាយជំនួស មិនសូវសាំញ៉ាំ និងមានគុណភាពទាប។ កម្ពុជាមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើសមាហរណកម្មចូលក្នុងសង្វាក់តម្លៃសកលលើគ្រប់ផ្នែកទាំងអស់ ទាំងការផលិតផលិតផលសម្រេច និងអន្តរការីក្នុងសង្វាក់តម្លៃសកល។ បើទោះជាកម្ពុជាមានសមត្ថភាពខ្ពស់ល្មមពាក់ព័ន្ធនឹងពាណិជ្ជកម្ម (រូប B2.3a) ប៉ុន្តែ សមត្ថភាពទាំងនោះនៅតែទាបជាងលក្ខខណ្ឌតម្រូវសម្រាប់ការធ្វើសមាហរណកម្មទៅក្នុងសកម្មភាពផលិតកាន់តែសាំញ៉ាំ។ តាមពិតទៅ សូចនាករស្តីពីការចំណាយលើការសម្រួលពាណិជ្ជកម្ម បង្ហាញថា កម្ពុជានៅក្រោមប្រទេសនានាក្នុងតំបន់ពាក់ព័ន្ធនឹងលក្ខខណ្ឌរូបិយវត្ថុ និងពេលវេលា ហើយការចំណាយនេះបានកើនឡើងទៀតផង (រូប B2.3b)។

ទីបួន គុណភាព និងភាពសកម្មបច្ចុប្បន្ននៃទំនាក់ទំនងទៅនឹងសង្វាក់ផ្គត់ផ្គង់រវាងការវិនិយោគផ្ទាល់ពីបរទេស និងក្រុមហ៊ុននៅកម្ពុជា នៅមានកម្រិតទាប។ ដោយសារតែមានការវិនិយោគផ្ទាល់ពីបរទេសច្រើន ការពង្រឹងទំនាក់ទំនងជាមួយក្រុមហ៊ុនអន្តរជាតិក្នុងស្រុក ដើម្បីទទួលបានការចែករំលែកចំណេះដឹង គឺជាគោលដៅយូរអង្វែងនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។ ទំនាក់ទំនងទាំងនេះ គឺជាបណ្តាញដ៏សំខាន់សម្រាប់ឲ្យក្រុមហ៊ុនបរទេសផ្ទេរបច្ចេកវិទ្យា ចំណេះធ្វើ និងការគ្រប់គ្រងព្រមទាំងបង្កើនផលិតភាពរបស់ក្រុមហ៊ុនផ្គត់ផ្គង់។ នៅពេលមានទំនាក់ទំនងទៅនឹងក្រុមហ៊ុននាំចេញ ទំនាក់ទំនងទាំងនេះជាបណ្តាញសម្រាប់ឲ្យក្រុមហ៊ុនផ្គត់ផ្គង់ជ្រៀតចូលក្នុងទីផ្សារ និងសង្វាក់តម្លៃអន្តរជាតិ ប៉ុន្តែការវិនិយោគផ្ទាល់ពីបរទេសភាគច្រើនប្រើប្រាស់កម្ពុជា ជាទីតាំងនាំចេញសម្រាប់ផលិតកម្មដែលមានការចំណាយតិច និងផលិតភាពទាប ដែល

**រូប B2.3a ៖ បង្ហាញពីកម្រិតសមត្ថភាពនៃផលិតផលក្នុងសង្វាក់តម្លៃសកល និងលទ្ធភាពរបស់កម្ពុជា**

(គម្លាតជាស្តង់ដារធៀបនឹងមធ្យមភាគសកល)




*ប្រភព* ៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើ Centre d'Etudesk Prospectives et d'Information Internationales (CEPII) មូលដ្ឋានទិន្នន័យ The Changing Wealth of Nations មូលដ្ឋានទិន្នន័យ Barro and Lee Education, Penn World Table 9.0 សូចនាករអភិបាលកិច្ចរបស់ធនាគារពិភពលោក សន្ទស្សន៍ប្រតិបត្តិការភស្តុភាររបស់ធនាគារពិភពលោក និង Farole and Pathikoda (2016)។

**រូប B2.3b ៖ សូចនាករនៃការធ្វើពាណិជ្ជកម្មឆ្លងដែនរបស់កម្ពុជា ធៀបនឹងមធ្យមភាគក្នុងតំបន់**

(លើស 1 មានន័យថា កម្ពុជាមានការចំណាយខ្ពស់ក្នុងការធ្វើពាណិជ្ជកម្មជាងមធ្យមភាគក្នុងតំបន់)




*ប្រភព* ៖ ការធ្វើពាណិជ្ជកម្មឆ្លងដែន ៖ ការធ្វើធុរកិច្ច ធនាគារពិភពលោក

---

៧ រួមមាន ការរួមចំណែកផ្ទាល់ និងការរួមចំណែកតាមរយៈវិស័យផ្សេងទៀត (ទំនាក់ទំនងលើផ្នែកផ្សេងៗក្រោយពីផលិតកម្ម)។

៨ ការខុសគ្នាទាំងនេះគឺបណ្តាលមកពីផ្នែកផ្សេងៗតាមវិស័យនៃការនាំចេញរបស់ប្រទេសនីមួយៗ ព្រោះថា ការដឹកជញ្ជូន និងឡូជីស្ទីកជាបញ្ហាសំខាន់ដោយសារតែចំនួនទំនិញនាំចេញ រួមនឹងភាពខុសគ្នានៃការចំណាយដែលប្រទេសនានាជួបប្រទះក្នុងការផ្តល់ដល់វិស័យទាំងនេះ។

៩ វាស់វែងតាមរយៈការប្រៀបធៀបផលិតភាពសរុប ទំហំ និងប្រាក់ឈ្នួលសម្រាប់ក្រុមហ៊ុននៅគ្រប់ប្រទេសទាំងអស់ ក្នុងប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប សម្រាប់តែតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក និងកម្ពុជាតែប៉ុណ្ណោះ។

មានសក្តានុពលតិចតួចក្នុងការផ្ទេរមូលធន និងចំណេះដឹង។ ក្រុមហ៊ុនផលិតកម្មដែលជាការវិនិយោគផ្ទាល់ពីបរទេស នាំចូលវត្ថុធាតុដើមផលិតកម្មប្រមាណ 95 ភាគរយ ដែលជាកម្រិតខ្ពស់បំផុតធៀបនឹងប្រទេសជិតខាង។ ចំណែកនៃការនាំចូលមានកំណើនបន្ថែមទៀត បើធៀបនឹងឆ្នាំ 2013។ ចំណុចនេះបង្ហាញថា មានតម្រូវការតិចតួចពីការវិនិយោគផ្ទាល់ពីបរទេសបច្ចុប្បន្ន ដែលត្រូវបានក្រុមហ៊ុនក្នុងស្រុកឆ្លើយតប ហើយតម្លៃភាគច្រើនត្រូវបានក្រុមហ៊ុនបរទេសស្រូបយក (រូប B2.4a)។ ទំនាក់ទំនងក្នុងវិស័យសេវាកម្មមានលក្ខណៈទូលំទូលាយជាង។

**រូប B2.4a ៖ ចំណែកនៃវត្ថុធាតុដើមពីបរទេសក្នុងប្រតិបត្តិការកម្មន្តសាល**




*ប្រភព* ៖ ការអង្កេតសហគ្រាសរបស់ក្រុមធនាគារពិភពលោក 2016

បរិយាកាសវិនិយោគនៅកម្ពុជាបច្ចុប្បន្ន មិនបានដោះស្រាយការបរាជ័យនៃទីផ្សារ និងឧបសគ្គដែលរាំងស្ទះវិស័យឯកជនមិនឲ្យទទួលផលប្រយោជន៍ពីទំនាក់ទំនងនេះឡើយ។ ក្រុមហ៊ុនដែលជាការវិនិយោគផ្ទាល់ពីបរទេស លើកឡើងថា[១០] កង្វះក្រុមហ៊ុនក្នុងស្រុកដែលមានភាពប្រកួតប្រជែង ក្នុងវិស័យដែលជាការវិនិយោគផ្ទាល់ពីបរទេស គឺជាឧបសគ្គធំជាងគេ។ ឧបសគ្គបន្ទាប់ទៀតគឺការចំណាយខ្ពស់ក្នុងការស្វែងរកក្រុមហ៊ុនផ្គត់ផ្គង់សមស្រប ក្រុមហ៊ុនផ្គត់ផ្គង់គ្មានលទ្ធភាពក្នុងការបំពេញលក្ខខណ្ឌគុណភាព និងការចំណាយនានា និងការខ្វះឯកសារបញ្ជាក់ជាមូលដ្ឋាន[១១] ដំណើរការលំបាកក្នុងការទាមទារពន្ធលើតម្លៃបន្ថែមមកវិញ និងដំណើរការងារក្រៅផ្លូវការ។ ដូចគ្នានេះដែរ ក្រុមហ៊ុនផ្គត់ផ្គង់នៅកម្ពុជាលើកឡើងថា កង្វះខាតផលិតភាព និងកម្លាំងពលកម្មជំនាញ គឺជាឧបសគ្គរាំងដល់ការទំនាក់ទំនងទៅនឹងការវិនិយោគផ្ទាល់ពីបរទេស។ ដោយសារតែការចំណាយពេលវេលាយូរក្នុងហិរញ្ញប្បទាននៃសង្វាក់ផ្គត់ផ្គង់ និងភាពចាំបាច់នៃការវិនិយោគដែលត្រូវមានក្នុងការកែលម្អសមត្ថភាពផលិតកម្ម លទ្ធភាពទទួលបានហិរញ្ញវត្ថុគឺជាបញ្ហាចោទសម្រាប់ក្រុមហ៊ុនផ្គត់ផ្គង់នៅកម្ពុជា នៅពេលមានទំនាក់ទំនងជាមួយនឹងការវិនិយោគផ្ទាល់ពីបរទេស។

បច្ចុប្បន្ន មិនសូវមានហេដ្ឋារចនាសម្ព័ន្ធគាំទ្រអាជីវកម្មសម្រាប់ជាប្រយោជន៍ដល់វិស័យឯកជនក្នុងស្រុកឡើយ។ គំនិតផ្តួចផ្តើមថ្មីៗរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើតមូលនិធិជំរុញសហគ្រិនភាព ធនាគារសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម និងការលើកទឹកចិត្តផ្នែកពន្ធ ដើម្បីគាំទ្រសហគ្រាសខ្នាតតូច និងមធ្យមក្នុងវិស័យអាទិភាពនានា គឺជាវិធានការទីមួយ។ វិថីទៅកាន់ភាពជោគជ័យអាស្រ័យលើការផ្តោតលើភាពលម្អិត លក្ខខណ្ឌ និងការអនុវត្តគំនិតផ្តួចផ្តើមទាំងនេះ។ មានចំណុចសំខាន់ពីរដែលជាការរៀនសូត្រពីបទពិសោធន៍អន្តរជាតិ។ ទីមួយ ហិរញ្ញវត្ថុតែមួយមុខជាធម្មតាគ្មានប្រសិទ្ធភាពឡើយ។ ការគាំទ្រត្រូវរួមមាន ក្របខណ្ឌច្បាប់ និងគោលនយោបាយគាំទ្រ ព្រមទាំងសេវាជំរុញក្នុងទម្រង់ជាការអភិវឌ្ឍសមត្ថភាពសហគ្រាស ការកសាងធនធានមនុស្ស និងព័ត៌មានទីផ្សារ។ ទីពីរគឺគោលការណ៍សម្រាប់ការរួមចំណែកក្នុងស្រុក ជាពិសេសពាក់ព័ន្ធនឹងវិស័យដែលងាយនឹងជំនួស និងធ្វើពាណិជ្ជកម្មបាន ដែលជាទូទៅមិនអាចដំណើរការបានទេ ព្រោះវាមិនបានដោះស្រាយបញ្ហាជាមូលដ្ឋាន និងអាចធ្វើឲ្យបញ្ហាកាន់តែធ្ងន់ធ្ងរ និងប៉ះពាល់ដល់ភាពប្រកួតប្រជែងរយៈពេលវែង។ នៅពេលគោលការណ៍ទាំងនោះត្រូវបានអនុវត្តតែចំពោះវិនិយោគិនមួយក្រុមនោះ វានឹងប៉ះពាល់ដល់ការប្រកួតប្រជែង។

ការពិនិត្យទៅលើបរិយាកាសវិនិយោគបង្ហាញថា សេដ្ឋកិច្ចកម្ពុជាកំពុងផ្តោតលើការគាំទ្រលំនាំកំណើនដែលមានតម្លៃទាប និងការចំណាយទាប ហើយលក្ខណៈមួយចំនួននៃលំនាំនេះបានធ្វើឲ្យកម្ពុជាមានកម្រិតប្រាក់ចំណូលបច្ចុប្បន្ននេះ។ ដោយសារតែជោគជ័យកន្លងមក កម្ពុជាត្រូវកែសម្រួលលំនាំនេះឲ្យជំរុញកំណើនផលិតភាពដែលជាចលករសំខាន់សម្រាប់កំណើន និងវិបុលភាពអនាគត។ ការធ្វើបែបនេះក៏សំខាន់ក្នុងការឆ្លើយតបទៅនឹងកត្តាសង្គម និងបរិស្ថាន និងការបញ្ចៀសការជាប់គាំងក្នុងប្រាក់ចំណូលមធ្យម ដែលអាចមាន។ ទីមួយ ការទំនាក់ទំនងជាសកលតាមរយៈពាណិជ្ជកម្ម ការវិនិយោគផ្ទាល់ពីបរទេស ការចូលរួមក្នុងសង្វាក់តម្លៃសកល និងការផ្ទេរកម្លាំងពលកម្មជំនាញ ត្រូវតែធ្វើការជំរុញ។ ទីពីរ ការវិនិយោគលើការអប់រំ និងជំនាញ ជាកត្តាសំខាន់ដើម្បីធានាថា កម្មករនិយោជិតមានសមត្ថភាពរៀនជំនាញថ្មីៗដើម្បីចាប់យកឱកាសថ្មី និងសម្របខ្លួនទៅនឹងការវិវឌ្ឍនៃបច្ចេកវិទ្យា និងលក្ខខណ្ឌការងារ។ ទីបី ការវិនិយោគលើសហគ្រិនភាព និងការច្នៃប្រឌិត ជាការចាំបាច់ក្នុងការធ្វើយ៉ាងណាឲ្យសេដ្ឋកិច្ចកម្ពុជាអាចស្រូបយក បន្សាំ និងទទួលប្រយោជន៍ពេញលេញពីទំនាក់ទំនងជាមួយអន្តរជាតិ និងបច្ចេកវិទ្យាថ្មីៗ។ ការខិតខំធ្វើកំណែទម្រង់បរិយាកាសវិនិយោគជាកត្តាដែលមិនអាចខ្វះបាននៅក្នុងដំណើរការផ្លាស់ប្តូរនេះ។

ដូចអ្វីដែលសេដ្ឋកិច្ចវិទូ Paul Krugman ម្ចាស់ពានរង្វាន់ណូបែលបានលើកឡើង “ផលិតភាពមិនមែនជាអ្វីគ្រប់យ៉ាងឡើយ ប៉ុន្តែ ក្នុងរយៈពេលវែង វាស្ទើរតែជាអ្វីគ្រប់បែបយ៉ាង”។ ច្បាស់ណាស់ថា ប្រសិនបើកម្ពុជាចង់សម្រេចបានគោលដៅប្រកបដោយមហិច្ឆិតារបស់ខ្លួន ដូចមានកំណត់ក្នុងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ៤[១២] ក្នុងការក្លាយទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ 2030 ដោយមានចក្ខុវិស័យសម្រេចបានចំណាត់ថ្នាក់ជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ 2050 កម្ពុជាត្រូវពិចារណាឡើងវិញលើលំនាំកំណើនរបស់ខ្លួន។ កត្តាកំណត់ជោគជ័យសំខាន់គឺថាតើអ្នកតាក់តែងគោលនយោបាយនៅកម្ពុជាអាចមានទស្សនវិស័យរយៈពេលវែងរបស់ខ្លួនដោយជោគជ័យឬទេ។

---

១០ ក្រុមធនាគារពិភពលោកបានធ្វើការអង្កេតក្រុមហ៊ុនដែលជាការវិនិយោគផ្ទាល់ពីបរទេស និងក្រុមហ៊ុនផ្គត់ផ្គង់នៅឆ្នាំ 2017។ លទ្ធផលទាំងនេះគឺជាលទ្ធផលនៃការអង្កេតនេះ។

១១ ក្រុមហ៊ុននៅកម្ពុជាតែ 5 ភាគរយប៉ុណ្ណោះដែលមានលិខិតបញ្ជាក់ទទួលស្គាល់ជាអន្តរជាតិ។ អត្រាមធ្យមភាគក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក គឺ 12 ភាគរយ។

១២ http://cnv.org.kh/wp-content/uploads/2012/10/Rectangular-Strategy-Phase-IV-of-the-Royal-Government-of-Cambodia-of-the-Sixth-Legislatureof-the-National-Assembly-2018-2023.pdf.

### កម្ពុជាទទួលបានជោគជ័យល្អនៅក្នុងការទាក់ទាញលំហូរការវិនិយោគផ្ទាល់ពីបរទេស ដោយសារគោលនយោបាយវិនិយោគ និងពាណិជ្ជកម្មសេរីរបស់ខ្លួន

**ក្នុងរយៈពេល 10 ឆ្នាំចុងក្រោយនេះ កម្ពុជាទទួលបានលំហូរសរុបនៃការវិនិយោគផ្ទាល់ពីបរទេសយ៉ាងច្រើនប្រហែល 10 ភាគរយនៃ ផសស។** កម្ពុជាស្ថិតក្នុងចំណោមប្រទេសឈានមុខគេទាំង 20 ក្នុងពិភពលោកដែលមានអត្រាលំហូរការវិនិយោគផ្ទាល់ពីបរទេសសរុបធៀបនឹង ផសស កម្រិតខ្ពស់ (រូប 15)។ ផ្អែកតាមការសិក្សាប្រចាំឆ្នាំដោយ FDI Intelligence ដែលផ្តោតលើការវិនិយោគលើសង្វាក់ផ្គត់ផ្គង់នៅឆ្នាំ 2017 ធៀបនឹងទំហំសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗ កម្ពុជាជាប្រទេសឈានមុខនៅអាស៊ី និងជាប់លំដាប់ទីបីជារួម។ សិង្ហបុរីឈរនៅលំដាប់ទីពីរ និងវៀតណាមទីបី[១២]។

**ក្នុងការជំរុញពិពិធកម្មការនាំចេញ ទំនាក់ទំនងសង្វាក់ផ្គត់ផ្គង់គឺជាបណ្តាញសំខាន់សម្រាប់ឲ្យក្រុមហ៊ុន ដែលជាការវិនិយោគផ្ទាល់ពីបរទេស ផ្ទេរបច្ចេកវិទ្យា ចំណេះធ្វើ និងជំនាញគ្រប់គ្រង។** ការកែលម្អបរិយាកាសវិនិយោគដើម្បីគាំទ្រសហគ្រាសខ្នាតតូច និងមធ្យម និងអាជីវកម្មឲ្យលូតលាស់ និងទទួលផលពីការវិនិយោគផ្ទាល់ពីបរទេស ដែលជាកំណើនផលិតភាពដែលទទួលបានពីការផ្ទេរចំណេះដឹង និងបច្ចេកវិទ្យាពីវិនិយោគិនបរទេសសម្រាប់សេដ្ឋកិច្ចក្នុងស្រុក ជាកត្តាសំខាន់បំផុតសម្រាប់សេដ្ឋកិច្ចប្រមូលផ្តុំ និងខ្នាតតូចរបស់កម្ពុជា (សូមមើលប្រអប់ 2)។

**ទំនុកចិត្តរឹងមាំរបស់អ្នកប្រើប្រាស់ រួមនឹងកំណើនប្រាក់ឈ្នួលបានបង្កើនអតិផរណា ដែលកើនដល់ 2.9 ភាគរយ (ធៀបនឹងឆ្នាំមុន) នៅខែ មិថុនា ឆ្នាំ 2018 កើនឡើងពី 2.2 ភាគរយនៅខែធ្នូ ឆ្នាំ 2017** (រូប 16)។ ដោយសារការកើនឡើងតម្លៃផលិតផលពីសត្វ ជាពិសេស សាច់គោ ត្រី និងអាហារសមុទ្រ សមាសធាតុម្ហូបអាហារ (សន្ទស្សន៍រង) ដែលមានចំណែក 43 ភាគរយនៃអតិផរណាសរុប រួមចំណែក 1.7 ភាគរយដល់កំណើនសន្ទស្សន៍តម្លៃអ្នកប្រើប្រាស់។ មធ្យោបាយដឹកជញ្ជូនរួមចំណែក 0.4 ភាគរយ។ គួរកត់សម្គាល់ថា លក្ខខណ្ឌធាតុអាកាសល្អប្រសើរ បានជួយដល់ការពង្រីកផលិតកម្មកសិកម្ម ដែលបានជួយត្បិតត្បៀតតម្លៃលក់រាយរបស់ម្ហូបអាហារមួយចំនួន ជាពិសេស អង្ករ បន្លែ និងផ្លែឈើ។ ស្ថានភាពនេះបានធ្វើឲ្យសម្ពាធអតិផរណាថយចុះ។

**លើសពីនេះទៀត ដើម្បីរក្សាស្ថិរភាពតម្លៃលក់រាយផលិតផលប្រេងឥន្ធនៈនៅពេលមានការកើនឡើងតម្លៃប្រេងក្នុងទីផ្សារអន្តរជាតិ អាជ្ញាធរកម្ពុជាបានកាត់បន្ថយពន្ធពិសេសមួយលើផលិតផលប្រេងឥន្ធនៈនាំចូល។** នៅខែ កក្កដា ឆ្នាំ 2018 មានការកាត់បន្ថយពន្ធពិសេសមួយ (ក្នុងចំណោមពន្ធទាំង 4) លើផលិតផលប្រេងឥន្ធនៈនាំចូល។ ពន្ធពិសេសត្រូវបានបន្ថយមកត្រឹម 15 ភាគរយ (ពី 35 ភាគរយ) សម្រាប់ប្រេងសាំង បន្ថយមកត្រឹម 5.5 ភាគរយសម្រាប់ប្រេងម៉ាស៊ូត (ពី 15 ភាគរយ) និងកាត់បន្ថយមកត្រឹម 5 ភាគរយសម្រាប់ប្រេងកាត (ពី 15 ភាគរយ)[១៣]។ របាយការណ៍បង្ហាញថា ប្រាក់ចំណូលដែលខាតបង់ គឺ 30 លានដុល្លារក្នុងមួយឆ្នាំ។ ដោយសារកម្ពុជានាំចូលផលិតផលប្រេងឥន្ធនៈទាំងអស់សម្រាប់ការប្រើប្រាស់ក្នុងស្រុក មានការផ្ទេរ "ឥទ្ធិពល" ពេលលេញពីតម្លៃប្រេងអន្តរជាតិទៅលើតម្លៃលក់រាយក្នុងស្រុក។

**តំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិកក៏មានកំណើនអតិផរណាផងដែរ ជាពិសេសនៅមីយ៉ាន់ម៉ា ហ្វីលីពីន និងវៀតណាម ដែលការកើនឡើងនៃតម្លៃទំនិញប្រើប្រាស់ បានធ្វើឲ្យមានគោលនយោ**

**រូប 15 ៖កម្ពុជាស្ថិតក្នុងចំណោមប្រទេសទាំង 20 ដែលទទួលបានលំហូរសរុបនៃការវិនិយោគផ្ទាល់ពីបរទេសច្រើនជាងគេ**

គិតជាភាគរយនៃ ផសស (2017)




*ប្រភព* ៖ សូចនាករអភិវឌ្ឍន៍ពិភពលោក

*សម្គាល់* ៖ ឆ្នាំ 2017 ឬឆ្នាំថ្មីបំផុត

**រូប 16 ៖ ការរួមចំណែកដល់អតិផរណារយៈពេល 12 ខែ**

(ភាគរយ)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

[១២] https://www.fdiintelligence.com/Locations/Asia-Pacific/Mozambique-tops-2017-Greenfield-FDI-Performance-Index?utm_campaign=August+2018+enews+2&utm_source=emailCampaign&utm_medium=email&utm_content.

[១៣] http://cnv.org.kh/petroleum-price-decrease-0-03-first-july/.

**បាយឆ្លើយតប**[១៤]។ ទាំងតម្លៃសម្រាប់អ្នកប្រើប្រាស់ និងអ្នកផលិតសុទ្ធតែត្រូវបានរំពឹងថានឹងកើនឡើង ដោយសារកត្តាសំខាន់ៗ 4 គឺ (ក) កំណើនសេដ្ឋកិច្ចរឹងមាំដែលលុបបំបាត់គម្លាតផលនៃការវិនិយោគ (ខ) ការធ្លាក់ថ្លៃគិតជាតួលេខដែលបង្កើនតម្លៃផលិតផលនាំចូល (គ) ឥទ្ធិពលនៃការកើនឡើងតម្លៃប្រេង និងអាហារនៅសកលលោក និង (ឃ) កំណើនប្រាក់ឈ្នួល។ ការកើនឡើងនៃថ្លៃផលិតកម្មបង្ហាញថា សម្ពាធតម្លៃអាចចាប់ផ្តើមកើតមាន ទោះបីជាតម្លៃអ្នកប្រើប្រាស់ ជាទូទៅស្ថិតក្នុងគោលដៅរបស់ធនាគារជាតិក្នុងតំបន់ក្តី។

### ទំនុកចិត្តលើប្រព័ន្ធធនាគារបន្តគាំទ្រការដាក់ប្រាក់បញ្ញើជារូបិយវត្ថុបរទេស

**យ៉ាងណាក៏ដោយ កំណើនរូបិយប័ណ្ណទូលាយ ថយចុះបន្តិចមកត្រឹម 21.6 ភាគរយនៅខែ មិថុនា ឆ្នាំ 2018 ដោយបានថយចុះពី 23.8 ភាគរយនៅខែ ធ្នូ ឆ្នាំ 2017។** ការថយចុះបន្តិចនេះគឺបណ្តាលមកពីកំណើនយឺតនៃប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស ដែល 18.8 ភាគរយ (ខណៈដែលការនាំចូលកើនឡើង) និងរូបិយវត្ថុក្នុងស្រុកដែលកំពុងធ្វើចរាចរណ៍ចំនួន 2 ភាគរយ ថយចុះពី 19.6 ភាគរយសម្រាប់ប្រាក់បញ្ញើ និង 3.2 ភាគរយសម្រាប់រូបិយវត្ថុក្នុងស្រុក (រូប 17)។

**កំណើនប្រាក់បម្រុងបរទេសដុលនៅតែបន្តមាន បើទោះជាក្នុងល្បឿនយឺតជាងមុន ដោយសារតែការថយចុះនៃកំណើនប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស។** រូបិយវត្ថុបរទេសបម្រុងទុកដុលរបស់ធនាគារកណ្តាលកើនដល់ 9.08 ពាន់លានដុល្លារ ឬស្មើនឹងរយៈពេល 6 ខែនៃការនាំចេញនៅពេលអនាគត នៅខែ មិថុនា ឆ្នាំ 2018។ ការចរាចរណ៍ប្រាក់រៀលបន្តកើនឡើង ប៉ុន្តែក្នុងល្បឿនយឺតជាងមុន ដោយថយចុះមកត្រឹម 18.2 ភាគរយ (ធៀបនឹងឆ្នាំមុន) នៅខែ មិថុនា ឆ្នាំ 2018 ដោយថយចុះពី 28.2 ភាគរយនៅខែ ធ្នូ ឆ្នាំ ២០១៧ (រូប 18) ដោយសារតែរូបិយវត្ថុក្នុងស្រុករងសម្ពាធពីកំណើនតម្រូវការនាំចូល។

**អត្រាប្តូរប្រាក់រៀល-ប្រាក់ដុល្លារ ធ្លាក់ចុះថ្លៃ** ដោយមានចំនួន 4,082 រៀល/ដុល្លារ នៅបំណាច់ខែ កញ្ញា ឆ្នាំ 2018 បើធៀបនឹងអត្រា 4,037 រៀល/ដុល្លារ នៅចុងខែ ធ្នូ ឆ្នាំ 2017។ ប្រាក់រៀលធ្លាក់ថ្លៃបន្តិច បើធៀបនឹងប្រាក់បាតថៃ ប៉ុន្តែអត្រាប្រាក់រៀលកើនឡើង បើធៀបនឹងប្រាក់ដុងវៀតណាម ធៀបនឹងរូបិយវត្ថុទីផ្សារនាំចូលសំខាន់ៗ (ក្រៅពីសហរដ្ឋអាមេរិក) អត្រាប្តូរប្រាក់រៀល-ប្រាក់អឺរ៉ូ ប្រាក់រៀល-ប្រាក់ដុល្លារកាណាដា ប្រាក់រៀល-ប្រាក់ផោនអង់គ្លេស កើនឡើង។

**យ៉ាងណាក៏ដោយ ដោយសារតែសេដ្ឋកិច្ចកម្ពុជាមានកម្រិតដុល្លាររូបនីយកម្មខ្ពស់ អត្រាប្តូរប្រាក់មិនបំពេញមុខងារបានពេញលេញឡើយ។** ឧទាហរណ៍ អត្រាប្តូរប្រាក់អាចមិនប៉ះពាល់ដល់តម្លៃក្នុងពាណិជ្ជកម្មអន្តរជាតិ។ ចំណែកនៃបញ្ញើជាប្រាក់ដុល្លារអាមេរិកធៀបនឹងចំណែកប្រាក់បញ្ញើសរុប មានអត្រា 95 ភាគរយ ឬ 68 ភាគរយនៃ ផសស។ ប្រតិបត្តិការធំៗ និងប្រាក់ឈ្នួលក្នុងវិស័យឯកជន ជាពិសេសក្នុងឧស្សាហកម្មកាត់ដេរ និងស្បែកជើងដែលជាវិស័យនាំចេញធំជាងគេរបស់កម្ពុជា ទូទាត់ជាប្រាក់ដុល្លារអាមេរិក។ នៅពេលដែលការផ្តល់មូលនិធិដោយដៃគូអភិវឌ្ឍន៍មានតិចជាងមុន ចំណាយសាធារណៈភាគច្រើន (ដូចជា ប្រាក់បៀវត្សរ៍មន្ត្រីរាជការ) ត្រូវបានទូទាត់ជាប្រាក់រៀល។ កំណើនចំណាយសាធារណៈធៀបនឹងភាគរយ ផសស ធ្វើឲ្យមានការប្រើប្រាស់រូបិយវត្ថុក្នុងស្រុកកាន់តែច្រើន។ ធនាគារជាតិនៅតែបន្តលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ។

**រូប 17 ៖ ការរួមចំណែកដល់កំណើនរូបិយវត្ថុទូលាយ**

(ភាគរយ)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

**រូប 18 ៖ ចរាចរណ៍ប្រាក់រៀល**

(ធៀបនឹងឆ្នាំមុន, ការប្រែប្រួលជាភាគរយ)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

[១៤] ធនាគារពិភពលោក ខែ តុលា ឆ្នាំ 2018 ៖ បច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក។

**អត្រាប្រាក់កម្ចីនៅតែបន្តថយចុះជាបណ្តើរៗ** (រូប 19)។ អត្រាប្រាក់កម្ចីជាប្រាក់ដុល្លារអាមេរិកបានថយចុះមកត្រឹម 11.4 ភាគរយ/ឆ្នាំ នៅខែ មិថុនា ឆ្នាំ 2018 ដោយថយពី 11.7 ភាគរយក្នុងមួយឆ្នាំនៅខែ ធ្នូ ឆ្នាំ 2017។ ប៉ុន្តែ អត្រាប្រាក់កម្ចីជាមធ្យមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានកម្រិតខ្ពស់ខ្លាំងជាងអត្រាប្រាក់កម្ចីរបស់ធនាគារ។ ការចំណាយខ្ពស់លើកម្ចី អាចធ្វើឲ្យធនាគារជាតិកំណត់កម្រិតអត្រាការប្រាក់ត្រឹម 18 ភាគរយនៅខែ មេសា ឆ្នាំ 2017 ដោយផ្តោតលើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលប្រាក់បញ្ញើ ប្រតិបត្តិករឥណទានជនបទដែលស្ថិតក្រោមការត្រួតពិនិត្យរបស់ខ្លួន។ អត្រាការប្រាក់មធ្យមរបស់ធនាគារនៅកម្ពុជានៅតែខ្ពស់ជាងនៅបណ្តាប្រទេសផ្សេងទៀតក្នុងតំបន់ និងពិភពលោក (រូប 20)។ នៅប្រទេសថៃ អត្រាការប្រាក់ឥណទានអប្បបរមាមធ្យម (អត្រាការប្រាក់របស់ធនាគារពាណិជ្ជ) ត្រឹមតែ 8 ភាគរយប៉ុណ្ណោះ[១៥]។ នៅប្រទេសវៀតណាម អត្រាការប្រាក់កម្ចីសម្រាប់ផលិតកម្ម និងអាជីវកម្ម គឺពី 6.8 ទៅ 9 ភាគរយ/ឆ្នាំសម្រាប់ឥណទានរយៈពេលខ្លី[១៦]។

**ភាពជោគជ័យនៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា ដែលបានអនុវត្តកាលពីឆ្នាំមុនដើម្បីបង្កើតអត្រាកំណត់កម្ចីរូបិយវត្ថុក្នុងស្រុក បានធ្វើឲ្យមានការថយចុះអត្រាប្រាក់កម្ចីជាប្រាក់រៀល។** ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានាដែលតម្រូវឲ្យមានមូលប័ត្រអាចជួញដូរបាន ជាសន្ទនីយភាពដើម្បីទទួលបានរូបិយវត្ថុក្នុងស្រុក (រួមនឹងការតម្រូវឲ្យមានការបង្កើនឥណទានជាប្រាក់រៀលរហូតដល់យ៉ាងតិច 10 ភាគរយនៃគម្រោងឥណទានសរុប ត្រឹមចុងឆ្នាំ 2019) បានផ្តល់លទ្ធភាពឲ្យធនាគារជាតិបញ្ចូលរូបិយវត្ថុក្នុងស្រុក និងរក្សាស្ថិរភាពអត្រាប្តូរប្រាក់រៀល-ប្រាក់ដុល្លារ[17]។ ដូច្នេះ អត្រាកម្ចីជាប្រាក់រៀលបានឈានមកមានចំនួនស្មើគ្នានឹងអត្រាកម្ចីជាប្រាក់ដុល្លារអាមេរិក។

**យ៉ាងណាក៏ដោយ អត្រាការប្រាក់បញ្ញើ នៅតែមិនប្រែប្រួល** ព្រោះធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលប្រាក់បញ្ញើប្រជែងគ្នាក្នុងការទទួលបានមូលនិធិ។ មធ្យមភាគនៃអត្រាការបញ្ញើជាប្រាក់ដុល្លារ (រយៈពេល 12 ខែ) មានអត្រាថេរត្រឹម 4.42 ភាគរយ/ឆ្នាំ នៅខែ មិថុនា ឆ្នាំ 2018។ ការពង្រីកយ៉ាងឆាប់រហ័សនៃវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ នៅតែបន្ត ដោយសារតែគម្លាតរវាងអត្រាប្រាក់កម្ចី និងអត្រាប្រាក់បញ្ញើ នៅតែមានទំហំធំ ជាពិសេសនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលប្រាក់បញ្ញើ (ដែលមានអត្រាប្រាក់កម្ចីជាមធ្យម 17.15 ភាគរយ ចំណែកអត្រាប្រាក់បញ្ញើគឺ 4.85 ភាគរយ នៅខែ មិថុនា ឆ្នាំ 2018)។ នេះក៏បង្ហាញថា ត្រូវកែលម្អបន្ថែមទៀតលើប្រសិទ្ធផលនៃវិស័យហិរញ្ញវត្ថុ។ គួរកត់សម្គាល់ថា ខណៈដែលអត្រាប្រាក់កម្ចីនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលប្រាក់បញ្ញើ ថយចុះ អត្រានេះនៅតែខ្ពស់ ប្រមាណ 25.7 ភាគរយ មុនពេលការកំណត់អត្រាការប្រាក់នៅខែ មេសា ឆ្នាំ 2017។

**គិតត្រឹមពាក់កណ្តាលឆ្នាំ 2018 ឥណទានមិនទាន់សងរួចសរុបដែលផ្តល់ដោយវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ កើនដល់ 93 ភាគរយនៃ ផសស ឬស្មើនឹង 92 ទ្រីលានរៀល (22.6 ពាន់លានដុល្លារអាមេរិក)។** ថ្វីបើមានអត្រាថយចុះបន្តិច ប៉ុន្តែនៅតែមានកំណើនឥណទានដដែល។ ទោះបីជាកំណើនឥណទានបន្តថយចុះបន្តិច ប៉ុន្តែផលធៀបឥណទាន-ផសស របស់ធនាគារ (និងមីក្រូហិរញ្ញវត្ថុ) បានកើនឡើងដល់ 73 ភាគរយ (និង 20 ភាគរយ) នៅចុងខែ មិថុនា ឆ្នាំ 2018 កើនពី 31.4 ភាគរយ

**រូប 19 ៖ អត្រាការប្រាក់ដុល្លា រយៈពេលខ្លីរបស់ធនាគារបានធ្លាក់ចុះ** (ភាគរយ/ឆ្នាំ)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

**រូប 20 ៖ អត្រាការប្រាក់កម្ចីកម្ពុជាធ្លាក់ចុះ បើទោះជានៅតែមានកម្រិតខ្ពស់** (ភាគរយ/ឆ្នាំ)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា និងធនាគារជាតិ/ការិយាល័យស្ថិតិក្នុងតំបន់

១៥ ធនាគារប្រទេសថៃ ៖ http://wwkw.bot.or.th

១៦ ស្ថានភាពសង្គម និងសេដ្ឋកិច្ចក្នុងត្រីមាសទីមួយក្នុងឆ្នាំ 2018 ៖ ការិយាល័យស្ថិតិទូទៅប្រទេសវៀតណាម ៖ https://www.gso.gov. vn/default _ en.aspx?tabid=622&ItemID=18799.

១៧ សូមមើល "បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា" ខែ មេសា ឆ្នាំ 2018 សម្រាប់ការពិភាក្សាលម្អិតស្តីពីការអនុវត្តប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានាក្នុងវិស័យរូបិយវត្ថុ។

(និង 3.8 ភាគរយ) នៅឆ្នាំ 2010 (រូប 21)។ វិស័យធនាគារផ្តល់ឥណទានក្នុងស្រុកសរុប 80 ភាគរយ ខណៈដែលឥណទាន 20 ភាគរយទៀតត្រូវបានផ្តល់ដោយវិស័យមីក្រូហិរញ្ញវត្ថុ ប៉ុន្តែ អត្រានេះមិនគិតឥណទានដែលផ្តល់ដោយវិស័យក្រៅផ្លូវការ (និងសកម្មភាពធនាគារមិនច្បាស់លាស់)។ ឥណទានក្នុងស្រុកដែលផ្តល់ដោយវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ កើនឡើងប្រមាណ 20.8 ភាគរយធៀបនឹងឆ្នាំមុន គិតត្រឹមពាក់កណ្តាលឆ្នាំ 2018 ថយចុះបន្តិចពីអត្រា 21.8 ភាគរយនៅចុងឆ្នាំ 2017។

**របាយការណ៍បង្ហាញថា ផលធៀបឥណទានមិនដំណើរការទាំងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ បានថយចុះ។** ផលធៀបឥណទានមិនដំណើរការសម្រាប់វិស័យធនាគារ កើនដល់ 3.1 ភាគរយនៅខែ មិថុនា ឆ្នាំ 2018 បើធៀបនឹងអត្រា 2.4 ភាគរយនៅចុងឆ្នាំ 2017[18]។ ដូចគ្នានេះដែរ ឥណទានមិនដំណើរការសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ កើនដល់ 5.0 ភាគរយនៅខែ មិថុនា ឆ្នាំ 2018 បើធៀបនឹងអត្រា 2.1 ភាគរយនៅចុងឆ្នាំ 2017។ យ៉ាងណាក៏ដោយ ត្រូវមានការបកស្រាយទៅលើផលធៀបឥណទានមិនដំណើរការដោយប្រុងប្រយ័ត្ន ព្រោះមានភាពមិនស៊ីសង្វាក់គ្នាលើចំណាត់ថ្នាក់ឥណទាន និងការបន្ត និងការផ្តល់ហិរញ្ញប្បទានឥណទានឡើងវិញ ដែលអាចបិទបាំងបញ្ហាផ្សេងៗ។

**វិស័យធនាគារមានអ្នកខ្ចីប្រាក់ចំនួន 755,000 នាក់ និងមានអ្នកដាក់ប្រាក់បញ្ញើធនាគារ 3.48 លាននាក់នៅឆ្នាំ 2017។** វិស័យមីក្រូហិរញ្ញវត្ថុមានអ្នកខ្ចីប្រាក់ប្រហែល 1.8 លាននាក់ និងអ្នកដាក់ប្រាក់បញ្ញើ 1.8 លាននាក់។ ដោយសារតែចំណែកទីផ្សារតូច និងចំនួនអ្នកខ្ចីប្រាក់ច្រើន ទំហំឥណទានមធ្យមក្នុងវិស័យមីក្រូហិរញ្ញវត្ថុមានត្រឹមតែ 9.4 លានរៀលប៉ុណ្ណោះ (ឬ 2,372

**រូប 21 ៖ កំណើនឥណទានក្នុងស្រុកថយចុះ ប៉ុន្តែនៅតែមានអត្រាកើនឡើង** (ភាគរយនៃ ផសស)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

ដុល្លារ) ឬស្មើនឹង 10 ភាគរយនៃទំហំឥណទានរបស់វិស័យធនាគារ។

**លទ្ធភាពទទួលបានហិរញ្ញវត្ថុពីវិស័យមីក្រូហិរញ្ញវត្ថុ ថយចុះដោយសារតែកំណើនយ៉ាងលឿននៃទំហំឥណទានមធ្យមរបស់វិស័យនេះ ដែលកើនឡើង 43 ភាគរយនៅឆ្នាំ 2017 កើនពីអត្រា 11.8 ភាគរយនៅឆ្នាំ 2016។** បើទោះជាកំណើនឥណទានរបស់វិស័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលប្រាក់បញ្ញើ មានអត្រា 36.1 ភាគរយនៅឆ្នាំ 2017 កើនពី 34.0 ភាគរយនៅឆ្នាំ 2016 ចំនួនអ្នកខ្ចីប្រាក់ (ដែលមាន 70 ភាគរយជាស្ត្រី) ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ បានថយចុះមកត្រឹម 1.8 លាននាក់នៅឆ្នាំ 2017 ថយពីចំនួន 1.88 លាននាក់នៅឆ្នាំ 2016។ លទ្ធភាពទទួលបានហិរញ្ញវត្ថុពីវិស័យធនាគារកើនឡើងបន្តិចនៅឆ្នាំ 2017។ ចំនួនអ្នកខ្ចីប្រាក់ក្នុងវិស័យធនាគារកើនឡើងបន្តិចត្រឹមតែ 1.1 ភាគរយនៅឆ្នាំ 2017 កើនដល់ 775,107 នាក់ ដែលជាចំនួនកើនឡើងបន្តិចពី 746,930 នាក់នៅឆ្នាំ 2016 (នៅពេលវិស័យនេះមានកំណើន 45.7 ភាគរយនៃចំនួនអ្នកខ្ចីប្រាក់ ដោយសារតែការចាត់ថ្នាក់ឡើងវិញពីប្រភេទគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយដែលទទួលប្រាក់បញ្ញើ ទៅជាធនាគារពាណិជ្ជ)។ ជាលទ្ធផល វិស័យធនាគារមានកំណើនទំហំឥណទានមធ្យម កើនឡើងប្រមាណ 17.2 ភាគរយ ដែលផ្ទុយពីដំណើរការល្អរបស់វិស័យនេះពាក់ព័ន្ធនឹងលទ្ធភាពទទួលបានហិរញ្ញវត្ថុនៅឆ្នាំ 2016 (នៅពេលដែលទំហំឥណទានមធ្យមថយចុះ 15.6 ភាគរយ)។

**បើទោះជាការកម្រិតអត្រាការប្រាក់ បានបន្ថយអត្រាការប្រាក់របស់វិស័យមីក្រូហិរញ្ញវត្ថុ ត្រូវមានការវិភាគបន្ថែមទៀតទៅលើឥទ្ធិពលនៃវិធានការនេះ លើលទ្ធភាពទទួលបានហិរញ្ញវត្ថុ។** សម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ ការថយចុះចំនួនអ្នកខ្ចីប្រាក់ បានចាប់ផ្តើមមានកាលពីមួយឆ្នាំមុនការកំណត់អត្រាការប្រាក់ (តារាង 1)

**តារាង 1 ៖ ទំហំឥណទានមធ្យមក្នុងវិស័យធនាគារ និងវិស័យមីក្រូហិរញ្ញវត្ថុ កើនឡើង ប៉ុន្តែលទ្ធភាពទទួលបានហិរញ្ញវត្ថុថយចុះ**

| | វិស័យធនាគារ | | វិស័យមីក្រូហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ទំហំឥណទានមធ្យម (US$) | ចំនួនអ្នកខ្ចីប្រាក់ | ទំហំឥណទានមធ្យម (US$) | ចំនួនអ្នកខ្ចីប្រាក់ |
| 2015 | 22,196.66 | 512,582 | 1,483.84 | 2,037,424 |
| 2016 | 18,723.75 | 746,930 | 1,659.46 | 1,899.914 |
| 2017 | 21,953.59 | 755,107 | 2,372.01 | 1,800,00 |

*ប្រភព* ៖ អាជ្ញាធរកម្ពុជា*ប្រភព* ៖ អាជ្ញាធរកម្ពុជា

[18] របាយការណ៍ពាក់កណ្តាលឆ្នាំ 2018 និងរបាយការណ៍ត្រួតពិនិត្យវិស័យធនាគារឆ្នាំ 2017 ធនាគារជាតិកម្ពុជា។

បើទោះជា មូលហេតុអាចបណ្តាលមកពីបញ្ហាផ្នែករចនាសម្ព័ន្ធ ដែលពាក់ព័ន្ធនឹងការធ្វើចំណាត់ថ្នាក់ឡើងវិញនៃប្រភេទគ្រឹះស្ថានហិរញ្ញវត្ថុទទួលប្រាក់បញ្ញើទៅជាធនាគារពាណិជ្ជនៅឆ្នាំ 2016 ក្តី។ ការកែសម្រួលលើការធ្វើចំណាត់ថ្នាក់ឡើងវិញនៃប្រភេទនេះ បង្ហាញថា ចំនួនអ្នកខ្ចីប្រាក់ក្នុងវិស័យមីក្រូហិរញ្ញវត្ថុថយចុះ 1.8 ភាគរយនៅឆ្នាំ 2016 និង 4.8 ភាគរយនៅឆ្នាំ 2017។ ក្នុងអំឡុងពេលដូចគ្នានេះ ចំនួនអ្នកខ្ចីប្រាក់ក្នុងវិស័យធនាគារកើនឡើង 22 ភាគរយនៅឆ្នាំ 2016 និង 0.7 ភាគរយនៅឆ្នាំ 2017[១៩]។ ដូច្នេះ ការកំណត់អត្រាការប្រាក់អាចប៉ះពាល់ខ្លាំងទៅលើលទ្ធភាពទទួលបានហិរញ្ញវត្ថុក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ប៉ុន្តែ ដោយសារតែទំហំឥណទានតូច និងប្រតិបត្តិការជ្រៀតចូលជ្រៅក្នុងតំបន់ជនបទ និងដាច់ស្រយាល លទ្ធភាពទទួលបានហិរញ្ញវត្ថុពីវិស័យមីក្រូហិរញ្ញវត្ថុពិតជាសំខាន់ណាស់ក្នុងការគាំទ្រសកម្មភាពផលិតកម្ម នាំឲ្យមានការកាត់បន្ថយភាពក្រីក្រ។ វិស័យមីក្រូហិរញ្ញវត្ថុដើរតួនាទីច្រើនក្នុងការជួយលើកកម្ពស់លទ្ធភាពទទួលបានហិរញ្ញវត្ថុសម្រាប់ប្រជាជនក្រីក្រ និងអ្នកដែលធ្លាប់រងផលប៉ះពាល់អវិជ្ជមានដោយសារកម្ចីក្រៅផ្លូវការ ដែលជាញឹកញាប់ពាក់ព័ន្ធនឹងកម្ចីដែលមានអត្រាការប្រាក់ខ្ពស់។

### គិតជាចំណែកនៃ ផសស ឥណទានរបស់វិស័យធនាគារនៅកម្ពុជាមានកម្រិតខ្ពស់ជាងឥណទានរបស់វិស័យធនាគារនៅឥណ្ឌូនេស៊ី និងហ្វីលីពីន

**ការប្រៀបធៀបក្នុងតំបន់បង្ហាញថា កំណើនឥណទានធនាគារនៅកម្ពុជាមានសន្ទុះលឿន ដោយសារតែវិស័យធនាគាររបស់កម្ពុជាទើបតែលូតលាស់** (រូប 22)។ សន្ទុះកំណើនឥណទានធនាគារដែលកើតឡើងក្រោយពេលចប់វិបត្តិហិរញ្ញវត្ថុសកលភាគច្រើនពាក់ព័ន្ធនឹងសន្ទុះកំណើនក្នុងវិស័យសំណង់ និងអចលនទ្រព្យ។ ដូចបង្ហាញក្នុងរូប 23 បើទោះជាកំណើនរួមនៃឥណទានធនាគារថយចុះ ចាប់ពីពាក់កណ្តាលឆ្នាំ 2016 វិស័យសំណង់ និងអចលនទ្រព្យ នៅតែមានកំណើនយ៉ាងលឿន។ រូប 23 ក៏បង្ហាញថា ឥណទានធនាគារសម្រាប់វិស័យពាណិជ្ជកម្ម ដូចជា វិស័យលក់ដុំ លក់រាយ និងកម្មន្តសាល បានថយចុះយ៉ាងខ្លាំងតាំងពីពេលនោះមក។

**ថ្មីៗនេះ វិស័យអចលនទ្រព្យបានក្លាយជាសកម្មភាពទិញ/លក់ប្រថុយប្រថាន ដោយមានការទិញលក់ដីឡូតិ៍ ដែលផ្តល់ផលចំណេញមិនសូវច្បាស់លាស់ ឬមិនសមស្របទៅនឹងការវិនិយោគ។** ថ្មីៗនេះ រដ្ឋាភិបាលកម្ពុជាបានចេញប្រកាសស្តីពីការអភិវឌ្ឍដីធ្លីដើម្បីធានាឲ្យមានការគ្រប់គ្រងដីធ្លី និងនគរូបនីយកម្មប្រកបដោយនិរន្តរភាព[២០]។ ប្រកាសនេះអាចជាការប៉ុនប៉ងគ្រប់គ្រង និងទប់ស្កាត់ការរីករាលដាលនៃការអភិវឌ្ឍដីធ្លីដោយគ្មានការត្រួតពិនិត្យការទិញ/លក់ដីឡូតិ៍ (ចំពោះវិធានការរបស់ប្រទេសជិតខាងក្នុងការបញ្ចុះកម្តៅទីផ្សារអចលនទ្រព្យ សូមមើលប្រអប់ 3 ស្តីពីកិច្ចខិតខំប្រឹងប្រែងរបស់សិង្ហបុរី)។ ជាសំខាន់ ការកើនឡើងនៃលំហូរការវិនិយោគផ្ទាល់ពីបរទេសបានជួយរក្សាសន្ទុះកំណើនក្នុងវិស័យសំណង់ ក៏ដូចជាបិទបាំងភាពងាយរងគ្រោះរបស់វិស័យហិរញ្ញវត្ថុ ក្រោយមានកំណើនឥណទានយ៉ាងលឿនក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមក។

**រូប 22 ៖ កំណើនឥណទានធនាគារនៅកម្ពុជា ស្ថិតក្នុងចំណោមអត្រាខ្ពស់បំផុត** (ឥណទានក្នុងស្រុក, ភាគរយ ផសស)




*ប្រភព* ៖ បច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ខែ តុលា ឆ្នាំ 2018, ធនាគារពិភពលោក

**រូប 23 ៖ ការរួមចំណែកដល់កំណើនឥណទានក្នុងស្រុក** (ភាគរយពិន្ទុ)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

---

១៩ ផ្អែកតាមរបាយការណ៍ប្រចាំឆ្នាំ 2017 របស់ធនាគារស្ថាបនា មានអ្នកខ្ចីប្រាក់ចំនួន 113,000 នាក់ 121,500 នាក់ និង 125,200 នាក់នៅឆ្នាំ 2015 2016 និង 2017។

២០ ប្រកាសស្តីពីការអភិវឌ្ឍដីធ្លី ថ្ងៃទី 11 ខែ ឧសភា ឆ្នាំ 2018 របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រអប់ 3

## សិង្ហបុរីបានចេញវិធានការថ្មីដើម្បីសម្រួលដល់វិស័យអចលនទ្រព្យ[១]

ក្រោយចូលជាធរមាននៅថ្ងៃទី 6 ខែ កក្កដា ឆ្នាំ 2018 រដ្ឋាភិបាលសិង្ហបុរីបានចេញវិធានការថ្មី ដើម្បីសម្រួលដល់វិស័យអចលនទ្រព្យ សំដៅកាត់បន្ថយតម្រូវការវិនិយោគលើអចលនទ្រព្យសម្រាប់លំនៅដ្ឋាន និងឧស្សាហកម្ម។ នេះជាវិធានការថ្មីបំផុតក្នុងចំណោមវិធានការសម្របសម្រួលនានា ដែលរួមមាន ការបង្កើនថ្លៃពន្ធប្រថាប់ត្រារបស់អ្នកទិញ និងការរឹតត្បិតកម្រិតឥណទានធៀបនឹងតម្លៃ។

**បង្កើនថ្លៃពន្ធប្រថាប់ត្រារបស់អ្នកទិញ ៖ ពន្ធប្រថាប់ត្រារបស់អ្នកទិញត្រូវបានកំណត់លើការទិញអចលនទ្រព្យទាំងអស់។** ថ្លៃពន្ធប្រថាប់ត្រាបន្ថែមសម្រាប់អ្នកទិញ ដែលត្រូវបានអនុវត្តដំបូងនៅឆ្នាំ 2012 មានគោលដៅធានាថា អចលនទ្រព្យលំនៅដ្ឋាននៅតែមានតម្លៃសមរម្យសម្រាប់ពលរដ្ឋសិង្ហបុរី និងរក្សាស្ថិរភាពទីផ្សារអចលនទ្រព្យ។ អត្រាថ្លៃពន្ធប្រថាប់ត្រាបន្ថែមសម្រាប់អ្នកទិញត្រូវបានបង្កើនដល់ 5 ភាគរយសម្រាប់ប្រជាជនគ្រប់ស្រទាប់វណ្ណៈ និង 10 ភាគរយសម្រាប់អង្គភាពនានា លើកលែងតែពលរដ្ឋសិង្ហបុរី និងអ្នករស់នៅអចិន្ត្រៃយ៍ក្នុងប្រទេសសិង្ហបុរី ដែលទិញផ្ទះជាលើកដំបូង (សូមមើលរូប B3.1)។

**ការរឹតត្បិតផលធៀបឥណទាន និងការវាយតម្លៃ ៖ ធនាគារសិង្ហបុរីអនុញ្ញាតឲ្យផ្តល់ឥណទានលំនៅដ្ឋានដែលផ្អែកតែលើកម្រិតផលធៀបឥណទាន និងការវាយតម្លៃប៉ុណ្ណោះ។** ផលធៀបនេះជាភាគរយអតិបរមានៃតម្លៃទិញអចលនទ្រព្យ ឬតម្លៃវាយតម្លៃដែលអាចខ្ចីពីធនាគារ។ ក្រោយថ្ងៃទី 6 ខែ កក្កដា ឆ្នាំ 2018 អត្រាទាំងនេះត្រូវបានបន្ថយមកត្រឹម 5% នៃតម្លៃអចលនទ្រព្យសម្រាប់អ្នកដែលមិនទាន់មានឥណទាន (មើលរូប B3.2)។

ជាលទ្ធផល ការលក់ផ្ទះបានធ្លាក់ចុះ 49 ភាគរយ ចំណែកតម្លៃផ្ទះបានកើនឡើង 0.1 ភាគរយ ក្រោយការចេញវិធានការសម្របសម្រួលចុងក្រោយនេះ។ វិធានការដ៏ប្រុងប្រយ័ត្នទាំងនេះធ្វើឲ្យជនជាតិសិង្ហបុរីមិនសូវចង់ទិញផ្ទះថ្មី និងជួយទប់ស្កាត់មិនឲ្យតម្លៃអចលនទ្រព្យកើនឡើងលឿន។

### រូប B3.1 ៖ ការកែសម្រួលអត្រាថ្លៃពន្ធប្រថាប់ត្រាបន្ថែមសម្រាប់អ្នកទិញ

| | មុនថ្ងៃទី 5 ខែ កក្កដា ឆ្នាំ 2018 | ក្រោយថ្ងៃទី 6 ខែ កក្កដា ឆ្នាំ 2018 |
|---|---|---|
| ពលរដ្ឋសិង្ហបុរីដែលទិញផ្ទះលើកដំបូង | 0% | 0% (មិនប្រែប្រួល) |
| ពលរដ្ឋសិង្ហបុរីដែលទិញផ្ទះលើកទីពីរ | 7% | 12% |
| ពលរដ្ឋសិង្ហបុរីដែលទិញផ្ទះលើកទីបី និងជាបន្តបន្ទាប់ | 10% | 15% |
| អ្នករស់នៅអចិន្ត្រៃយ៍ក្នុងប្រទេសសិង្ហបុរីដែលទិញផ្ទះជាលើកដំបូង | 5% | 5% (មិនប្រែប្រួល) |
| អ្នករស់នៅអចិន្ត្រៃយ៍ក្នុងប្រទេសសិង្ហបុរីដែលទិញផ្ទះលើកទីពីរ និងជាបន្តបន្ទាប់ | 10% | 15% |
| ជនបរទេសដែលទិញអចលនទ្រព្យណាមួយ | 15% | 20% |
| អង្គភាពដែលទិញអចលនទ្រព្យណាមួយ | 15% | 25% + 5% (ថ្មី, មិនអាចបង្វែរបាន) |

*ប្រភព* ៖ អាជ្ញាធរប្រាក់ចំណូលដីគោកសិង្ហបុរី

*សម្គាល់* ៖ SCs=ពលរដ្ឋសិង្ហបុរី SPRs=អ្នករស់នៅអចិន្ត្រៃយ៍ក្នុងប្រទេសសិង្ហបុរី

### រូប B3.2 ៖ ការកែសម្រួលកម្រិតផលធៀបឥណទាន និងការវាយតម្លៃ

| | មុនថ្ងៃទី 5 ខែ កក្កដា ឆ្នាំ 2018 | ក្រោយថ្ងៃទី 6 ខែ កក្កដា ឆ្នាំ 2018 |
|---|---|---|
| កម្រិតផលធៀបសម្រាប់ផ្ទះដំបូង | 80% | 75% |
| កម្រិតផលធៀបសម្រាប់ផ្ទះទីពីរ | 50% | 45% |
| កម្រិតផលធៀបសម្រាប់ផ្ទះទីបី និងបន្តបន្ទាប់ | 40% | 35% |
| ប្រាក់បង់ដំបូងអប្បរមា (លុយសុទ្ធ) | 5% | 5% (មិនប្រែប្រួល) |
| ប្រាក់នៅសល់ (ប្រាក់សុទ្ធ/មូលនិធិប្រាក់សោធន) | 15% | 20% |

*ប្រភព* ៖ អាជ្ញាធរប្រាក់ចំណូលដីគោកសិង្ហបុរី

១ រៀបរៀងដោយលោកស្រី គី លីណា ទីប្រឹក្សាធនាគារពិភពលោក។

### ការពង្រឹកសារពើពន្ធបានជំរុញតម្រូវការក្នុងស្រុក ការប្រើប្រាស់ និងការនាំចូល

**ការពង្រីកសារពើពន្ធនៅឆ្នាំនេះបានជួយជំរុញតម្រូវការក្នុងស្រុក និងការប្រើប្រាស់ និងការនាំចូល។** តាមរយៈកំណើនប្រាក់ឈ្នួល និងការវិនិយោគសាធារណៈ ថវិកាសម្រាប់ចំណាយសាធារណៈត្រូវបានបង្កើនយ៉ាងច្រើន ដោយកើនដល់ 24.6 ភាគរយនៃ ផសស នៅឆ្នាំ 2018 ពីអត្រា 23.1 ភាគរយនៅឆ្នាំ 2017។

### ស្ថានភាពប្រាក់ចំណូលនៅឆ្នាំនេះនៅតែរឹងមាំ និងត្រូវបានព្យាករណ៍ថានឹងឆ្លើយតប ឬលើសគោលដៅថវិកាឆ្នាំ 2018

**យ៉ាងណាក៏ដោយ ដោយសារតែដំណើរការល្អបំផុតនៃការប្រមូលប្រាក់ចំណូលកាលពីឆ្នាំមុន ការប្រមូលប្រាក់ចំណូលនៅឆ្នាំនេះត្រូវបានប៉ាន់ស្មានថានឹងថយចុះបន្តិច** (រូប 24)។ ផ្អែកលើដំណើរការប្រមូលប្រាក់ចំណូលនៅឆមាសទីមួយក្នុងឆ្នាំ 2018 ប្រាក់ចំណូលក្នុងស្រុករបស់រដ្ឋាភិបាលនៅឆ្នាំនេះត្រូវបានរំពឹងថានឹងកើនឡើងប្រហែល 10 ភាគរយ ដែលត្រូវបានព្យាករណ៍ថានឹងកើនដល់ប្រមាណ 19 ភាគរយនៃ ផសស។

**ចំណូលក្នុងស្រុកនៅតែទទួលបានភាគច្រើនពីពន្ធប្រយោលដែលរួមចំណែកប្រហែលជាពាក់កណ្តាលនៃការប្រមូលចំណូលសរុបនៅឆ្នាំនេះ** ក្នុងនោះ ពន្ធលើតម្លៃបន្ថែម និងពន្ធអាករ (លើការនាំចូល) មានប្រមាណ 90 ភាគរយ។ ការរួមចំណែករបស់ពន្ធផ្ទាល់ឈរនៅលំដាប់ទីពីរ មានប្រមាណ 20 ភាគរយនៃការប្រមូលចំណូលសរុប។ ចំណូលផ្សេងៗទៀតបានមកពីចំណូលមិនមែនពន្ធ ពន្ធពាណិជ្ជកម្ម និងពន្ធផ្សេងទៀត។ ការប្រមូលពន្ធផ្ទាល់មានភាពប្រសើរឡើង និងមានការគ្រប់គ្រងបានល្អ។ ដោយសារតែកម្ពុជាមិនបានអនុវត្តពន្ធលើប្រាក់ចំណូលផ្ទាល់ខ្លួនខណៈដែលពន្ធលើប្រាក់ចំណូលពីអាជីវកម្មនៅតែលំបាកដោយសារតែការអនុគ្រោះពន្ធ កម្ពុជានៅតែពឹងផ្អែកលើពន្ធប្រយោលមួយរយៈខាងមុខ។ ចំណូលមិនមែនពន្ធមានភាពប្រសើរឡើងជាបណ្តើរៗ សំខាន់ដោយសារតែការកែលម្អប្រព័ន្ធប្រមូល និងគ្រប់គ្រងពន្ធតាមរយៈការអនុវត្តប្រកាសអន្តរក្រសួង និងប្រព័ន្ធចេញវិក្កយបត្រស្តង់ដារ។ ពន្ធលើពាណិជ្ជកម្មថយចុះ ដោយសារតែការប្តេជ្ញាចិត្តរបស់កម្ពុជាក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន (AFTA)។

**នៅរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដំណើរការប្រមូលប្រាក់ចំណូលមានភាពរឹងមាំគួរឲ្យកត់សម្គាល់ និងប្រហែលជាមិនអាចសម្រេចបានជាថ្មីទៀតក្នុងរយៈពេលប្រាំឆ្នាំក្រោយឡើយ លើកលែងតែមានយុទ្ធសាស្ត្រថ្មី។** យុទ្ធសាស្ត្រប្រមូលចំណូលថ្មីរយៈពេលប្រាំឆ្នាំក្រោយ ដែលរំពឹងថានឹងត្រូវបានណែនាំនៅពេលឆាប់ៗនេះ នឹងជួយធ្វើឲ្យការគ្រប់គ្រងចំណូលកាន់តែមានភាពប្រសើរ និងដោះស្រាយចំណុចខ្វះខាតផ្នែករចនាសម្ព័ន្ធនៃប្រព័ន្ធប្រមូលចំណូលបច្ចុប្បន្ន រួមទាំង ការពង្រីកមូលដ្ឋានចំណូលផងដែរ។

**ការពង្រីកសារពើពន្ធនៅឆ្នាំនេះ ក៏ជំរុញចំណាយទូទៅរបស់រដ្ឋាភិបាលលើការបង្កើនប្រាក់បៀវត្សរ៍របស់មន្ត្រីរាជការ និងការពង្រីកដំបូងនៃការវិនិយោគក្នុងវិស័យសាធារណៈ។** ប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈនឹងកើនឡើង 8.4 ភាគរយនៃ ផសស នៅឆ្នាំ 2018 (រូប 25) ដើម្បីសម្រេចគោលដៅប្រាក់បៀវត្សរ៍អប្បបរមារបស់មន្ត្រីរាជការឲ្យបានយ៉ាងហោចណាស់ 1 លានរៀលនៅឆ្នាំ 2018។ នេះមានន័យថា ប្រាក់បៀវត្សរ៍អប្បបរមារបស់មន្ត្រីរាជការបានកើនឡើងបីដង បើធៀបនឹងកម្រិតនៅឆ្នាំ 2013។ លើសពីនេះទៀត ជាលើកដំបូងបំផុតក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមក មានការជំរុញយ៉ាងខ្លាំងទៅលើការវិនិយោគដោយប្រើទុនក្នុងស្រុក។ ការពង្រីកសារពើពន្ធធំៗបានបង្កើនការចំណាយមូលធនក្នុងស្រុករហូតដល់ 3.2 ភាគរយនៃ ផសស កើនឡើងពី 2.3 ភាគរយនៅឆ្នាំ 2017។

**រូប 24 ៖ ចំណូលទូទៅរបស់រដ្ឋាភិបាល ៖ ផ្នែកសំខាន់ៗ**

(ភាគរយនៃ ផសស)




*ប្រភព ៖* អាជ្ញាធរកម្ពុជា

*សម្គាល់ ៖* e=ការប៉ាន់ស្មាន b=ថវិកា

**រូប 25 ៖ ចំណាយទូទៅរបស់រដ្ឋាភិបាល ៖ ផ្នែកសំខាន់ៗ**

(ភាគរយនៃ ផសស)




*ប្រភព ៖* អាជ្ញាធរកម្ពុជា

*សម្គាល់ ៖* e=ការប៉ាន់ស្មាន b=ថវិកា

**តារាង 2 ៖ ប្រាក់បៀវត្សរ៍នៅកម្ពុជាធៀបនឹងចំណាយ បានកើនឡើង និងស្ថិតក្នុងចំណោមអត្រាខ្ពស់ជាងគេនៅអាស៊ីអាគ្នេយ៍**

| ប្រាក់បៀវត្សរ៍ (% នៃចំណាយ) | 2008 | 2013 | 2017* |
|---|---|---|---|
| កម្ពុជា | 38.9 | 37.8 | 40.4 |
| ហ្វីលីពីន | 34.3 | 36.6 | 35.6 |
| ម៉ាឡេស៊ី | 27.2 | 29.1 | 34.9 |
| ឡាវ | 47.4 | 56.3 | 34.8 |
| ថៃ | 35.3 | 28.9 | 28.5 |
| សិង្ហបុរី | 27.2 | 29.6 | 26.6 |
| ឥណ្ឌូនេស៊ី | 12.4 | 15.1 | 16.4 |

*ប្រភព* ៖ សូចនាករអភិវឌ្ឍន៍ពិភពលោក អាជ្ញាធរកម្ពុជា និងរបាយការណ៍បុគ្គលិករបស់ IMF កថាខណ្ឌ IV ឆ្នាំ 2018

*សម្គាល់* ៖ * ទិន្នន័យសម្រាប់ឆ្នាំ 2016 លើកលែងតែសម្រាប់កម្ពុជា និងឡាវ

**តារាង 3 ៖ ប្រាក់បៀវត្សរ៍នៅកម្ពុជាធៀបនឹងប្រាក់ចំណូល កើនឡើង និងស្ថិតក្នុងចំណោមអត្រាខ្ពស់ជាងគេនៅអាស៊ីអាគ្នេយ៍**

| ប្រាក់បៀវត្សរ៍ (% នៃចំណាយ) | 2008 | 2013 | 2017* |
|---|---|---|---|
| ឡាវ | 37.8 | 60.5 | 50.0 |
| កម្ពុជា | 26.6 | 32.6 | 34.6 |
| ម៉ាឡេស៊ី | 25.7 | 28.6 | 34.4 |
| ហ្វីលីពីន | 31.9 | 34 | 32.9 |
| ថៃ | 32.0 | 26.9 | 27.1 |
| សិង្ហបុរី | 19.3 | 21.3 | 20.8 |
| ឥណ្ឌូនេស៊ី | 11.5 | 15.5 | 19.5 |

*ប្រភព* ៖ សូចនាករអភិវឌ្ឍន៍ពិភពលោក អាជ្ញាធរកម្ពុជា និងរបាយការណ៍បុគ្គលិករបស់ IMF កថាខណ្ឌ IV ឆ្នាំ 2018

*សម្គាល់* ៖ * ទិន្នន័យសម្រាប់ឆ្នាំ 2016 លើកលែងតែសម្រាប់កម្ពុជា និងឡាវ

**ការពង្រីកការវិនិយោគសាធារណៈតាមរយៈហិរញ្ញប្បទានក្នុងស្រុក អាចឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរកម្ពុជាក្នុងការប៉ះប៉ូវទៅលើការធ្លាក់ចុះបន្តិចម្តងៗ (ភាគរយនៃ ផសស) នៃចំណែកថវិកាដែលទទួលបានពីដៃគូអភិវឌ្ឍន៍** ព្រោះថា បច្ចុប្បន្នកម្ពុជាបានក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប។ ការចំណាយមូលធនសរុប (ហិរញ្ញប្បទានក្នុងស្រុក និងពីបរទេស) បានកើនដល់កម្រិតដែលបានផ្តល់យោបល់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ 2014-2018 រួចហើយ។ ក្រសួងអប់រំ យុវជន និងកីឡា ទទួលបានកំណើនចំណែកថវិកាច្រើនជាងគេនៅក្នុងថវិកាវិនិយោគមូលធនរបស់ខ្លួននៅឆ្នាំ 2018 ដើម្បីបំពេញតម្រូវការក្នុងការសាងសង់សាលារៀនបន្ថែមនៅតាមខេត្ត ដោយទទួលបានកញ្ចប់ថវិកា 420 ទ្រីលានរៀល (ឬ 0.5 ភាគរយនៃ ផសស) កើនពី 90 ទ្រីលានរៀលនៅឆ្នាំ 2017។

**ប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈកើនឡើងយ៉ាងឆាប់រហ័សនៅរយៈពេលប្រាំឆ្នាំចុងក្រោយ។** ការប្រៀបធៀបក្នុងតំបន់បង្ហាញថា ការចំណាយលើប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈរបស់កម្ពុជាធៀបនឹងចំណែកនៃចំណាយសាធារណៈ និងចំណូលក្នុងស្រុក កើនឡើង (តារាង 2 និង 3)។ ដូច្នេះ មានឱកាសតិចតួចក្នុងការបង្កើនប្រាក់បៀវត្សរ៍ប្រកបដោយនិរន្តរភាព។ ជាការសំខាន់ត្រូវពន្លឿនកិច្ចការសំខាន់ៗស្តីពីកំណែទម្រង់រដ្ឋបាលសាធារណៈ ដោយផ្តោតលើការគ្រប់គ្រងធនធានមនុស្ស ដើម្បីកែលម្អការផ្តល់សេវាសាធារណៈ។ ដោយសារតែវិស័យសាធារណៈគឺជាអ្នកផ្តល់សេវាកម្ម និងជាអ្នកសម្របសម្រួលសំខាន់ ចាំបាច់ត្រូវផ្សារភ្ជាប់កំណើនប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈទៅនឹងការកែលម្អការផ្តល់សេវាកម្ម។ ការកើនឡើងនៃផលិតភាពក្នុងវិស័យសាធារណៈជាការគាំទ្រដល់ការអភិវឌ្ឍវិស័យឯកជនក្នុងការជំរុញកំណើន និងកាត់បន្ថយភាពក្រីក្រ។

**រូប 26 ៖ ឱនភាពសារពើពន្ធទូទៅរបស់រដ្ឋាភិបាល កើនឡើងនៅឆ្នាំ 2018 ដោយសារការពង្រីកសារពើពន្ធ** (ភាគរយនៃ ផសស)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

*សម្គាល់* ៖ e=ការប៉ាន់ស្មាន b=ថវិកា

**រូប 27 ៖ ប្រាក់បញ្ញើរដ្ឋាភិបាលក្នុងប្រព័ន្ធធនាគារ**

(ភាគរយនៃ ផសស)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

**ឱនភាពសារពើពន្ធត្រូវបានកំណត់ឲ្យកើនឡើងដល់ 4.2 ភាគរយនៃ ផសស សម្រាប់កញ្ចប់ថវិកាឆ្នាំ 2018** ដោយកើនឡើងពី 1.6 ភាគរយនៅឆ្នាំ 2017 (រូប 26)។ ហិរញ្ញប្បទានខាងក្រៅប្រទេសត្រូវបានកំណត់ឲ្យមាន 3.7 ភាគរយនៃ ផសស នៃឱនភាពសារពើពន្ធ ផសស 4.2 ភាគរយ ខណៈដែលអត្រានៅសល់ 0.5 ភាគរយនៃ ផសស ត្រូវបានកំណត់ថាទទួលបានហិរញ្ញប្បទានពីមូលនិធិក្នុងស្រុក ដោយភាគច្រើនយកពីប្រាក់បញ្ញើរបស់រដ្ឋាភិបាលនៅធនាគារជាតិ។ យ៉ាងណាក៏ដោយ វិធានការការពារសារពើពន្ធរបស់អាជ្ញាធរកម្ពុជានៅតែមានច្រើន ដែលមានអត្រាប្រមាណ 13 ភាគរយនៃ ផសស គិតត្រឹមឆ្នាំ 2018 (រូប 27)។ នៅឆមាសទីមួយក្នុងឆ្នាំ 2018 ប្រាក់បញ្ញើរបស់រដ្ឋាភិបាលក្នុងប្រព័ន្ធធនាគារបន្តកើនឡើង មួយផ្នែកដោយសារតែដំណើរការប្រមូលប្រាក់ចំណូលបានល្អ[២១]។

**នៅឆ្នាំ 2017 កម្ពុជាមានបំណុលសាធារណៈ 977.63 លានដុល្លារក្នុងទម្រង់ជាកម្ចីសម្បទានពីដៃគូអភិវឌ្ឍន៍ (ស្មើនឹងសិទ្ធិដកប្រាក់ពិសេស (SDR) 684.71 លានដុល្លារ)** ដែលមានចំនួន 97.82 ភាគរយនៃកម្រិតកំណត់បំណុលចំនួនសិទ្ធិដកប្រាក់ពិសេស 700 លាន[22] ក្នុងនោះ 82.3 ភាគរយត្រូវបានចុះហត្ថលេខាជាមួយដៃគូអភិវឌ្ឍន៍ទ្វេភាគី រីឯបំណុលនៅសល់ត្រូវបានចុះហត្ថលេខាជាមួយដៃគូអភិវឌ្ឍន៍ពហុភាគី។ កម្ចីនេះមានគោលបំណងផ្តល់ហិរញ្ញប្បទានដល់គម្រោងវិនិយោគសាធារណៈ ដែលនៅឆ្នាំ 2017 មានអត្រា 100 ភាគរយនៃកម្ចីសរុប។ ជារួម កម្ចីនៅតែជាសម្បទានកម្រិតខ្ពស់ ដោយជំនួយឥតសំណងមានចំនួន 54.9 ភាគរយ។ ចាប់ពីឆ្នាំ 1993 រហូតដល់ចុងឆ្នាំ 2017 អាជ្ញាធរកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងកម្ចីសម្បទានក្នុងទំហំទឹកប្រាក់ 9.6 ពាន់លានដុល្លារជាមួយដៃគូអភិវឌ្ឍន៍ (87.8 ភាគរយសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ និង 12.2 ភាគរយសម្រាប់វិស័យអាទិភាពផ្សេងទៀត)។

**នៅចុងឆ្នាំ 2017 បំណុលសាធារណៈដែលមិនទាន់សងមានចំនួន 6.67 ពាន់លានដុល្លារ (30.2 ភាគរយនៃ ផសស)** ក្នុងនោះ 0.04 ភាគរយ (ឬ 2.77 លានដុល្លារ) ជាបំណុលសាធារណៈក្នុងស្រុក។

### ប្រទេសចិនគឺជាអ្នកផ្តល់ឥណទានធំជាងគេ ដែលមានចំណែកជិតពាក់កណ្តាលនៃបំណុលរបស់កម្ពុជាដែលមិនទាន់សង

**បំណុលពីក្រៅប្រទេសរបស់កម្ពុជាដែលជំពាក់ប្រទេសចិន ស្មើនឹង 48.4 ភាគរយនៃបំណុលសរុបគិតត្រឹមឆមាសទីមួយក្នុងឆ្នាំ 2018។** អ្នកផ្តល់ឥណទានធំទីពីរ និងទីបី គឺ ស្ថាប័នពហុភាគីដែលជា ធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក ដែលមានចំនួន 19.3 ភាគរយ និង 8.0 ភាគរយ នៃបំណុលសរុបដែលមិនទាន់សង ខណៈដែលបំណុលចាស់ (កំពុងចរចា) មានចំនួន 9.1 ភាគរយ។ កម្រិតបំណុលរបស់កម្ពុជានៅតែនៅទាបនៅឡើយ បើតាមការវិភាគអំពីនិរន្តរភាពបំណុលដោយធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ។

### ដោយសារដំណើរការនាំចេញដែលល្អជាងការរំពឹងទុក កំណើនការប្រើប្រាស់ និងសុទិដ្ឋិនិយមរបស់វិនិយោគិន ទស្សនវិស័យកំណើនត្រូវបានកែសម្រួលឡើងវិញ

**គាំទ្រដោយការនាំចេញ និងចំណាយរបស់រដ្ឋាភិបាល កំណើនសេដ្ឋកិច្ចរបស់កម្ពុជាត្រូវបានរំពឹងថានឹងកើនឡើងដល់ 7.1 ភាគរយនៅឆ្នាំ 2018** (ធៀបនឹងតួលេខកំណើនដែលត្រូវបានកែសម្រួលថ្មីជាផ្លូវការគឺ 7.0 ភាគរយនៅឆ្នាំ 2017)។ ដោយសារតែកំណើនសេដ្ឋកិច្ចឆ្នាំ 2018 ត្រូវបានជំរុញមួយផ្នែកដោយការពង្រីកសារពើពន្ធយ៉ាងច្រើន ទស្សនវិស័យកំណើនត្រូវបានព្យាករណ៍ថានឹងថយចុះបន្តិចនៅក្នុងរយៈពេលពីរឆ្នាំក្រោយ ប៉ុន្តែ នៅតែមានអត្រាល្អចំនួន 6.8 ភាគរយរហូតដល់ឆ្នាំ 2020។ ទស្សនៈវិស័យកំណើនរយៈពេលវែងមានភាពប្រសើរ សំខាន់ដោយសារតែការកើនឡើងនៃលំហូរការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យប្រកបដោយផលិតភាព ដូចជា កម្មន្តសាល និងកសិកម្ម រួមទាំងការកែច្នៃផលិតផលកសិកម្ម។ អាជ្ញាធរកម្ពុជាមានគំនិតផ្តួចផ្តើមថ្មីៗជាច្រើន ក្នុងការជំរុញសហគ្រាសខ្នាតតូច និងមធ្យម និងធុរកិច្ច ក៏ដូចជាជំរុញទំនាក់ទំនងជាមួយនឹងវិស័យវិនិយោគផ្ទាល់ពីបរទេស (សូមមើលប្រអប់ 2)។ ការកាត់បន្ថយភាពក្រីក្រត្រូវបានរំពឹងថានឹងបន្តកើតមាន តាមរយៈការពង្រីកវិស័យសេវាកម្ម និងវិស័យកម្មន្តសាល។

**ការកើនឡើងនៃលំហូរការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យកម្មន្តសាល រួមទាំង ការកែច្នៃផលិតផលកសិកម្ម ត្រូវបានលើកទឹកចិត្ត។** ក្នុងស្ថានភាពនេះ គន្លងកំណើនសេដ្ឋកិច្ចរបស់កម្ពុជាត្រូវបានរំពឹងថានឹងប្រសើរឡើង ជាពិសេសសម្រាប់ទស្សនវិស័យរយៈពេលខ្លី និងរយៈពេលមធ្យម បើធៀបនឹងការព្យាករនាពេលកន្លងមក (តារាង 4)។ កិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរកម្ពុជាក្នុងការបង្កើនលទ្ធភាពទទួលបានការអប់រំមូលដ្ឋាន ដែលមានគុណភាព រួមទាំង គំនិតផ្តួចផ្តើមនៅសាលារៀនថ្មី អាចធ្វើឲ្យលទ្ធផលសិក្សាល្អប្រសើរ និងមានកម្លាំងពលកម្មដែលមានគុណភាពក្នុងរយៈពេលមធ្យម និងរយៈពេលវែង។ គំនិតផ្តួចផ្តើមផ្សេងៗនៅក្នុងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់រដ្ឋបាលសាធារណៈ ត្រូវបានរៀបចំឡើងក្នុងគោលបំណងបង្កើនប្រសិទ្ធភាពនៃការចំណាយថវិកា និងការផ្តល់សេវាសាធារណៈ ដែលសម្រួលដល់កំណើនវិស័យឯកជន។

២១ នៅខែ មិថុនា ឆ្នាំ 2018 ប្រាក់បញ្ញើរបស់រដ្ឋាភិបាលប្រមាណ 31 ភាគរយនៅធនាគារជាតិកម្ពុជាគឺជាប្រាក់ដុល្លាអាមេរិក។

២២ "ព្រឹត្តិប័ត្រស្ថិតិស្តីពីបំណុលសាធារណៈរបស់កម្ពុជា" លេខ 5 ខែ មីនា ឆ្នាំ 2018 និងលេខ 6 ខែ កញ្ញា ឆ្នាំ 2018 ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**តារាង 4 ៖ ការកែលម្អទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចក្នុងរយៈពេលខ្លី និងមធ្យម**

| ភាគរយនៃ ផសស លើកលែងតែមានការបញ្ជាក់ខុសពីនេះ | 2018 | 2019 | 2020 |
|---|---|---|---|
| **កំណើន ផសស** (%) | 7.1 | 6.8 | 6.8 |
| **តម្រូវការក្នុងស្រុក** (ការប្រែប្រួលភាគរយធៀបនឹងឆ្នាំមុន) | 9.4 | 9.7 | 10.1 |
| **អតិផរណា** (ការប្រែប្រួលភាគរយធៀបនឹងឆ្នាំមុន) | 3.2 | 3.3 | 3.0 |
| **តុល្យភាពសារពើពន្ធរួម** | -4.2 | -4.2 | -4.3 |
| **បំណុលរដ្ឋាភិបាល** | 36 | 37 | 38 |
| **កំណើនការនាំចេញ** (ការប្រែប្រួលភាគរយ) | 14.9 | 13.6 | 12.7 |
| **កំណើនការនាំចូល** (ការប្រែប្រួលភាគរយ) | 14.6 | 12.0 | 10.3 |
| **គណនីចរន្ត** | -10.3 | -10.2 | -9.9 |
| **ការវិនិយោគផ្ទាល់ពីបរទេស** | 10.9 | 10.6 | 10.4 |
| **ប្រាក់បម្រុងអន្តរជាតិដុល** (ចំនួនខែនៃការនាំចូល) | 5.9 | 6.0 | 6.0 |

*ប្រភព* ៖ ការប៉ាន់ស្មាន និងការព្យាកររបស់បុគ្គលិកធនាគារពិភពលោក

**បើទោះជាកំណើនលំហូរការវិនិយោគផ្ទាល់ពីបរទេសកន្លងមកបានជួយជំរុញការវិនិយោគ ការរក្សាអត្រាវិនិយោគខ្ពស់ក្នុងរយៈពេលវែង អាចសម្រេចទៅបានតែក្នុងករណីមានអត្រាប្រាក់សន្សំក្នុងស្រុកខ្ពស់ប៉ុណ្ណោះ។** Feldstein និង Horioka យល់ឃើញថា ភាពខុសគ្នាជាអន្តរជាតិនៃអត្រាប្រាក់សន្សំក្នុងស្រុកនៅក្នុងចំណោមប្រទេសមានជាងគេលើសកលលោក ធ្វើឲ្យមានភាពខុសគ្នានៃអត្រាការវិនិយោគក្នុងស្រុកដែរ[២៣]។ នៅពេលកម្ពុជាខិតខំឲ្យក្លាយទៅជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅក្នុងរយៈពេលរង្វង់បួនទសវត្សរ៍ទៀតនោះ កម្ពុជានឹងត្រូវរក្សាអត្រាវិនិយោគខ្ពស់ជាងកម្រិតបច្ចុប្បន្ននេះ។ កម្ពុជាមានអត្រាប្រាក់សន្សំទាប និងពឹងផ្អែកខ្លាំងលើប្រាក់សន្សំពីបរទេសតាមរយៈការវិនិយោគផ្ទាល់ពីបរទេស។ ដូច្នេះ ការបង្កើនអត្រាវិនិយោគប្រហែលជាមិនអាចធ្វើទៅបានឡើយ។ លំនាំដែលបង្ហាញក្នុងផ្នែកអត្ថបទជម្រើសបង្ហាញថា កម្ពុជានឹងត្រូវបង្កើនអត្រាវិនិយោគឲ្យបាន 28.5 ភាគរយនៃ ផសស (ធៀបនឹងអត្រាបច្ចុប្បន្ន 20 ភាគរយនៃ ផសស) ត្រឹមឆ្នាំ 2030 ដែលប្រហាក់ប្រហែលគ្នានឹងគន្លងរបស់ម៉ាឡេស៊ី ដើម្បីសម្រេចបានចំណាត់ថ្នាក់ជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ 2035 និងប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ 2050។

**ជាការសំខាន់ត្រូវត្រៀមខ្លួនសម្រាប់ការចាកចេញពីចំណាត់ថ្នាក់ជាប្រទេសដែលមានការអភិវឌ្ឍតិចតួចបំផុត និងការបាត់បង់ការអនុគ្រោះពន្ធពាណិជ្ជកម្ម និងការទទួលបានឥណទានសម្បទានកាន់តែតិចក្នុងរយៈពេលមួយទសវត្សរ៍ទៀត។** បច្ចុប្បន្នកម្ពុជាកំពុងទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធនៃការអនុគ្រោះពន្ធនាំចូលទៅទីផ្សារសហភាពអឺរ៉ុបសម្រាប់រាល់ផលិតផលគ្រប់បែបយ៉ាង លើកលែងតែអាវុធ ដែលមានឈ្មោះថា EBA និងទទួលបានប្រព័ន្ធអនុគ្រោះទូទៅរបស់សហរដ្ឋអាមេរិក ដែលលុបពន្ធនាំចូលរបស់អាមេរិកលើផលិតផលធ្វើដំណើរ (Travel Goods) ដែលធ្វើដោយកម្ពុជា ដូចជា ការបូបដាក់ឥវ៉ាន់អ្នកដំណើរ កាបូបស្ពាយ កាបូបដៃ និងកាបូបលុយ។ នៅពេលដែលកម្ពុជាលែងទទួលបានការអនុគ្រោះពន្ធពាណិជ្ជកម្មនៅទីផ្សារសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិកក្នុងរយៈពេលមួយទសវត្សរ៍ទៀត កម្ពុជានឹងលែងសូវមានភាពទាក់ទាញចំពោះការវិនិយោគផ្ទាល់ពីបរទេស ក៏ដូចជាមានលទ្ធភាពតិចជាងមុនក្នុងការទទួលបានកម្ចីសម្បទាន។ ក្នុងស្ថានភាពនេះ អាជ្ញាធរកម្ពុជាត្រូវចាប់ផ្តើមចាត់វិធានការដើម្បីអនុលោមតាមលក្ខខណ្ឌ និងអនុសញ្ញានានា ដើម្បីបន្តទទួលបានការអនុគ្រោះពន្ធសម្រាប់ទីផ្សារសហភាពអឺរ៉ុប តាមរយៈប្រព័ន្ធអនុគ្រោះពន្ធថ្មីឈ្មោះថា GSP+ (ដែលមានលក្ខខណ្ឌល្អជាងការគ្មានកិច្ចព្រមព្រៀង)។

## មានហានិភ័យកាន់តែច្រើនដោយសារតែឥណទានក្នុងស្រុកបន្តហូរចូលទៅលើវិស័យសំណង់ និងអចលនទ្រព្យ

**ស្ថានភាពនេះ រួមជាមួយនឹងអត្រាប្រាក់សន្សំក្នុងស្រុកទាបបានធ្វើឲ្យវិស័យហិរញ្ញវត្ថុងាយរងគ្រោះ។** ថ្មីៗនេះ កំណើនសកម្មភាពវិស័យអចលនទ្រព្យ ធ្វើឲ្យមានសកម្មភាពទិញ/លក់ប្រថុយប្រថាន ដោយមានការទិញនិងលក់ដីនៅជាយក្រុង និងក្នុងបណ្តាខេត្តជុំវិញ ដែលផលចំណេញនៃការវិនិយោគនេះមិនច្បាស់លាស់ ឬមិនសមស្រប។ យ៉ាងណាក៏ដោយ ការកើនឡើងនៃលំហូរការវិនិយោគផ្ទាល់ពីបរទេស បានបិទបាំងភាពងាយរងគ្រោះរបស់វិស័យហិរញ្ញវត្ថុដោយសារតែកំណើនឥណទានលឿនក្នុងរយៈពេលវែង។

**នៅផ្នែកក្រៅប្រទេស ហានិភ័យពាក់ព័ន្ធនឹងលទ្ធភាពព្យួរការអនុគ្រោះពន្ធ EBA ជាបណ្តោះអាសន្នពីកម្ពុជា។** ទីផ្សារសហភាពអឺរ៉ុបមានចំណែកជាង 1 ភាគ 3 នៃការនាំចេញសំខាន់ៗរបស់កម្ពុជា គឺ សម្លៀកបំពាក់ និងស្បែកជើង។ ដូច្នេះ ការបាត់បង់ការអនុគ្រោះពន្ធ EBA នឹងធ្វើឲ្យចំណែកទីផ្សារនាំចេញរបស់កម្ពុជារួមតូច និងមានផលអវិជ្ជមានលើកំណើនពិត ប្រសិនបើការដកប្រព័ន្ធអនុគ្រោះនេះចូលជាធរមានក្នុងរយៈពេល 12 ខែទៀត[២៤]។

---

២៣ ប្រាក់សន្សំក្នុងស្រុក និងលំហូរមូលធនអន្តរជាតិ ដោយ Feldstein និង Horioka (ឯកសាររបស់ NBERK លេខ 310 ខែ មករា ឆ្នាំ 1979។

២៤ ព័ត៌មានផ្សព្វផ្សាយ ថ្ងៃទី 7 ខែ តុលា ឆ្នាំ 2018 គណៈប្រតិភូសហភាពអឺរ៉ុបក្នុងដំណើរទស្សនៈកិច្ចនៅកម្ពុជា។

**បច្ចុប្បន្ននេះ គ្មានការសិក្សាណាមួយស្តីពីផលប៉ះពាល់នៃការដកប្រព័ន្ធអនុគ្រោះពន្ធនេះជាបណ្តោះអាសន្នឡើយ។** ប្រសិនបើគ្មាន EBA ការនាំចេញភាគច្រើនរបស់កម្ពុជាទៅកាន់ទីផ្សារអឺរ៉ុបនឹងត្រូវជាប់ពន្ធគយចំនួន 12 ភាគរយ។

## ឥទ្ធិពលដែលអាចកើតមានពីជម្លោះពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក និងប្រទេសចិនលើសេដ្ឋកិច្ចកម្ពុជា

**ឥទ្ធិពលនៃជម្លោះពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក និងប្រទេសចិន អាចវិជ្ជមាន និងអវិជ្ជមានដល់ប្រទេសផ្សេងៗទៀត រួមទាំងកម្ពុជាផង។** ជាចំណុចវិជ្ជមាន ការកំណត់ពន្ធនាំចូលខ្ពស់ជាងមុនលើពាណិជ្ជកម្មទ្វេភាគីរវាងសហរដ្ឋអាមេរិក និងប្រទេសចិន អាចផ្តល់ឱកាសឲ្យប្រទេសផ្សេងៗទៀតបង្កើនការនាំចេញទៅទីផ្សារអាមេរិក។ ប្រទេសដែលអាចបង្កើនការនាំចេញរបស់ខ្លួនទៅសហរដ្ឋអាមេរិក គឺប្រទេសដែលជាគូប្រកួតប្រជែងការនាំចេញរបស់ប្រទេសចិននៅសហរដ្ឋអាមេរិក និងអាចទាញប្រយោជន៍ពីចំណេះដឹងរបស់ខ្លួនពីដំណើរការពាណិជ្ជកម្ម និងទំនាក់ទំនងអាជីវកម្មបច្ចុប្បន្នជាមួយសហរដ្ឋអាមេរិក។

**មានសញ្ញាបង្ហាញថា ជម្លោះពាណិជ្ជកម្មទាំងនេះអាចធ្វើឲ្យមានការផ្លាស់ទីតាំងក្រុមហ៊ុនចេញពីប្រទេសចិន ហើយកម្ពុជាទទួលបានកំណើនលំហូរការវិនិយោគផ្ទាល់ពីប្រទេសចិនក្នុងវិស័យកាត់ដេរ ស្បែកជើង និងទំនិញធ្វើដំណើរ។** ផលប៉ះពាល់អវិជ្ជមាននៃជម្លោះពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក និងប្រទេសចិន នឹងមានដល់ប្រទេសផ្សេងៗទៀតតាមរយៈសង្វាក់ផ្គត់ផ្គង់ក្នុងតំបន់។ លើសពីនេះទៀត ការបង្កើនពន្ធនាំចូលរបស់សហរដ្ឋអាមេរិកនឹងបង្កើនតម្លៃទំនិញពីប្រទេសចិននៅសហរដ្ឋអាមេរិក និងធ្វើឲ្យតម្រូវការផលិតផលចិនធ្លាក់ចុះ។ ផលប៉ះពាល់នេះនឹងស្តែងចេញតាមរយៈសង្វាក់តម្លៃក្នុងតំបន់ ដែលធ្វើឲ្យមានការថយចុះតម្រូវការទំនិញនាំចេញពីប្រទេសកំពុងអភិវឌ្ឍន៍ដែលជាធនធានសម្រាប់ការនាំចេញរបស់ប្រទេសចិនទៅកាន់សហរដ្ឋអាមេរិក។ ប៉ុន្តែ កម្ពុជាហាក់ទទួលរងផលប៉ះពាល់តិចតួចពីភាពតានតឹងនេះ ព្រោះថា ការនាំចេញរបស់កម្ពុជាទៅកាន់ប្រទេសចិន ដែលរួមទាំងផលិតផលសម្រេច និងផលិតផលពាក់កណ្តាលសម្រេច មានត្រឹមតែ 9 ភាគរយនៃការនាំចេញសរុបរបស់ខ្លួនប៉ុណ្ណោះ[២៥]។

**ឥទ្ធិពលអវិជ្ជមានខ្លាំងដែលអាចកើតឡើងតាមរយៈពាណិជ្ជកម្មក្នុងវិស័យសេវាកម្ម ជាពិសេសវិស័យទេសចរណ៍ និងលំហូរហិរញ្ញវត្ថុក្នុងទម្រង់ជាការវិនិយោគផ្ទាល់ពីបរទេស។** វិស័យទេសចរណ៍ ជាពិសេសប្រាក់ចំណូលពីភ្ញៀវទេសចរចិន បានក្លាយជា ប្រភពចំណូលសំខាន់ៗមួយនៃរូបិយវត្ថុបរទេសរបស់កម្ពុជា។ នៅពេលដកកំណើនចំណែកភ្ញៀវទេសចរចិនចេញ ចំនួនភ្ញៀវទេសចរមកកាន់កម្ពុជាបានថយចុះនាពេលថ្មីៗនេះ។ ដូចគ្នានេះដែរ បើដកកំណើនលំហូរការវិនិយោគផ្ទាល់ពីប្រទេសចិនចេញ ការវិនិយោគផ្ទាល់ពីបរទេសថយចុះដែរ។

## ការគាំពារសុខភាពនៃវិស័យហិរញ្ញវត្ថុគឺជាអាទិភាពខ្ពស់បំផុត

**ដោយសារតែកំណើនរយៈពេលយូរក្នុងវិស័យសំណង់ អាទិភាពខ្ពស់បំផុតសម្រាប់អាជ្ញាធរកម្ពុជាគឺការគាំពារសុខភាពនៃវិស័យហិរញ្ញវត្ថុក្នុងរយៈពេលខ្លីខាងមុខ។** ថ្មីៗនេះ វិស័យអចលនទ្រព្យបានក្លាយជាសកម្មភាពទិញ/លក់ប្រថុយប្រថាន ដែលជាការទិញ/លក់ដីដោយលទ្ធភាពចំណេញនៃការវិនិយោគនេះ មិនច្បាស់លាស់ ឬមិនសមស្រប។ ការកើនឡើងនៃលំហូរការវិនិយោគផ្ទាល់ពីបរទេសបានបិទបាំងភាពងាយរងគ្រោះរបស់វិស័យហិរញ្ញវត្ថុ ដែលបង្កឡើងដោយកំណើនឥណទានលឿនក្នុងរយៈពេលវែង។ ដូច្នេះ ចាំបាច់ត្រូវតាក់តែងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចបង្ការ រួមទាំង វិធានការហិរញ្ញវត្ថុ និងសារពើពន្ធ ដើម្បីកាត់បន្ថយវិសាលភាពនៃសកម្មភាពទិញ/លក់ប្រថុយប្រថាន ដែលផ្តល់ហិរញ្ញប្បទានដោយវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ (សូមមើលប្រអប់ 3)។ សំខាន់បំផុត ត្រូវបង្កើតគោលការណ៍ណែនាំស្តីពីប្រាក់កម្ចី រួមទាំង ការកំណត់ពីផលធៀបតម្លៃ និងឥណទាន ក៏ដូចជាការកំណត់ពន្ធបន្ថែមលើការទិញ/លក់អចលនទ្រព្យ ជាពិសេសដីធ្លី ដែលជាការវិនិយោគ (ប្រថុយប្រថាន)។ ដូចគ្នានេះដែរ ត្រូវពិនិត្យលើចំណាត់ថ្នាក់ឥណទានមិនដំណើរការ។ លើសពីនេះទៀត ត្រូវពិចារណាទៅលើវិធានការបង្ការផ្សេងទៀត ដូចជា ផលធៀបឥណទាន និងប្រាក់ចំណូល ជួយបង្កើនការបង់ប្រាក់ដំបូង ក៏ដូចជាកត្តាផ្សេងៗទៀតដែរ។

**ការដោះស្រាយបញ្ហាខ្វះខាតហេដ្ឋារចនាសម្ព័ន្ធ គឺជាការចាំបាច់ ដើម្បីស្រូបយកកំណើនលំហូរការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យកម្មន្តសាល និងការកែច្នៃផលិតផលកសិកម្ម។** បើទោះជាមានភាពប្រសើរជាងមុនក្តី ត្រូវមានការវិនិយោគបន្ថែមលើការកែលម្អ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដើម្បីអាចឲ្យកម្ពុជា ធ្វើសមាហរណកម្មកាន់តែប្រសើរទៅក្នុងសង្វាក់តម្លៃតំបន់ (និងសកល)។ នេះគឺជាការទាញប្រយោជន៍ពីទីតាំងយុទ្ធសាស្ត្ររបស់កម្ពុជា ដែលជាចំណុចស្នូលរបស់អាស៊ាន តាមរយៈការសម្របសម្រួល និងការបន្តជំរុញការវិនិយោគសម្រាប់ពិពិធកម្មនាំចេញ (សូមមើលប្រអប់ 2)។ ដើម្បីសម្រួលដល់ការពង្រីកពាណិជ្ជកម្ម ការភ្ជាប់ទំនាក់ទំនង ដូចជា ទំនើបកម្មមធ្យោបាយដឹកជញ្ជូន និងឡូជីស្ទីក ត្រូវបានកំណត់ជាចំណុចសំខាន់នៅក្នុងការរៀបចំផែនការជាតិស្តីពីឡូជីស្ទីក និងការបង្កើតក្រុមប្រឹក្សាជាតិសម្រាប់ឡូជីស្ទីក។ ពាក់ព័ន្ធនឹងសមត្ថភាពផ្នែកឡូជីស្ទីក កម្ពុជាឈរលំដាប់ទី 98 ក្នុងចំណោមប្រទេស 160 នៅក្នុងសន្ទស្សន៍ស្តីពីប្រតិបត្តិការឡូជីស្ទីកឆ្នាំ 2018 ដោយថយពីលំដាប់ទី 73 នៅឆ្នាំ

---

២៥ https://www.adb.org/publications/key-indicators-asia-and-pacific-2018.

2016។ ប្រទេសនាំចេញគ្រឿងអេឡិចត្រូនិកសំខាន់ៗ ដូចជា ម៉ាឡេស៊ី និងថៃ ឈរនៅលំដាប់កំពូល 40។ ក្រៅពីនេះ ការបង្កើនជំនាញកម្លាំងពលកម្មក្នុងរយៈពេលខ្លី និងរយៈពេលមធ្យម ក៏ជាចំណុចសំខាន់ផងដែរ[២៦]។

### កម្ពុជាត្រូវការការជំរុញការវិនិយោគបន្ថែមទៀតច្រើន ដើម្បីសម្រេចបានគោលដៅក្នុងការក្លាយជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់

**ការប្រមូលការប្រាក់សន្សំក្នុងស្រុកគឺជាចាំបាច់ក្នុងការជំរុញការវិនិយោគក្នុងរយៈពេលមធ្យម និងរយៈពេលវែង។** ដូចពិភាក្សានៅក្នុងអត្ថបទជម្រើសខាងក្រោម ដែលមានចំណងជើងថា "តើកម្ពុជាអាចក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ 2030 និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ 2050 ឬទេ?" អត្រាប្រាក់សន្សំក្នុងស្រុកដុលរបស់កម្ពុជាដែលទាបជាង 20 ភាគរយនៃ ផសស ស្ថិតក្នុងអត្រាទាបបំផុតក្នុងតំបន់។ កម្ពុជាពឹងផ្អែកយ៉ាងខ្លាំងលើប្រាក់សន្សំពីបរទេសក្នុងទម្រង់ជាការវិនិយោគផ្ទាល់ពីបរទេស ដែលមិនត្រឹមតែប្រែប្រួលប៉ុណ្ណោះទេ ថែមទាំងគ្មាននិរន្តរភាពក្នុងរយៈពេលវែងផង។ ដូច្នេះ ចាំបាច់ត្រូវចាប់ផ្តើមបង្កើតធនធានបន្ថែមក្នុងស្រុកដើម្បីផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគដែលមានផលិតភាព ដោយសារកម្ពុជាខិតខំប្រឹងប្រែងឲ្យក្លាយជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ក្នុងរយៈពេលប្រមាណបួនទសវត្សរ៍ទៀត។ ការបង្កើនការវិនិយោគគឺជាការចាំបាច់ក្នុងការជំរុញឲ្យកម្ពុជាក្លាយជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់តាមការរំពឹងទុក។ ក្នុងស្ថានភាពនេះ ការប្រមូលប្រាក់សន្សំគឺជាបុរេលក្ខខណ្ឌមួយ ហើយការអភិវឌ្ឍទីផ្សារមូលធន រួមទាំង ប្រព័ន្ធប្រាក់សោធន ក៏ជាការចាំបាច់ដែរ។ ដូច្នេះ ត្រូវមានវិធានការគោលនយោបាយគាំទ្រការសន្សំប្រាក់ ដើម្បីលើកទឹកចិត្តឲ្យគ្រួសារសន្សំប្រាក់ និងផ្តល់ការលើកទឹកចិត្តដល់អាជីវកម្មដែលបន្តធ្វើការវិនិយោគផ្សេងទៀត (សូមមើលប្រអប់ S2)។ ការអភិវឌ្ឍប្រព័ន្ធអេកូហិរញ្ញវត្ថុ ដើម្បីបង្កើតទំនុកចិត្តលើវិស័យហិរញ្ញវត្ថុ រួមទាំង ការពង្រឹងក្របខណ្ឌនិយ័តកម្ម និងត្រួតពិនិត្យ ការកែលម្អប្រព័ន្ធរាយការណ៍ហិរញ្ញវត្ថុ អភិបាលកិច្ចសាជីវកម្មល្អ និងការបង្កើតប្រព័ន្ធការពារហិរញ្ញវត្ថុ នឹងជួយជំរុញការសន្សំប្រាក់បន្ថែមទៀត។




២៦ សម្រាប់ការវិភាគលម្អិត សូមមើលអត្ថបទជម្រើស "ខ្លឹមសារសង្ខេបនៃរបកគំហើញស្តីពីការងារនាពេលអនាគតនៅកម្ពុជា" ខែ មេសា ឆ្នាំ 2018 "បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា"។





## ផ្នែកទី 2

# តើកម្ពុជាអាចក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ 2030 និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ 2050 ដែរឬទេ?

# ផ្នែកទី 2 ៖ អត្ថបទជម្រើស ៖
## តើកម្ពុជាអាចក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ 2030 និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ 2050 ដែរឬទេ?[២៧]

### I. សេចក្តីផ្តើម

**ក្រោយពីមានការបន្តកំណើនសេដ្ឋកិច្ចលឿនក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមក កម្ពុជាទទួលបានចំណាត់ថ្នាក់ជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាបនៅឆ្នាំ 2015។** កម្ពុជាមានប្រជាជនសរុបចំនួន 16.1 លាននាក់ ហើយប្រាក់ចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ ត្រូវបានប៉ាន់ស្មានថាមានចំនួន 1,230 ដុល្លារនៅឆ្នាំ 2017។ តួលេខប៉ាន់ស្មានផ្លូវការបង្ហាញថា ភាគរយប្រជាជនកម្ពុជាដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រជាតិ បានថយចុះពី 47.8 ភាគរយនៅឆ្នាំ 2007 មកត្រឹម 13.5 ភាគរយនៅឆ្នាំ 2014។ កំណើន ផសស ពិត ត្រូវបានព្យាករណ៍ថាកើនឡើងដល់ 7.1 ភាគរយនៅឆ្នាំ 2018 និងរំពឹងថា មានកំណើនរឹងមាំក្នុងរយៈពេលមធ្យមខាងមុខ។

**ខុសពីប្រទេសដែលមានមនុស្សចាស់ច្រើនក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក កម្ពុជាកំពុងទទួលបានអត្ថប្រយោជន៍ពីភាគលាភប្រជាសាស្ត្រ។** ប្រជាជនគ្រប់អាយុធ្វើការនៅកម្ពុជា (15-64 ឆ្នាំ) កំពុងកើនឡើងលឿនជាងអត្រាកំណើនប្រជាជន ដោយកើនឡើងក្នុងអត្រា 2.3 ភាគរយធៀបនឹង 1.56 ភាគរយនៅអំឡុងឆ្នាំ 2007 និង 2015។ កំណើននេះបានផ្តល់ធនធានមនុស្សយ៉ាងច្រើនសម្រាប់ការវិនិយោគ និងកំណើនប្រាក់ចំណូលគ្រួសារ[២៨]។ ផ្អែកលើភាពសកម្មនៃប្រជាជនបច្ចុប្បន្ននេះ កម្ពុជាមានឱកាសសម្រេចបានកំណើនសេដ្ឋកិច្ចលឿននៅក្នុងរយៈពេល 30 ឆ្នាំក្រោយ រហូតដល់ពេលប្រជាជនគ្រប់អាយុធ្វើការនៅកម្ពុជាចាប់ផ្តើមថយចុះ។

**ទីតាំងជាយុទ្ធសាស្ត្ររបស់កម្ពុជានៅចំកណ្តាលអាស៊ាន រួមនឹងគោលនយោបាយពាណិជ្ជកម្មសេរី និងការវិនិយោគ បានទាក់ទាញលំហូរការវិនិយោគពីបរទេសយ៉ាងច្រើន។** លំហូរសរុបនៃការវិនិយោគផ្ទាល់ពីបរទេសមានចំនួន 10 ភាគរយនៃ ផសស នៅក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ហើយស្ថិតក្នុងចំណោមប្រទេសលំដាប់ខ្ពស់ទាំង 20 ក្នុងពិភពលោក។ កម្ពុជាឈរនៅលំដាប់ឈានមុខគេនៅអាស៊ី (នាំមុខសិង្ហបុរី និងវៀតណាម ដែលឈរនៅលំដាប់ទីពីរ និងទីបី) និងឈរនៅលំដាប់ទី ៣ ក្នុងសន្ទស្សន៍ស្តីពីប្រតិបត្តិការការវិនិយោគផ្ទាល់ពីបរទេសរបស់ Greenfield នៅឆ្នាំ 2017[២៩]។ ទិន្នន័យរបស់ Euromonitor International បង្ហាញថា កម្ពុជាត្រូវបានកំណត់ជាប្រទេសមួយក្នុងចំណោមទីផ្សារទាំង 20 នៅថ្ងៃអនាគត ដែលផ្តល់ឱកាសល្អសម្រាប់ ក្រុមហ៊ុនអន្តរជាតិមកវិនិយោគ[៣០]។

**របាយការណ៍របស់ក្រុមប្រឹក្សាពាណិជ្ជកម្ម និងធុរកិច្ច របស់ប្រទេសស៊ុយអែត បង្ហាញថា ជាមួយនឹងប្រទេសមីយ៉ាន់ម៉ា និងឡាវ កម្ពុជាត្រូវបានកំណត់ថាស្ថិតក្នុងចំណោម "ទីផ្សារឈានមុខនៅអាស៊ីអាគ្នេយ៍"[៣១]។** "ទីផ្សារឈានមុខ" ឬទីផ្សារដែលបម្រុងនឹងងើបឡើង គឺជាប្រទេសកំពុងអភិវឌ្ឍន៍ដែលមានសក្តានុពលខ្ពស់សម្រាប់ការវិនិយោគ ដែលមានឱកាសជាច្រើន រួមមានអត្រាកំណើនខ្ពស់ ថ្លៃពលកម្មទាប និងទីផ្សារអ្នកប្រើប្រាស់រីកធំឡើង ប៉ុន្តែ ត្រូវមានការងាររយៈពេលវែង និងការអភិវឌ្ឍវិស័យសំណង់ និងហេដ្ឋារចនាសម្ព័ន្ធយ៉ាងច្រើន និងមានបញ្ហាប្រឈមក្នុងការធ្វើធុរកិច្ច។

**កម្ពុជាមានគោលដៅក្លាយទៅជាប្រទេស ដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ 2030 និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ 2050[៣២]។** អត្ថបទជម្រើសនេះត្រូវបានរៀបចំឡើងដោយប្រើប្រាស់លំនាំកំណើនរយៈពេលវែងរបស់ធនាគារពិភពលោក (LTGM) ដើម្បីបង្ហាញពីសក្តានុពលកំណើនរបស់កម្ពុជាក្នុងរយៈពេល 33 ខាងមុខ (Loayza និង Pennings 2018)[៣៣]។ អត្ថបទនេះពិភាក្សាអំពីឱកាស និងបញ្ហាប្រឈមផ្សេងៗ ប្រសិន បើកម្ពុជាក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ 2030 និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ 2050 រួមទាំង ចំណុចដែលត្រូវកែលម្អ និងអ្វីដែលត្រូវបង្កើតឲ្យមាន។ ក្រៅពីនេះ ក៏មានការប្រៀបធៀបក្នុងតំបន់ ដើម្បីវាយតម្លៃអំពីសន្ទុះកំណើនប្រាក់

---

២៧ ឯកសារនេះត្រូវបានរៀបរៀងដោយ Steven Pennings និង Jorge Guzman ដោយមានយោបល់ពីលោក លី សូដេត និងលោក ភឹម រុនស៊ីណារិទ្ធ។
២៨ ការគណនារបស់បុគ្គលិកធនាគារពិភពលោកផ្អែកលើទិន្នន័យ WDI។
២៩ https://www.fdiintelligence.com.
៣០ http://www.euromonitor.com/markets-of-the-future-in-cambodia/report; https://www.fundhive.com/Invest_in_Cambodia_ebook.pdf.
៣១ https://www.business-sweden.se/contentassets/4ecbc372953f4ed4be227d97c758cd73/frontier-sea-markets-pov---final-report.pdf.
៣២ សូមមើលយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី 4 របស់រាជរដ្ឋាភិបាលកម្ពុជា ខែ កញ្ញា ឆ្នាំ 2018 ទំព័រ 44។
៣៣ រៀបរៀងឡើងដោយ Steven Pennings, Leonardo Garrido និង Jorge Luis Guzman។ សូមមើល http://www.worldbank. org/LTGM។ លំនាំកំណើនផ្អែកលើស្នាដៃរបស់ Hevia និង Loayza 92012។

ចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ៗដែលកម្ពុជាអាចសម្រេចបានដោយសមស្រប។

**អត្ថបទជម្រើសនេះត្រូវបានរៀបចំឡើងដូចតទៅ។** ផ្នែកទី 2 ផ្តល់សាវតារព័ត៌មានស្តីពីសេដ្ឋកិច្ច ដោយផ្តោតលើការផ្លាស់ប្តូររចនាសម្ព័ន្ធ។ ផ្នែកទី 3 ប្រើប្រាស់លំនាំកំណើននេះ ដើម្បីពិនិត្យមើលការសម្រេចបានប្រាក់ចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់របស់កម្ពុជា (វិធីសាស្ត្រ Atlas)។ ផ្នែកទី 4 ផ្តល់ជាជម្រើសផ្នែកគោលនយោបាយសំខាន់ៗ។

## II. ការផ្លាស់ប្តូររចនាសម្ព័ន្ធ

### 1. កំណើនខ្លាំង ដែលជំរុញដោយវិស័យកសិកម្ម កាត់ដេរ ទេសចរណ៍ និងថ្មីៗនេះ វិស័យសំណង់កំពុងជំរុញការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចយ៉ាងលឿន

**កម្ពុជាជាប់លំដាប់ទី 6 ក្នុងចំណោមប្រទេសដែលមានកំណើនសេដ្ឋកិច្ចក្នុងពិភពលោកនៅអំឡុងឆ្នាំ 1994 និង 2015 ដោយមានអត្រាកំណើនជាមធ្យម 7.6 ភាគរយ និងមានការផ្លាស់ប្តូររចនាសម្ព័ន្ធយ៉ាងលឿន។** ប្រាក់ចំណូលជាតិដុលសម្រាប់មនុស្សម្នាក់កើនឡើងក្នុងអត្រា 5.4 ភាគរយនៅអំឡុងឆ្នាំ 1996 និង 2015 ដែលជាឆ្នាំកម្ពុជាបានក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប។ នៅអំឡុងពេលនេះ សេដ្ឋកិច្ចកម្ពុជាមានការផ្លាស់ប្តូររចនាសម្ព័ន្ធយ៉ាងច្រើន។ ចំណែកនៃវិស័យកសិកម្មនៃ ផសស បានថយចុះពី 45.3 ភាគរយនៅឆ្នាំ 1993 មកត្រឹម 23.4 ភាគរយនៅឆ្នាំ 2017 (រូប S1)។ ការងារក្នុងវិស័យកសិកម្មធៀបនឹងអត្រាការងារសរុប បានថយចុះមកត្រឹម 36.4 ភាគរយនៅឆ្នាំ 2016 ដោយថយចុះពី 58.3 ភាគរយនៅឆ្នាំ 2004។ ការថយចុះអត្រាការងារក្នុងវិស័យកសិកម្មត្រូវបានប៉ះប៉ូវដោយកំណើនការងារក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម ដែលនាំឲ្យមានការបង្កើតការងារ និងការស្រូបកម្លាំងពលកម្មថ្មីៗក្នុងទីផ្សារការងារធៀបនឹងកំណើនប្រជាជន (រូប S2)។

### 2. មូលធនដុលនៅតែមានកម្រិតទាប ដោយខ្វះលទ្ធភាពក្នុងការប្រមូលប្រាក់សន្សំក្នុងស្រុក

**ចំនួនមូលធនថេរដុលរបស់កម្ពុជាធៀបនឹងភាគរយ ផសស គឺតិចជាង 20 ភាគរយ សម្រាប់រយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ។** នេះជាអត្រាទាបជាងប្រទេសក្នុងតំបន់ និងទាបខ្លាំងជាងប្រទេសវៀតណាម និងថៃ ក្នុងអំឡុងឆ្នាំដែលប្រទេសទាំងពីរនេះមានកំណើនសេដ្ឋកិច្ចខ្លាំង (រូប S3)។ បើទោះជាការវិនិយោគសរុបនៅកម្ពុជាបច្ចុប្បន្នមានការកើនឡើង ភាគច្រើន ការវិនិយោគនេះស្ថិតក្នុងវិស័យសំណង់ មិនមែនលើគ្រឿងម៉ាស៊ីន និងបរិក្ខារឡើយ។ អត្រាទាបនៃមូលធនថេរដុលរបស់កម្ពុជាអាចបណ្តាលមកពីប្រាក់សន្សំតិចក្នុងប្រទេស។ ដោយសារប្រាក់សន្សំក្នុងប្រទេសតិច (រូប S4) ការវិនិយោគភាគច្រើនទទួលបានហិរញ្ញប្បទានពីប្រាក់សន្សំពីបរទេស ដែលជាការវិនិយោគលើវិស័យឯកជនដោយវិនិយោគិនបរទេស និងការវិនិយោគសាធារណៈដោយដៃគូអភិវឌ្ឍន៍ជាផ្លូវការ។ តាមការប៉ាន់ស្មាន 10 ទៅ 11 ភាគរយនៃ ផសស ពាក់ព័ន្ធនឹងមូលធនទទួលបានហិរញ្ញប្បទានពីការវិនិយោគផ្ទាល់ពីបរទេស និងប្រមាណ 50 ភាគរយ ទទួលបានហិរញ្ញប្បទានពីការវិនិយោគក្នុងស្រុក។ សល់ពីនេះគឺការវិនិយោគលើវិស័យសាធារណៈដែលទទួលបានហិរញ្ញប្បទានភាគច្រើនពីដៃគូអភិវឌ្ឍន៍។ បើទោះជាមានកំណើនមូលធនក្នុងរយៈពេលប៉ុន្មានឆ្នាំនេះក្តី របាយនៃការវិនិយោគនេះហាក់មិនសូវមានប្រសិទ្ធផលទេ ដោយមានការថយចុះនៃផលចំណេញពីការវិនិយោគ[៣៤]។ ការវិនិយោគលើបរិក្ខារបានផ្តល់កំណើនច្រើនជាងការវិនិយោគលើសំណង់ ហើយប្រទេសដែលមានការវិនិយោគខ្ពស់លើបរិក្ខារ មានកំណើនកាន់តែខ្ពស់ (Summers និង DeLong 1991, 1992)។

**អត្រាប្រាក់សន្សំក្នុងប្រទេសទាប អាចបណ្តាលមកពីប្រវត្តិសោកនាដកម្មនៅកម្ពុជា រួមទាំង ឥទ្ធិពលនៃសង្គ្រាមវៀតណាម**

**រូប S1 ៖ ការផ្លាស់ប្តូររចនាសម្ព័ន្ធ ឆ្នាំ 1995 និង 2017**

ការថយចុះយ៉ាងលឿននៃចំណែកវិស័យកសិកម្មក្នុង ផសស (ចំណែកជា %)




*ប្រភព* ៖ ប្រភពផ្លូវការ និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

**រូប S2 ៖ ការថយចុះនៃអត្រាការងារក្នុងវិស័យកសិកម្ម**

ការចូលរួមក្នុងការបង្កើតការងារ (ពាន់ការងារ)




*ប្រភព* ៖ ការអង្កេតសេដ្ឋកិច្ចសង្គមនៅកម្ពុជា

៣៤ “កម្ពុជាឆ្នាំ 2017 ៖ ការរក្សាកំណើនរឹងមាំសម្រាប់ជាប្រយោជន៍របស់មនុស្សគ្រប់គ្នា ៖ ការវិភាគប្រទេសជាប្រព័ន្ធ ធនាគារពិភពលោក វ៉ាស៊ីនតោន ឌីស៊ី ឆ្នាំ 2017។

**និងអំពើប្រល័យពូជសាសន៍ទ្រង់ទ្រាយធំ។** ក្នុងអំឡុងពេលទាំងនេះ កម្ពុជាមានអតិផរណាខ្ពស់ក្នុងរយៈពេលយូរ។ ហេតុការណ៍អាក្រក់បំផុតបានកើតឡើងនៅសម័យខ្មែរក្រហម នៅពេលដែលរូបិយវត្ថុរបស់កម្ពុជាត្រូវបានបំផ្លាញចោល និងត្រូវបានជំនួសដោយប្រព័ន្ធដោះដូរទំនិញជាងបីឆ្នាំ។ នៅអំឡុងទសវត្សរ៍ឆ្នាំ 1980 ក្រោយរបបខ្មែរក្រហមដួលរលំ វិស័យធនាគារមិនបានបំពេញមុខងារពេញលេញឡើយ ដោយសារតែអស្ថិរភាព និងការបន្តសង្គ្រាមស៊ីវិលនៅតាមតំបន់ជាច្រើនក្នុងប្រទេស។ សូម្បីតែក្រោយពេលដែលមានការស្តារសន្តិភាពបានយ៉ាងច្រើននៅអំឡុងទសវត្សរ៍ឆ្នាំ 1990 ក្តី ក៏ទំនុកចិត្តលើប្រព័ន្ធធនាគារបានកើនឡើងយ៉ាងយឺត ចំណែករូបិយវត្ថុក្នុងស្រុកទទួលបានទំនុកចិត្តតិចតួចបំផុត។ អត្រាដុល្លាររូបនីយកម្មខ្ពស់នៅកម្ពុជាជាការឆ្លុះបញ្ចាំងពីអស្ថិរភាពពីអតីតកាល។

**វិស័យហិរញ្ញវត្ថុរបស់កម្ពុជា ទើបតែចាប់ផ្តើមរីកចម្រើនតែប៉ុណ្ណោះ ដែលធ្វើកម្ពុជាមានការលំបាកក្នុងការបង្កើនមូលធនដើម្បីផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគ។** មិនទាន់មានទីផ្សារមូលធន ឬទីផ្សារបំណុលក្នុងស្រុកដែលដំណើរការល្អនៅឡើយនៅកម្ពុជា ដូច្នេះ គ្មានហេដ្ឋារចនាសម្ព័ន្ធសម្រាប់បង្កើនមូលនិធិរយៈពេលវែង បើទោះជាបានផ្តល់ឱកាសឲ្យសាធារណជនវិនិយោគលើប្រាក់សន្សំរយៈពេលវែងរបស់ខ្លួន។ ឱកាសសម្រាប់ឲ្យគ្រឹះស្ថានផ្សេងៗ ដូចជា ធនាគារពាណិជ្ជ មូលនិធិសង្គហ ឬមូលនិធិវិនិយោគ សម្រាប់ការវិនិយោគប្រាក់សន្សំ នៅមានកម្រិតទាបនៅឡើយ។ កំណើនលំហូរការវិនិយោគផ្ទាល់ពីបរទេសនៅកម្ពុជាក្នុងរយៈពេលមួយទសវត្សរ៍កន្លងទៅ ពាក់ព័ន្ធនឹងគម្លាតរវាងប្រាក់សន្សំ និងការវិនិយោគ ដែលធ្វើឲ្យកម្ពុជាលំបាករក្សាបានកំណើនរឹងមាំក្នុងរយៈពេលវែង។ ជាការសំខាន់ ដោយសារតែឱនភាពគណនីចរន្តធំ សេដ្ឋកិច្ចកម្ពុជាកាន់តែងាយប្រឈមនឹងវិបត្តិខាងក្រៅ។

## 3. ធនធានមនុស្សកើនឡើងយ៉ាងលឿន ប៉ុន្តែ មានមូលដ្ឋានទាប ដោយកម្លាំងពលកម្មដែលកំពុងកើនឡើងនេះ នៅខ្វះការបណ្តុះបណ្តាលឲ្យបានគ្រប់គ្រាន់នៅឡើយ

**ការអង្កេតសហគ្រាសនាពេលថ្មីៗនេះបង្ហាញថា ក្រុមហ៊ុនជាច្រើនយល់ថា កម្លាំងពលកម្មដែលមានការអប់រំមិនគ្រប់គ្រាន់ជាឧបសគ្គមួយក្នុងចំណោមឧបសគ្គធំៗទាំងបី** (រូប S5)។ ឧបសគ្គដែលបង្កឡើងដោយកម្លាំងពលកម្មគ្មានជំនាញ ត្រូវបានបង្ហាញនៅក្នុងការស្ទង់មតិអ្នកដឹកនាំនៅវេទិកាសេដ្ឋកិច្ចពិភពលោក ដែលក្រុមហ៊ុនក្នុងចំនួនដូចគ្នានេះបង្ហាញថា បញ្ហានេះជាចំណុចរាំងស្ទះដ៏ធំលើការធ្វើអាជីវកម្ម។ សក្តានុពលនៃការធ្វើពិពិធកម្មសេដ្ឋកិច្ច អាចត្រូវបានរាំងស្ទះដោយសារខ្វះធនធានមនុស្ស និងការចំណាយខ្ពស់លើថ្លៃសេវាក្រៅផ្លូវការ និងថ្លៃអគ្គិសនី[៣៥]។ ការបង្កើនប្រាក់ឈ្នួលអប្បបរមាយ៉ាងលឿន គឺជាបញ្ហាប្រឈមមួយទៀត។

**កំណើនធនធានមនុស្សគឺជាកត្តាសំខាន់ក្នុងការសម្រួលដល់ពិពិធកម្មសេដ្ឋកិច្ច និងការបង្កើតការងារ។** ធនធានមនុស្សត្រូវបានរំពឹងថានឹងកាន់តែមានសារៈសំខាន់ ដោយសារតែកម្ពុជាកំពុងខិតខំដើម្បីបំពេញការងារក្នុងសង្វាក់តម្លៃកម្រិតខ្ពស់ និងធ្វើពិពិធកម្មលើសពីផលិតផលកាត់ដេរដែលមានតម្លៃទាប។ បើទោះជាបទប្បញ្ញត្តិដែលមានភាពទាក់ទាញខ្ពស់ បានបង្កើនលទ្ធភាពរបស់កម្ពុជា (ធៀបនឹងប្រទេសជិតខាង) ក្នុងការធ្វើពិពិធកម្មវិស័យសេវាកម្ម បញ្ហាកម្រិតអប់រំទាបនៅកម្ពុជាគឺជាឧបសគ្គក្នុងការធ្វើដំណើរឆ្ពោះទៅកាន់ការងារដែលមានតម្លៃបន្ថែមខ្ពស់ និងឧស្សាហកម្ម និងវិស័យដែលមានភាពទំនើបជាង (រូប S6)។

**រូប S3 ៖ មូលធននៅមានកម្រិតទាប**

មូលធនថេរដុល (មធ្យមភាគពេលវេលា % នៃ ផសស)




*ប្រភព* ៖ សូចនាករអភិវឌ្ឍន៍ពិភពលោក

**រូប S4 ៖ គម្លាតនៃប្រាក់សន្សំ និងការវិនិយោគនៅកម្ពុជា**




*ប្រភព* ៖ សូចនាករអភិវឌ្ឍន៍ពិភពលោក

*សម្គាល់* ៖ ប្រាក់សន្សំគឺជាអ្វីដែលសល់ពីការវិនិយោគ រួមនឹងតុល្យភាពគណនីចរន្ត

[៣៥] "កម្ពុជាឆ្នាំ 2017 ៖ ការរក្សាកំណើនរឹងមាំសម្រាប់ជាប្រយោជន៍របស់គ្រប់គ្នា ៖ ការវិភាគប្រទេសជាប្រព័ន្ធ ធនាគារពិភពលោក វ៉ាស៊ីនតោន ឌីស៊ី ឆ្នាំ 2017។

**រូប S5 ៖ សហគ្រាសខ្នាតតូច និងមធ្យមដែលមានកម្លាំងពលកម្មដែលមានជំនាញមិនគ្រប់គ្រាន់ មាន “កម្លាំងពលកម្មដែលមានជំនាញមិនគ្រប់គ្រាន់” ស្ថិតក្នុងចំណោមឧបសគ្គធំៗ ៣ ហើយមានចំនួនតិចជាងសម្រាប់ក្រុមហ៊ុនធំៗ** (% ក្រុមហ៊ុន)




*ប្រភព ៖* ការអង្កេតសហគ្រាសឆ្នាំ 2016

**រូប S6 ៖ កម្រិតអប់រំទាប**

កម្រិតអប់រំ យ៉ាងហោចណាស់បានបញ្ចប់មធ្យមសិក្សាបឋមភូមិ (ប្រជាជនអាយុ 25 ឆ្នាំឡើងទៅ, សរុប (%), សរុប)




*ប្រភព ៖* WDI និង CSES ឆ្នាំ 2016

*សម្គាល់ ៖* ទិន្នន័យទាំងនេះសម្រាប់ឆ្នាំ 2016 ឬឆ្នាំថ្មីបំផុត

**ផ្នែកខាងក្រោមពិភាក្សាពីឱកាស និងបញ្ហាប្រឈមសម្រាប់កម្ពុជា ក្នុងការសម្រេចបានគោលដៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ 2030 និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ 2050 (យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី 4)**[៣៦]។ នៅក្នុងគោលបំណងនេះ ផ្នែកនេះពិនិត្យមើលជាពិសេសទៅលើការសម្រេចបានប្រាក់ចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់របស់កម្ពុជានៅរយៈពេល 33 ឆ្នាំខាងមុខ តាមរយៈការប្រើប្រាស់លំនាំកំណើនរយៈពេលវែងរបស់ធនាគារពិភពលោក (Loayza និង Pennings 2018)។

## III. ការវាយតម្លៃទៅលើសក្តានុពលកំណើនរយៈពេលវែងរបស់កម្ពុជា

### គោលដៅកំណើន

**កម្ពុជាកំពុងខិតខំសម្រេចគោលដៅជាប្រទេស ដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ 2030 និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ 2050 ប៉ុន្តែ កម្ពុជាត្រូវមានកំណើនសេដ្ឋកិច្ចថេរ និងលឿន ដើម្បីសម្រេចបានគោលដៅនេះ។** តាមការបែងចែកប្រភេទរបស់ក្រុមធនាគារពិភពលោក ប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់គឺជាប្រទេសដែលមានប្រាក់ចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ៗ (វិធីសាស្ត្រ Atlas)[៣៧] យ៉ាងតិច 3,896 ដុល្លារ ចំណែកប្រទេសដែលមានប្រាក់ចំណូលខ្ពស់គឺជាប្រទេស ដែលមានប្រាក់ចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ៗ យ៉ាងតិច 12,056 ដុល្លារ។ នៅឆ្នាំ 2017 កម្ពុជាមានប្រាក់ចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ៗ 1,230 ដុល្លារ។ មានន័យថា ប្រាក់ចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ៗរបស់កម្ពុជាត្រូវកើនឡើងជាង 3 ដងក្នុងរយៈពេល 13 ឆ្នាំខាងមុខ ដើម្បីក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ 2030 និងកំណើនប្រាក់ចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ៗ ជិត 10 ដងក្នុងរយៈពេល 33 ឆ្នាំខាងមុខ។ អាចនិយាយបានថា គោលដៅទាំងនេះតម្រូវឲ្យមានការធានាបានកំណើនប្រាក់ចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ៗប្រមាណ 9.3 ភាគរយក្នុងអំឡុងឆ្នាំ 2018 និង 2030 ដើម្បីឲ្យកម្ពុជាក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ 2030 និងអត្រាកំណើនប្រាក់ចំណូលជាតិសរុប សម្រាប់មនុស្សម្នាក់ៗ 7.2 ភាគរយក្នុងអំឡុងឆ្នាំ 2018 និង 2050 ដើម្បីឲ្យកម្ពុជាក្លាយជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ 2050។ ផ្ទុយទៅ

**រូប S7 ៖ ផសស និង ប្រាក់ចំណូលជាតិដុលសម្រាប់មនុស្សម្នាក់ៗមានកំណើនប្រហាក់ប្រហែលគ្នា** (%)




*ប្រភព ៖* សូចនាករអភិវឌ្ឍន៍ពិភពលោក

៣៦ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី 4 រាជរដ្ឋាភិបាលកម្ពុជា ខែ កញ្ញា ឆ្នាំ 2017។

៣៧ https://datahelpdesk.worldbank.org/knowledgebase/articles/378832-the-world-bank-atlas-method-detailed-methodology.

វិញ ក្នុងរយៈពេល 5 ឆ្នាំកន្លងទៅនេះ ប្រាក់ចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ៗរបស់កម្ពុជាកើនឡើងតែ 5.2 ភាគរយប៉ុណ្ណោះ (រូប S7)។ ដូច្នេះ គោលដៅឆ្នាំ 2050 តម្រូវឲ្យមានកំណើន 2 ភាគរយពិន្ទុ ចំណែកគោលដៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ តម្រូវឲ្យមានកំណើន ផសស សម្រាប់មនុស្សម្នាក់ជិត 2 ដង។ គួរកត់សម្គាល់ថា ផសស សម្រាប់មនុស្សម្នាក់ និង ប្រាក់ចំណូលជាតិដុលសម្រាប់មនុស្សម្នាក់ៗ កើនឡើងក្នុងអត្រាប្រហាក់ប្រហែលគ្នា ដូច្នេះហើយយើងនឹងប្រើប្រាស់ពាក្យទាំងពីរនេះជំនួសឲ្យគ្នាទៅវិញទៅមក[៣៨]។

**ផ្អែកតាមគន្លងអភិវឌ្ឍន៍ដែលមានកំណើនលឿនរបស់បណ្ដាប្រទេសនៅអាស៊ីគិតត្រឹមពេលដែលប្រទេសទាំងនោះមានកម្រិតប្រាក់ចំណូលដូចកម្ពុជានេះ (រូប S8) ប្រទេសទាំងអស់ លើកលែងតែប្រទេសចិន មិនសម្រេចបានគោលដៅជាប្រទេសដែលមានប្រាក់ចំណូលទាបមធ្យម (2030) ឡើយ ហើយប្រទេសទាំងអស់លើកលែងតែសាធារណរដ្ឋកូរ៉េ មិនសម្រេចបានគោលដៅជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ (2050) នោះទេ។** កាលពីឆ្នាំ 1958 ប្រទេសម៉ាឡេស៊ីមានអត្រាប្រាក់ចំណូលជាតិដុលសម្រាប់មនុស្សម្នាក់ៗ ដូចកម្ពុជាបច្ចុប្បន្ន ហើយប្រទេសថៃមានអត្រាចំណូលនេះដូចកម្ពុជាកាលពីឆ្នាំ 1975។ បើទោះជាមានអត្រាកំណើនខ្ពស់ ប៉ុន្តែប្រទេសទាំងពីរនេះមិនសម្រេចបានគោលដៅបង្កើនប្រាក់ចំណូលជាតិដុលសម្រាប់មនុស្សម្នាក់ៗឲ្យបានបីដងក្នុងរយៈពេល 13 ឆ្នាំ ឬបង្កើនប្រាក់ចំណូលជាតិដុលសម្រាប់មនុស្សម្នាក់ៗ 10 ដងក្នុងរយៈពេល 33 ឆ្នាំឡើយ។ កាលពីឆ្នាំ 2006 ប្រទេសវៀតណាមមានអត្រាប្រាក់ចំណូលជាតិដុលសម្រាប់មនុស្សម្នាក់ៗ ដូចកម្ពុជា ប៉ុន្តែហាក់មានគន្លងកំណើនដូចប្រទេសថៃ និងម៉ាឡេស៊ី។ កាលពីឆ្នាំ 1963 ប្រទេសកូរ៉េមានកម្រិតអភិវឌ្ឍនដូចកម្ពុជាបច្ចុប្បន្ន ប៉ុន្តែបើទោះជាមានកំណើនខ្លាំងជា "ខ្លាសេដ្ឋកិច្ចអាស៊ី" ហើយសម្រេចបានគោលដៅជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ក្ដី ក៏ប្រទេសនេះមិនសម្រេចបានគោលដៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ដែរ[៣៩]។

**បទពិសោធន៍នាពេលថ្មីៗរបស់ប្រទេសចិន មិនមែនជាមគ្គុទេសន៍ដ៏ល្អសម្រាប់កម្ពុជាឡើយ ព្រោះប្រទេសចិនមានអត្រាការវិនិយោគ និងប្រាក់សន្សំខ្ពស់ពីដំបូង។** នៅពេលដែលប្រទេសចិនមានកម្រិតអភិវឌ្ឍន៍ប្រហាក់ប្រហែលកម្ពុជាបច្ចុប្បន្ន (នៅអំឡុងឆ្នាំ 1994) ប្រទេសចិនបានវិនិយោគ 35 ភាគរយនៃ ផសស និងកើនឡើងដល់ 45 ភាគរយនៃ ផសស នៅក្នុងរយៈពេល 15 ឆ្នាំក្រោយមក (រូប 9)។ ផ្ទុយទៅវិញ កម្ពុជាទើបតែ

**រូប S8 ៖ ការប្រៀបធៀបប្រទេសដែលមានកំណើនសេដ្ឋកិច្ចលឿន ដែលមិនសម្រេចបានគោលដៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់**




*ប្រភព* ៖ សូចនាករអភិវឌ្ឍន៍ពិភពលោក

*សម្គាល់* ៖ ចំណូលម្នាក់ៗ $1,230 (ដុល្លា គិតតាមវិធីសាស្ត្រ Atlas) នៅកម្ពុជា គឺ $1,062 នៃអត្រាប្តូរប្រាក់ដុល្លាឆ្នាំ 2010។ ការគណនាទាំងនេះផ្អែកលើពេលដែលចំណូលម្នាក់ៗរបស់ប្រទេសនានានៅត្រឹមកម្រិតនោះ (អត្រាប្តូរប្រាក់ដុល្លាឆ្នាំ 2010)។ អត្រាកំណើន ផសស ម្នាក់ៗ ពិត ពី PWT9 ឬ WDI ដែលប្រើដើម្បីបំពេញ នៅពេលគ្មានចំណូលម្នាក់ៗពិត។

**រូប S9 ៖ អត្រាវិនិយោគរបស់ប្រទេសចិនមានកម្រិតខ្ពស់ខ្លាំង សូម្បីតែនៅពេលគិតត្រឹមកម្រិតអភិវឌ្ឍន៍របស់កម្ពុជាក្ដី**




*ប្រភព* ៖ សូចនាករអភិវឌ្ឍន៍ពិភពលោក

---

៣៨ គោលដៅក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ ត្រូវបានកំណត់ជាប្រាក់ដុល្លាអាមេរិក ដោយប្រើអត្រាប្តូរប្រាក់ទីផ្សារជាមធ្យមភាពក្នុងរយៈពេលជាច្រើនឆ្នាំ (មធ្យោបាយ Atlas)។ ធនាគារពិភពលោកបានកែសម្រួលការកាត់បន្ថយរៀងរាល់ឆ្នាំ ដែលជាទូទៅកើនឡើង ដើម្បីគិតបញ្ចូលអតិផរណា។ ដូច្នេះ ការកាត់បន្ថយពិតប្រាកដនៅឆ្នាំ 2030 និង 2050 មិនអាចដឹងបានឡើយ។ ផ្ទុយទៅវិញ យើងបានធ្វើការសន្មតធម្មតាពីរ គឺ (ក) ការកាត់បន្ថយនៅថេរគិតជាតម្លៃពិត (កើនឡើងតាមអតិផរណាប្រាក់ដុល្លា) និង (ខ) ចំណូលជាតិសរុប និង ផសស កើនឡើងក្នុងអត្រាដូចគ្នា។ នៅអំឡុងពីឆ្នាំ 1996 ដល់ 2017 (គ) ប្រហែលជាពិត ៖ អត្រាកំណើនមធ្យមនៃចំណូលជាតិសរុប គឺ 0.25 ភាគរយពិន្ទុ យឺតជាងកំណើន ផសស។ ក្នុងរយៈពេលរហូតដល់ឆ្នាំ 2030 កំណើនប្រចាំឆ្នាំប្រមាណ 0.25 នឹងកើនឡើងដល់ 3 ភាគរយពិន្ទុ ហើយរហូតដល់ឆ្នាំ 2050 អត្រានេះកើនឡើងដល់ 7 ភាគរយពិន្ទុ។ ប៉ុន្តែ ក៏មានកំហុសដោយសារតែការសរុបចំពោះកំណើន 3 ដង ឬ 10 ដងនៃ ផសស សម្រាប់មនុស្សម្នាក់ៗនៅអំឡុងពេលដូចគ្នានេះ។

៣៩ យើងក៏ពិចារណាពីប្រទេសជប៉ុន និងសិង្ហបុរី ប៉ុន្តែ ចំណូលម្នាក់ៗខ្ពស់ជាចំណូលម្នាក់ៗរបស់កម្ពុជា នៅពេលទិន្នន័យប្រចាំឆ្នាំចាប់មានពីឆ្នាំ 1950។

វិនិយោគ 22 ភាគរយនៃ ផសស ហើយថ្មីៗនេះមានការវិនិយោគតិចជាង 20 ភាគរយ។ ជាក់ស្តែង អត្រាវិនិយោគខ្ពស់អាចមានជាក់ស្តែងបាន លុះត្រាតែមានអត្រាប្រាក់សន្សំខ្ពស់ប៉ុណ្ណោះ សូម្បីតែសម្រាប់ប្រទេស ដែលមានគណនីមូលធនបើកចំហក្តី (the Felstein-Horioka Puzzle)។ ខណៈដែលប្រទេសចិនមានអត្រាប្រាក់សន្សំប្រមាណ 35 ភាគរយនៃ ផសស នៅឆ្នាំ 1994 កម្ពុជាមានអត្រាប្រាក់សន្សំតិចជាង 15 ភាគរយនៃ ផសស (រូប S4 ខាងលើ)។ ការបង្កើនអត្រាប្រាក់សន្សំ និងការវិនិយោគ អាចធ្វើទៅបានក្នុងរយៈពេលវែង (ពិភាក្សាលម្អិតក្នុងផ្នែកខាងក្រោម) ប៉ុន្តែការបង្កើនឲ្យបានលឿនគឺជាការលំបាក។

**បទពិសោធន៍របស់ប្រទេសម៉ាឡេស៊ី និងកូរ៉េដែលមានអត្រាកំណើនការវិនិយោគយឺត គឺជាមគ្គុទេសន៍ដ៏ល្អ ដែលមានអត្រាវិនិយោគដំបូងប្រហែលគ្នានឹងអត្រាវិនិយោគរបស់កម្ពុជា ក្នុងអត្រាកំណើនដល់ 30 ភាគរយនៃ ផសស ក្នុងរយៈពេល 15 ឆ្នាំ** (រូប S10)។ អត្រាវិនិយោគនៅប្រទេសម៉ាឡេស៊ី និងកូរ៉េ មានកម្រិតទាបបំផុតជាចំណែកនៃ ផសស និងពេលខ្លះទាបជាងអត្រាវិនិយោគរបស់កម្ពុជាបច្ចុប្បន្នទៅទៀត។ ប៉ុន្តែ ប្រទេសទាំងពីរនេះអាចបង្កើនអត្រានេះបានជិត 10 ភាគរយពិន្ទុនៃ ផសស ក្នុងមួយឆ្នាំនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ 1960 និងដើមទសវត្សរ៍ឆ្នាំ 1970 ដើម្បីសម្រេចបានអត្រាវិនិយោគ 28 និង 33 ភាគរយពិន្ទុ។ យើងយល់ថា កម្ពុជាអាចសម្រេចបានតាមគន្លងនេះ ហើយវាជាមគ្គុទេសន៍សម្រាប់ការអនុវត្តតាម “ការវិនិយោគដូចនៅកូរ៉េ និងម៉ាឡេស៊ី” ក្នុងផ្នែកខាងក្រោម។

ការពិនិត្យទៅលើទស្សនវិស័យរបស់កម្ពុជា នៅក្នុងសេណារីយ៉ូធម្មតា បង្ហាញថា កម្ពុជានឹងមិនអាចសម្រេចបានទាំងគោលដៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់

**លំនាំកំណើនរយៈពេលវែងរបស់ធនាគារពិភពលោក គឺជាឧបករណ៍ក្នុងកម្មវិធី Excel ដែលផ្អែកតាមលំនាំកំណើន Solow-Swan ដ៏ល្បីល្បាញ និងត្រូវបានប្រើប្រាស់សម្រាប់ការពិនិត្យទៅលើគន្លងកំណើនរបស់កម្ពុជានៅក្នុងសេណារីយ៉ូជាច្រើន។** លំនាំកំណើននេះរួមមាន ការវិនិយោគ ផលិតភាពសរុប ធនធានមនុស្ស ស្ថានភាពប្រជាសាស្ត្រ និងចលករកំណើនផ្សេងៗទៀតដែលចាំបាច់សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសដែលមានសេដ្ឋកិច្ចងើបឡើង (សូមមើលឧបសម្ព័ន្ធ និង www.worldbank.org/LTGM ដែលរៀបរាប់ពីលំនាំកំណើននេះ ឬទទួលបានឯកសារនេះ)។

**មានទិន្នន័យគោលដែលប្រព្រឹត្តតាមធម្មតាពីរ គឺ ទិន្នន័យគោលធម្មតាដែលមានកំណើន 7 ភាគរយនៃកំណើន ផសស ពីដំបូង (ដូចគ្នានឹងអំឡុងឆ្នាំ 2013-2017) ឬទិន្នន័យគោលអភិរក្សដែលមានកំណើន 6.1 ភាគរយ (ដូចគ្នានឹងអំឡុងឆ្នាំ 2008-2017)។** កំណើននៅក្នុងទិន្នន័យគោលទាំងពីរមានស្ថិរភាពបង្គួរ (រូប S12) ដោយកើនឡើងប្រមាណ 0.5 ភាគរយពិន្ទុក្នុងអំឡុងពេលនេះរហូតដល់ឆ្នាំ 2045 មុនពេលថយចុះ (ភាគច្រើន ដោយសារកត្តាប្រជាសាស្ត្រ ដូចបានពិភាក្សាខាងក្រោម)។ ក្នុងរូប S11 តួលេខកំណើនផសស (មិនមែនសម្រាប់មនុស្សម្នាក់) មានកម្រិតថេរត្រឹម 7 ភាគរយតាំងពីឆ្នាំ 2011 ដែលជាចំណុចដៅនៃទិន្នន័យគោលធម្មតា បើទោះជារាប់ទាំងវិបត្តិហិរញ្ញវត្ថុ កំណើននេះមានអត្រាថយចុះជិត 1 ភាគរយ (ចំណុចដៅនៃទិន្នន័យគោលកម្រិតទាប)។

**អត្រាកំណើនខុសគ្នារវាងទិន្នន័យគោលធម្មតា និងទិន្នន័យគោលអភិរក្ស កើតចេញពីភាពខុសគ្នាពីរ។** ទីមួយ ទិន្នន័យគោលធម្មតាយកអត្រាវិនិយោគខ្ពស់ប្រមាណ 22 ភាគរយនៃ ផសស នៅឆ្នាំ 2017 និងការព្យាកររបស់មូលនិធិរូបិយវត្ថុអន្តរជាតិ

**រូប S10 ៖ កូរ៉េ និងម៉ាឡេស៊ី អាចបង្កើនអត្រាវិនិយោគ ដោយចាប់ផ្តើមពីកម្រិតរបស់កម្ពុជា**

ផលធៀបនៃការវិនិយោគ និង ផសស (%)




*ប្រភព* ៖ សូចនាករអភិវឌ្ឍន៍ពិភពលោក (បន្ទាត់ជាប់) Penn World Tables v9 (បន្ទាត់ដាច់)

**រូប S11 ៖ កម្ពុជាមានប្រវត្តិកំណើនលឿន ប៉ុន្តែនៅថេរត្រឹម 7 ភាគរយតាំងពីឆ្នាំ 2011** (%)




*ប្រភព* ៖ សូចនាករអភិវឌ្ឍន៍ពិភពលោក

ចំណែកទិន្នន័យគោលកម្រិតទាបយកផលធៀបនៃការវិនិយោគ និងផសស ដែលមាន 20 ភាគរយដែលជាមធ្យមភាគក្នុងរយៈពេល 5 ឬ 10 ឆ្នាំកន្លងទៅនេះ។ ទីពីរ ទិន្នន័យគោលធម្មតាយកចំណែកការងារទាប (40 ភាគរយ) ដោយផ្អែកលើទិន្នន័យពីគម្រោងវិភាគពាណិជ្ជកម្មសកល (GTAP) ដែលជំរុញប្រសិទ្ធភាពនៃការវិនិយោគដើម្បីទទួលបានកំណើនសេដ្ឋកិច្ច។ ជាញឹកញាប់ ចំណែកការងារក្នុងទិន្នន័យនេះមានកម្រិតទាបពេក ព្រោះប្រាក់ចំណូលក្នុងវិស័យក្រៅផ្លូវការត្រូវបានរាប់ជាប្រាក់ចំណូលមូលធន។ ដូច្នេះ ទិន្នន័យគោលកម្រិតទាបសយកអត្រា 50 ភាគរយវិញ ដែលជាអត្រាជិតមេដ្យានប្រាក់ចំណូលនៃប្រទេសផ្សេងៗដែលមានប្រាក់ចំណូលជាមធ្យមកម្រិតទាបប្រមាណ 53 ភាគរយ (Barrot 2016)។ លក្ខណៈផ្សេងទៀតនៃទិន្នន័យគោលធម្មតា មានលក្ខណៈទូទៅ (សូមមើលតារាង S1) ដោយ (ក) ផលធៀបទុន និងផលិតផល 2 (តម្លៃទាបទៅមធ្យម ដែលកើតចេញពីកំណើនខ្ពស់ និងការវិនិយោគតិចបំផុត) (ខ) អត្រាកំណើនធនធានមនុស្ស 1.5 ភាគរយ ដោយផ្អែកលើទិន្នន័យ Penn World Tables v9 ដែលជាមធ្យមភាពក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយ[៤០] និង (គ) អត្រាកំណើនផលិតភាពខ្ពស់សរុបមាន 2 ភាគរយ ជាអ្វីដែលបានមកពីអត្រាកំណើនខ្ពស់ប៉ុន្តែមានការវិនិយោគតិច[៤១]។

**តារាង S1 ៖ ខ្លឹមសារសង្ខេបនៃប៉ារ៉ាម៉ែត្រ និងការសន្មតសំខាន់ៗ**

| **អញ្ញត្តិ** | **ទិន្នន័យគោលអភិរក្ស** | **ទិន្នន័យគោលធម្មតា** | **ប្រភព/មតិយោបល់** |
|---|---|---|---|
| | **ក្រុម ក ៖ ប៉ារ៉ាម៉ែត្រ/ការសន្មតជាទូទៅ** | | |
| **ផលធៀប ទុន និង ផល** | 2.0 | | PWT 8.1 សម្រាប់ឆ្នាំ 2010, PWT 9 សម្រាប់ឆ្នាំ 2014 ៖ 2.03 |
| **កំណើនធនធានមនុស្ស** | 1.5% | | ស្រដៀងគ្នានឹង PWT 9 ៖ មធ្យមភាគ 5-10 ឆ្នាំ |
| **កំណើនផលិតភាពសរុប** | 2% | | គ្មានកំណើន PWT TFP ។ 2% គឺនៅចន្លោះពី 2.2% សម្រាប់មធ្យមភាគ 20 ឆ្នាំ និង 1.3% សម្រាប់មធ្យមភាគ 10 ឆ្នាំ (ការគណនាផ្ទាល់ខ្លួន) និងប្រមាណ 95 ចំណែកប្រភាគ (percentile) សម្រាប់មធ្យមភាគ 20 ឆ្នាំ តាមបណ្ដាប្រទេសនានា |
| **អត្រាចុះថ្លៃ** | 4.7% | | 2011 សម្រាប់ PWT 8.1 |
| **កំណើនប្រជាជន 2017-2050** | 1.54%...0.54% | | ការព្យាករចំនួនប្រជាជនដោយអង្គការសហប្រជាជាតិ (តាមរយៈធនាគារពិភពលោក និងបណ្ដាញអភិវឌ្ឍន៍មនុស្ស) |
| **កម្រិតចំណូលម្នាក់ៗ (2017)** | US$ 1,230 | | |
| | **ក្រុម ខ ៖ ទិន្នន័យគោលការងារប្រព្រឹត្តតាមធម្មតា (ប៉ារ៉ាម៉ែត្រផ្សេងទៀតដូចក្នុងក្រុម ក)** | | |
| **ផលធៀបនៃការវិនិយោគ និង ផសស** | 20% | 22% | កម្រិតទាប ៖ ជិតមធ្យមភាគ 5-10 ឆ្នាំ<br>ជាធម្មតា ៖ ស្មើនឹងចំនួនឆ្នាំ 2017 ដែលប្រហែលគ្នានឹងការប៉ាន់ស្មានរបស់ IMF កថាខណ្ឌ IV សម្រាប់ពេលអនាគត (2018-2023) |
| **ចំណែកការងារធៀបនឹងប្រាក់ចំណូល** | 50% | 40% | ជាមធ្យម ៖ GTAP (38%) (គ្មានទិន្នន័យ PWT)<br>កម្រិតទាប ៖ មេដ្យានក្នុងប្រទេសផ្សេងៗ (50%)* |
| **កំណើន ផសស ជាញឹកញាប់នៅឆ្នាំ 2018** | 6.1% | 7.0% | អត្រាកំណើនជាញឹកញាប់នៃ ផសស ក្នុងអត្រា 7 ភាគរយ ស៊ីសង្វាក់គ្នានឹងការប៉ាន់ស្មានរបស់ IMF កថាខណ្ឌ IV។ |
| | **ក្រុម គ ៖ សេណារីយ៉ូដែលមានការវិនិយោគខ្ពស់ ដើម្បីសម្រេចបានគោលដៅកំណើន (ប៉ារ៉ាម៉ែត្រផ្សេងទៀតដូចក្នុងក្រុម ក ឬ ខ)** | | |
| **ផលធៀបនៃការវិនិយោគ និង ផសស (2030-50)** | 28% | 33% | ជាធម្មតា ៖ អត្រាវិនិយោគរបស់កូរ៉េ (មធ្យមភាគឆ្នាំ 1978-95, WDI)<br>កម្រិតអភិរក្ស ៖ អត្រាវិនិយោគរបស់ម៉ាឡេស៊ី (មធ្យមភាគឆ្នាំ 1971-90, WDI) |

*សម្គាល់* ៖ * ចំណែកការងាររបស់ GTAP អាចមានភាពលម្អៀងចុះក្រោម ដោយសារតែប្រាក់ចំណូលពីអាជីវកម្មក្នុងវិស័យក្រៅផ្លូវការត្រូវបានរាប់ជាប្រាក់ចំណេញ មិនមែនជាកម្លាំងពលកម្មទេ។ GTAP គឺជាគម្រោងវិភាគពាណិជ្ជកម្មសកល PWT= តារាង Penn world, TFP=ផលិតភាពសរុប។

[៤០] ធនធានមនុស្សត្រូវបានកំណត់ជាផលិតភាពរបស់កម្មករនិយោជិតម្នាក់ដែលមានចំនួនឆ្នាំសិក្សាជាមធ្យម ធៀបនឹងផលិតភាពរបស់កម្មករនិយោជិតម្នាក់ដែលមិនបានចូលរៀន។ ការប៉ាន់ស្មានផលិតភាពផ្អែកលើអត្រាកំណើនប្រាក់ឈ្នួលធៀបនឹងការសិក្សា ដូចទៅនឹងដំណើរ Mincer។ ចំនួនឆ្នាំសិក្សាមិនត្រូវបានកែសម្រួលតាមគុណភាពឡើយ។ នៅឆ្នាំ 2014 ចំនួនឆ្នាំសិក្សាមធ្យមគឺ 4.6 ដែលផ្ដល់រង្វាស់ធនធានមនុស្ស 1.8។

[៤១] អត្រាកំណើនធនធានមនុស្សនេះដូចគ្នាក្នុងប្រទេសកូរ៉េកាលពីអំឡុងពីឆ្នាំ 1960 ទៅ 2014 និងជាអត្រាខ្ពស់គ្រាន់បើ។ អត្រាកំណើន ផលិតភាពសរុបខ្ពស់ជាងអត្រាកំណើនរបស់កូរ៉េនៅគ្រប់ទសវត្សរ៍ លើកលែងតែនៅទសវត្សរ៍ឆ្នាំ 1980 (Jeong 2017)។ ដូច្នេះ មានលទ្ធភាពតិចតួចក្នុងការបង្កើនអត្រាផលិតភាពសរុប ឬកំណើនធនធានមនុស្ស ដោយសារមូលហេតុនេះហើយទើបវាមិនត្រូវបានចាត់ទុកជាវិធីជំរុញកំណើនថែមទៀតនៅក្នុងផ្នែកនេះ។

**អត្រាកំណើនសម្រាប់មនុស្សម្នាក់ (រូប S13) ជាអ្វីដែលពាក់ព័ន្ធសម្រាប់គោលដៅជាប្រទេស ដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ មាននៅពេលដំបូងប្រមាណ 1.5 ភាគរយពិន្ទុ យឺតជាងអត្រាតួលេខកំណើន ផសស** (រូប S12) ទោះបីជាគម្លាតរួមតូចក្នុងឆ្នាំខាងមុខនៅពេលដែលមានអត្រាកំណើនប្រជាជនយឺត។ យោងតាមការព្យាកររបស់អង្គការសហប្រជាជាតិ កំណើនប្រជាជនបច្ចុប្បន្ននៅកម្ពុជាមានប្រមាណ 1.5 ភាគរយពិន្ទុ ប៉ុន្តែត្រូវបានរំពឹងថានឹងថយចុះមកត្រឹម 0.5 ភាគរយពិន្ទុនៅឆ្នាំ 2050 (រូប S14)។ ការថយចុះនៃកំណើនប្រជាជនបានបង្កើនកំណើន ផសស សម្រាប់មនុស្សម្នាក់ប្រមាណ 0.3 ភាគរយពិន្ទុនៅឆ្នាំ 2050 ក្នុងទិន្នន័យគោលធម្មតា ប៉ុន្តែបន្ថយកំណើនប្រមាណ 0.7 ភាគរយពិន្ទុ[៤២]។ មានចំណុចវិជ្ជមានប្រជាសាស្ត្របន្តិចចេញពីកំណើនចំណែកប្រជាជនដែលគ្រប់អាយុធ្វើការ ដែលបានធ្វើឲ្យកំណើនកើនឡើងពី 0.1ទៅ 0.2 ភាគរយនៅអំឡុងពីឆ្នាំ 2023 ដល់ 2043។ បន្ទាប់ពីឆ្នាំ 2043 ភាគលាភប្រជាសាស្ត្រនឹងមានលក្ខណៈអវិជ្ជមាន នៅពេលប្រជាជនចាស់ជរានឹងធ្វើឲ្យមានការថយចុះកំណើនចំណូលសម្រាប់មនុស្សម្នាក់ៗ (ប្រមាណ 0.5 ភាគរយពិន្ទុនៅអំឡុងឆ្នាំ 2043 និង 48 សូមមើលរូប S14)[៤៣]។

**ប្រសិនបើកម្ពុជានៅតែមានអត្រាកំណើនដូចពេលបច្ចុប្បន្ននេះ ចំពោះទិន្នន័យគោលធម្មតា កម្ពុជានឹងមិនសម្រេចបានគោលដៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់បានឡើយ** (រូប S15)។ កម្ពុជាត្រូវមានអត្រាកំណើន 9.3 ភាគរយសម្រាប់មនុស្សម្នាក់ៗ ដើម្បីក្លាយជាប្រទេស ដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ 2030 ប៉ុន្តែ អត្រាកំណើនសម្រាប់មនុស្សម្នាក់ ៗត្រឹម 6% ក្នុងទិន្នន័យគោលធម្មតា និងអត្រា 5 ភាគរយក្នុងទិន្នន័យគោលកម្រិតទាប កើតមាននៅអំឡុងពេលនោះ ដូចបង្ហាញនៅក្នុងរូប S13 ដែលធ្វើឲ្យមិនអាចសម្រេចបានប្រាក់ចំណូលជាតិដុលសម្រាប់មនុស្សម្នាក់ៗមានចំនួនតិចជាង 2 ភាគ 3 នៃគោលដៅ។ គោលដៅជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ 2050 តម្រូវឲ្យមានកំណើនចំណូល 7.2 ភាគរយសម្រាប់មនុស្សម្នាក់ៗ

**រូប S12 ៖ អត្រាកំណើន ផសស ពិតរបស់កម្ពុជា**




*ប្រភព* ៖ លំនាំកំណើនរបស់ក្រុមធនាគារពិភពលោក

**រូប S13 ៖ អត្រាកំណើន ផសស សម្រាប់មនុស្សម្នាក់ៗនៅកម្ពុជា**




*ប្រភព* ៖ លំនាំកំណើនរបស់ក្រុមធនាគារពិភពលោក

**រូប S14 ៖ ប្រជាសាស្ត្ររបស់កម្ពុជា**




*ប្រភព* ៖ លំនាំកំណើនរបស់ក្រុមធនាគារពិភពលោក

**រូប S15 ៖ កម្រិតចំណូលម្នាក់ៗរបស់កម្ពុជា**




*ប្រភព* ៖ លំនាំកំណើនរបស់ក្រុមធនាគារពិភពលោក

៤២ នៅក្នុងទិន្នន័យគោលអភិរក្ស ការថយចុះកំណើនប្រជាជនបានបង្កើនកំណើន ផសស សម្រាប់មនុស្សម្នាក់ៗប្រមាណ 0.2 ភាគរយពិន្ទុ និងបន្ថយតួលេខកំណើននៃ ផសស សម្រាប់មនុស្សម្នាក់ៗប្រមាណ 0.8 ភាគរយ។

៤៣ នៅប្រទេសកូរ៉េ ការប្រែប្រួលផលធៀបនៃប្រជាជនគ្រប់អាយុធ្វើការ និងការចូលរួមក្នុងកម្លាំងពលកម្ម បានបន្ថែមប្រមាណ 0.5 ភាគរយពិន្ទុដល់កំណើននៅអំឡុងពីឆ្នាំ 1960 ដល់ 2014 (Jeong 2017)។

ដែលនៅតែលើសអត្រាកំណើនមធ្យមភាគ 5.4-6.4 ភាគរយ សម្រាប់មនុស្សម្នាក់ៗនៃទិន្នន័យគោលមធ្យមក្នុងអំឡុងពេលនេះ ដែលធ្វើឲ្យប្រាក់ចំណូលជាតិដុលសម្រាប់មនុស្សម្នាក់ៗស្មើនឹង 1 ភាគ 4 នៃគោលដៅ។

## កម្ពុជាអាចសម្រេចបានគោលដៅកំណើន (ខ្លះ) តាមរយៈការបង្កើនការវិនិយោគខ្ពស់ជាងមុន

### ក) បើតាមលំនាំ "ការវិនិយោគដូចប្រទេសកូរ៉េ" កម្ពុជានឹងសម្រេចបានគោលដៅជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ 2050 ប៉ុន្តែនឹងមិនសម្រេចបានគោលដៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ឡើយ

**ដើម្បីពន្លឿនកំណើន កម្ពុជាប្រហែលជាត្រូវអនុវត្តតាមគន្លងរបស់ប្រទេសម៉ាឡេស៊ី ឬកូរ៉េ ដោយត្រូវបង្កើនអត្រាវិនិយោគដល់ 28 និង 38 ភាគរយនៅឆ្នាំ 2030។** រូប S10 បានបង្ហាញថា ទាំងប្រទេសកូរ៉េ និងម៉ាឡេស៊ី សុទ្ធតែបានចាប់ផ្តើមពីអត្រាវិនិយោគប្រហាក់ប្រហែលនឹងអត្រាវិនិយោគរបស់កម្ពុជាបច្ចុប្បន្ន ប៉ុន្តែក្រោយមក បានបង្កើនអត្រា 28 (កូរ៉េ) ទៅ 33 (ម៉ាឡេស៊ី) ភាគរយនៃ ផសស ក្នុងរយៈពេល 15 ឆ្នាំ។ បទពិសោធន៍របស់ប្រទេសកូរ៉េមានភាពពាក់ព័ន្ធបំផុត ដោយសារតែកូរ៉េអាចសម្រេចបានចំណាត់ថ្នាក់ជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ក្នុងរយៈពេល 33 ឆ្នាំ បន្ទាប់ពីកូរ៉េមានកម្រិតអភិវឌ្ឍន៍ស្មើកម្រិតរបស់កម្ពុជានាពេលបច្ចុប្បន្ន។ ជាក់ស្តែង លំនាំរបស់យើងចាប់ផ្តើមដោយទិន្នន័យគោលធម្មតា រួចបង្កើនឲ្យដល់អត្រាវិនិយោគរបស់កូរ៉េ ដែលមាន 33 ភាគរយនៃ ផសស នៅឆ្នាំ 2030។ លំនាំទីពីររបស់យើងចាប់ផ្តើមពីទិន្នន័យគោលអភិរក្ស និងបង្កើនអត្រាវិនិយោគឲ្យដល់អត្រារបស់ម៉ាឡេស៊ី ដែលមាន 28 ភាគរយនៃ ផសស នៅឆ្នាំ 2030។

**ជាមួយនឹងកំណើនវិនិយោគយ៉ាងលឿន និងប៉ារ៉ាម៉ែត្រទិន្នន័យគោលមធ្យមផ្សេងទៀត កម្ពុជានឹងសម្រេចបានគោលដៅជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ឆ្នាំ 2050 ប៉ុន្តែនឹងមិនសម្រេចបានគោលដៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ឆ្នាំ 2030** (រូប S17)។ រូប S16 បង្ហាញពីលំនាំកំណើននៃអត្រាវិនិយោគតាមលំនាំទីមួយរបស់យើង ដែលជា "ការវិនិយោគដូចប្រទេសកូរ៉េ" ដោយការវិនិយោគកើនឡើង 11 ភាគរយពិន្ទុនៃ ផសស (កើនពី 22 ភាគរយ ដល់ 33 ភាគរយ)

**រូប S16 ៖ ផលធៀបនៃការវិនិយោគ និង ផសស នៅកម្ពុជា**




*ប្រភព* ៖ លំនាំកំណើនរបស់ក្រុមធនាគារពិភពលោក

**រូប S17 ៖ កម្រិតចំណូលម្នាក់ៗនៅកម្ពុជា**

(ធៀបនឹងអត្រាវិនិយោគរបស់កូរ៉េពីឆ្នាំ 2030)




*ប្រភព* ៖ លំនាំកំណើនរបស់ក្រុមធនាគារពិភពលោក

**រូប S18 ៖ អត្រាកំណើន ផសស សម្រាប់មនុស្សម្នាក់ៗនៅកម្ពុជា**




*ប្រភព* ៖ លំនាំកំណើនរបស់ក្រុមធនាគារពិភពលោក

**រូប S19 ៖ អត្រាកំណើន ផសស ពិតនៅកម្ពុជា**




*ប្រភព* ៖ លំនាំកំណើនរបស់ក្រុមធនាគារពិភពលោក

នៅអំឡុងឆ្នាំ 2018 និង 2030។ ការវិនិយោគបន្ថែមបានបង្កើនកំណើនជិត 2.5 ភាគរយពិន្ទុនៅឆ្នាំ 2031 ដែលធ្វើឲ្យមានកំណើនសម្រាប់មនុស្សម្នាក់ៗ មានចំនួន 8.8 ភាគរយ (រូប S18) និងបង្កើនកំណើនដល់ជិត 10 ភាគរយ (រូប S19)។ ប៉ុន្តែកម្រិតចំណូលសម្រាប់មនុស្សម្នាក់នៅតែធ្លាក់តិចជាងប្រហែល 20 ភាគរយ សម្រាប់គោលដៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ 2030 ដែលបង្ហាញក្នុងរូប S17 មួយផ្នែក ដោយសារតែមហិច្ឆិតានៃគោលដៅនោះ និងមួយផ្នែកទៀតដោយសារតែការបង្កើនអត្រាវិនិយោគ ក្នុងរយៈពេលជាងមួយទសវត្សរ៍ (ដូចនៅប្រទេសកូរ៉េ)។ ចំណុចវិជ្ជមានមួយវិញទៀត កម្ពុជាពិតជាសម្រេចបានគោលដៅជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់។ តាមពិត កម្ពុជានឹងសម្រេចបានលើសពីគោលដៅឆ្នាំ 2050 ទៅទៀត ដោយកម្ពុជាគ្រាន់តែត្រូវសម្រេចឲ្យបានផលធៀបនៃការវិនិយោគ និង ផសស ប្រមាណ 28.3 ភាគរយពីឆ្នាំ 2030 ដើម្បីសម្រេចបានគោលដៅនោះ។

### ខ) ប្រសិនបើការវិនិយោគមានលំនាំតាមប្រទេសម៉ាឡេស៊ី និងយកការសន្មតកម្រិតទាប (ទំនងជាមានភាពជាក់ស្តែង) សម្រាប់ចំណែកមូលធន កម្ពុជានឹងមិនសម្រេចបានគោលដៅកំណើនទាំងពីរ

**ដូច្នេះ ផ្អែកតាមការសន្មតអភិរក្ស (និងទំនងជាមានភាពជាក់ស្តែង) ពាក់ព័ន្ធនឹងការវិនិយោគ និងចំណែកមូលធន កម្ពុជានឹងមិនអាចសម្រេចបានគោលដៅកំណើនទាំងពីរនេះបានឡើយ។** រូប S20 បង្ហាញពីកំណើនអត្រាវិនិយោគតាមលំនាំរបស់យើង “ការវិនិយោគដូចប្រទេសម៉ាឡេស៊ី ដែលការវិនិយោគកើនឡើង 8 ភាគរយពិន្ទុនៃ ផសស (កើនពី 20 ភាគរយ ដល់ 28 ភាគរយ) នៅអំឡុងឆ្នាំពី 2018 ដល់ 2030 ដោយមានចំណែកមូលធនចំនួន 50 ភាគរយ។ ដោយសារតែអត្រាប្រាក់សន្សំទាបរបស់កម្ពុជា ហើយមានការពឹងផ្អែកខ្លាំងលើប្រាក់សន្សំពីបរទេសតាមរយៈការវិនិយោគផ្ទាល់ពីបរទេស ការបង្កើនការវិនិយោគយ៉ាងច្រើនប្រហែលជាមិនអាចធ្វើបានឡើយ។ ការវិនិយោគបន្ថែមបានធ្វើឲ្យមានកំណើនជិត 1.5 ភាគរយពិន្ទុនៅឆ្នាំ 2031 ដែលធ្វើឲ្យមានកំណើនសម្រាប់មនុស្សម្នាក់ៗចំនួន 7 ភាគរយ (គ្មានរបាយការណ៍) និងកំណើនជិត 8 ភាគរយ (រូប S22)។ គួរឲ្យសោកស្តាយ កម្ពុជាមិនអាចសម្រេចបានគោលដៅទាំងអស់នេះ ដោយមិនសម្រេចបានគោលដៅជាប្រទេស ដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ (ទោះបីជានៅឆ្ងាយពីចំណុចគោលដៅ) ហើយកម្ពុជាបច្ចុប្បន្នមិន

**រូប S20 ៖ ផលធៀបនៃការវិនិយោគ និង ផសស នៅកម្ពុជា**




*ប្រភព* ៖ លំនាំកំណើនរបស់ក្រុមធនាគារពិភពលោក

**រូប S21 ៖ កម្រិតចំណូលម្នាក់ៗនៅកម្ពុជា (កម្រិតទាប)**

(ដោយមាន វិនិយោគ ពីឆ្នាំ 2030)




*ប្រភព* ៖ លំនាំកំណើនរបស់ក្រុមធនាគារពិភពលោក

**រូប S22 ៖ អត្រាកំណើន ផសស ពិតនៅកម្ពុជា**




*ប្រភព* ៖ លំនាំកំណើនរបស់ក្រុមធនាគារពិភពលោក

**រូប S23 ៖ ផលធៀបនៃទុន និងផល កើនឡើង (តិចតួច)**(ICOR)




*ប្រភព* ៖ លំនាំកំណើនរបស់ក្រុមធនាគារពិភពលោក

អាចសម្រេចបានគោលដៅជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ 2050 ក្នុងអត្រា 25 ភាគរយ ដូចបង្ហាញក្នុងរូប S21។

**កម្ពុជាមិនសម្រេចបានគោលដៅកំណើនរបស់ខ្លួន នៅក្នុងលំនាំទិន្នន័យគោលកម្រិតទាបទីពីរឡើយ ដោយសារតែអត្រាវិនិយោគទាប ហើយផលប៉ះពាល់នៃការវិនិយោគលើកំណើនមានកម្រិតទាប។** គេអាចប្រើ លំនាំកំណើនរយៈពេលវែង ដើម្បីវាស់វែងពីប្រសិទ្ធភាពនៃការវិនិយោគក្នុងការជំរុញកំណើន តាមរយៈអត្រាកំណើនបន្ថិចនៃផលធៀបទុន និងផល ដែលជាទំហំនៃកំណើនការវិនិយោគចាំបាច់ដើម្បីធ្វើឲ្យមានកំណើនបន្ថែម 1 ភាគរយកំណើន (ផ្ទុយទៅនឹងកំណើនផលនៃមូលធន)[៤៤]។ អត្រាកំណើនខាងលើត្រូវបានគណនាជាផលធៀបមូលធន និងផល (ជំហ៊ាន 2 ក្នុងលំនាំទាំងអស់) ចែកនឹងចំណែកមូលធននៃចំណូល (1 ចំណែកកម្លាំងពលកម្ម)។ ចំណែកមូលធនមានចំនួន 0.6 ក្នុងទិន្នន័យគោលមធ្យម ប៉ុន្តែ មានអត្រា 0.5 ភាគរយក្នុងទិន្នន័យគោលកម្រិតទាប។ លំនាំនេះផ្តល់អត្រាកំណើនបន្ថែមចំនួន 3.3 (ជាមធ្យម) ធៀបនឹង 4 (កម្រិតទាប)។ មានន័យថា កំណើនបន្ថែមមួយឯកតា ត្រូវមានការវិនិយោគបន្ថែម 20% នៅក្នុងប៉ារ៉ាម៉ែត្រកម្រិតទាប (រូប S23)។

**អត្រាវិនិយោគខ្ពស់ក៏មិនសូវមានប្រសិទ្ធភាពក្នុងការជំរុញកំណើនក្នុងអំឡុងពេលមួយដែរ។** តាមភាពសកម្ម កំណើនដែលជំរុញដោយការវិនិយោគ ធ្វើឲ្យមានកំណើនបរិមាណមូលធនឡើងលឿនជាង ផសស និងធ្វើឲ្យមានកំណើនផលធៀបមូលធន និងផលិតផល ហើយអត្រាកំណើនបន្ថែម ដូច្នេះហើយ ធ្វើឲ្យប្រសិទ្ធភាពនៃការវិនិយោគថយចុះ។ នេះគឺជាហេតុផលដែលថាសន្ទុះកំណើនថយចុះក្រោយឆ្នាំ 2031 នៅក្នុងលំនាំទាំងអស់ដែលមានការវិនិយោគខ្ពស់ (រូប S18 S19 S22) ដូចជា នៅឆ្នាំ 2050 (ប៉ារ៉ាម៉ែត្រកម្រិតទាប) កំណើនបន្ថែម 1 ឯកតា ត្រូវមានការវិនិយោគបន្ថែម 30 ភាគរយ (អត្រាកំណើនបន្តិចបន្ថែម=4.7) ដែលខ្ពស់ជាងក្នុងទិន្នន័យគោល (អត្រាកំណើនបន្តិចបន្ថែម=3.65)។

## គ) ផលប៉ះពាល់នៃប្រាក់សន្សំដែលតម្រូវឲ្យមាន

**ក្នុងរយៈពេលវែង ឱនភាពគណនីចរន្តអាចនឹងថយពីកម្រិតកំណើនបច្ចុប្បន្ន។** ប្រមាណ 9 ភាគរយពិន្ទុនៃអត្រាវិនិយោគ 22 ភាគរយ ទទួលបានហិរញ្ញប្បទានពីប្រាក់សន្សំពីបរទេស ដែលជាឱនភាពគណនីចរន្តមួយ។ តុល្យភាពគណនីចរន្តក្នុងប្រទេសនានា (ឧ. ម៉ាឡេស៊ី និងកូរ៉េ) មានអត្រាជាមធ្យម -2 ភាគរយនៃ ផសស ក្នុងរយៈពេលជាង 20 ឆ្នាំ ចាប់ពីពេលដែលមានទិន្នន័យរហូតដល់ពេលមានវិបត្តិហិរញ្ញវត្ថុនៅអាស៊ី (រូប S24) ទោះបីជាតុល្យភាពគណនីចរន្តងាយប្រែប្រួលក្នុងអំឡុងពេលនោះក្តី។ ក្នុងរយៈពេល 20 រហូតដល់ឆ្នាំ 2012 តុល្យភាពគណនីចរន្តរបស់កម្ពុជាមានកម្រិតថេរត្រឹម -5 ភាគរយនៃ ផសស ដែលជាញឹកញាប់ត្រូវបានចាត់ទុកថាកម្រិតកំណត់សម្រាប់ឱនភាពដែលគ្មាននិរន្តរភាព។ ទោះបីជាឱនភាពគណនីចរន្តរបស់កម្ពុជាកើតមានដោយសារតែការវិនិយោគផ្ទាល់ពីបរទេសក្តី ប៉ុន្តែ ឱនភាពនេះបាត់ទៅវិញក្នុងអំឡុងពេលនៃលំនាំនេះ។ តាមបទពិសោធន៍របស់កម្ពុជា យើងសន្មតថា តុល្យភាពគណនីចរន្តមានអត្រា -5 ភាគរយនៃ ផសស នៅឆ្នាំ 2030 (រូប S25)។

**ដើម្បីរក្សាអត្រាវិនិយោគបច្ចុប្បន្ន ឬតម្លើងការវិនិយោគ ដើម្បីសម្រេចបានគោលដៅកំណើន កម្ពុជាត្រូវបង្កើនអត្រាប្រាក់សន្សំយ៉ាងច្រើន** (រូប S25)។ ដោយសារតែការសន្មតពីគន្លងនៃការវិនិយោគ និងតុល្យភាពគណនីចរន្ត គេអាចគណនាយ៉ាងងាយស្រួលពីអត្រាប្រាក់សន្សំចាំបាច់ គិតជាចំណែក នៃ ផសស ស្មើនឹងផលបូករវាងអត្រាវិនិយោគ និងតុល្យភាពគណនីចរន្ត (ចំណែកនៃ ផសស)។

**រូប S24 ៖ ម៉ាឡេស៊ី និងកូរ៉េ ៖ ប្រាក់សន្សំ និងតុល្យភាពគណនីចរន្ត** (ភាគរយនៃ ផសស)

រយៈពេលជាង 20 ឆ្នាំមុនពេលមានវិបត្តិហិរញ្ញវត្ថុអាស៊ី




*ប្រភព* ៖ សូចនាករអភិវឌ្ឍន៍ពិភពលោក

*សម្គាល់* ៖ *នៅឆ្នាំ 1998 តុល្យភាពគណនីចរន្តមានអតិរេកជាង 10 ភាគរយនៃ ផសស។

**រូប S25 ៖ ប្រាក់សន្សំ និង CAB នៅកម្ពុជា**

(ភាគរយនៃ ផសស)




*ប្រភព* ៖ សូចនាករអភិវឌ្ឍន៍ពិភពលោក

៤៤ កំណើននៃផលធៀបនៃទុន និងផល បែបធម្មតា ត្រូវបានវាស់វែងដោយផលធៀបនៃការវិនិយោគ និងកំណើន ហើយត្រូវបានប្រើប្រាស់ជាគោលការណ៍ណែនាំសម្រាប់អនុវត្តសម្រាប់ការវាស់វែងប្រសិទ្ធភាពការវិនិយោគ។ កំណើននៃផលធៀបនៃទុន និងផលបន្តិច គឺជាលំនាំប្រហាក់ប្រហែលនៃលំនាំកំណើនរយៈពេលវែង ដែលបង្ហាញថា កំណើនរងការប៉ះពាល់ដោយសារកត្តាក្រៅពីការវិនិយោគផ្សេងៗទៀត។

បច្ចុប្បន្ន កម្ពុជាមានអត្រាប្រាក់សន្សំប្រមាណ 13 ភាគរយនៃ ផសស។ ដូច្នេះ ដើម្បីរក្សាបានអត្រាវិនិយោគបច្ចុប្បន្ន កម្ពុជាត្រូវបង្កើនអត្រាប្រាក់សន្សំឲ្យបាន 17 ភាគរយនៃ ផសស ត្រឹមឆ្នាំ 2030 (កំណើន ផសស 4 ភាគរយ)។ ប្រសិនបើកម្ពុជាបង្កើនអត្រាវិនិយោគស្មើអត្រារបស់ប្រទេសកូរ៉េ (33 ភាគរយនៃ ផសស ត្រឹមឆ្នាំ 2030) អត្រាប្រាក់សន្សំត្រូវកើនឡើង 28 ភាគរយនៃ ផសស (កំណើន ផសស 15 ភាគរយ)។ អត្រាប្រាក់សន្សំក្នុងប្រទេសម៉ាឡេស៊ី និងប្រទេសកូរ៉េ មានចំនួនជាមធ្យម 30 ភាគរយនៃ ផសស ក្នុងរយៈពេលជាង 15 ឆ្នាំក្រោយពីប្រទេសទាំងនេះមានកម្រិតស្មើនឹងកម្រិតអភិវឌ្ឍន៍បច្ចុប្បន្នរបស់កម្ពុជា ដោយមាននិន្នាការកើនឡើងខ្ពស់ ដូចបង្ហាញក្នុងរូប S24។ ប្រអប់ S1 ផ្តល់ព័ត៌មានបន្ថែមស្តីពីបណ្តាប្រទេសនានា ចំណែកប្រអប់ S2 បង្ហាញពីវិធីដែលកម្ពុជាអាចប្រើប្រាស់គោលនយោបាយដើម្បីជំរុញអត្រាប្រាក់សន្សំកាន់តែខ្ពស់។

## បញ្ហាប្រឈមក្នុងការរក្សាកំណើន៖ ភស្តុតាងពីប្រទេសផ្សេងៗ

> "តាមពិត ប្រទេសកំពុងអភិវឌ្ឍន៍ទាំងអស់ សុទ្ធតែឆ្លងកាត់កំណើនខ្លាំង និងការធ្លាក់ចុះក្នុងរយៈពេលយូរ (10-15 ឆ្នាំ) ប៉ុន្តែ ការរក្សាកំណើនគឺជាការលំបាក និងអាចបង្កជាបញ្ហាប្រឈមផ្សេងៗទៀត" (Jones និង Olken 2008)

**ចំណុចគន្លឹះសម្រាប់ការអភិវឌ្ឍរយៈពេលវែង គឺការរក្សាកំណើន មិនមែនជាការពន្លឿនកំណើនទេ។** សហរដ្ឋអាមេរិក ដែលជាប្រទេសមានជាងគេបំផុតក្នុងសកលលោក មិនដែលមានកំណើនលឿនពេកនោះទេ។ ផ្ទុយទៅវិញ អាមេរិករក្សាបានអត្រាកំណើន 2 ភាគរយសម្រាប់មនុស្សម្នាក់ៗក្នុងរយៈពេលជាងមួយសតវត្សរ៍មកហើយ (រូប S26 ៖ ដកស្រង់ចេញពី Jones 2016)។ ប្រទេសផ្សេងៗទៀតនៅអាស៊ី ដូចជា សិង្ហបុរី ម៉ាឡេស៊ី និងកូរ៉េ សម្រេចបានអត្រាកំណើនលឿន ប៉ុន្តែ ប្រទេសទាំងនេះនៅតែរក្សាបានអត្រាកំណើនក្នុងរយៈពេលវែង។ ស្ថានភាពនេះមានការពាក់ព័ន្ធខ្លាំងចំពោះមហិច្ឆិតារបស់កម្ពុជាក្នុងការសម្រេចបានគោលដៅជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ 2050 ដែលតម្រូវឲ្យមានការរក្សាកំណើនក្នុងរយៈពេលជាង 30 ឆ្នាំ។

យោងតាមអត្ថបទខាងលើដកស្រង់ពី Jones និង Olken (2008) បានស្នើថា អំឡុងពេលដែលមានកំណើនលឿនកើតមានជាទូទៅក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ ប៉ុន្តែ ការលំបាកនោះគឺ ការមិនអាចរក្សាកំណើនបាន ហើយផ្ទុយទៅវិញ ប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ៗនៅថេរ ឬមានការថយចុះផង។ បទពិសោធន៍ផ្ទាល់របស់កម្ពុជាបង្ហាញច្បាស់ពីចំណុចនេះ គឺថា ទោះបីជាកំណើនមានស្ថិរភាពបង្គួរ ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1980 ក្តី ក៏អស្ថិរភាពនយោបាយកន្លងមក ធ្វើឲ្យប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ៗថយចុះយ៉ាងលឿន (រូប S27)។

**អ្នកតាក់តែងគោលនយោបាយនៅកម្ពុជា អាចពិចារណាពីគោលនយោបាយបង្កើនពេលវេលាដែលមានកំណើនខ្ពស់ ក្រៅពីគោលនយោបាយបង្កើនកំណើនរបស់ខ្លួន។** Berg, Ostry និង Zettelmeyer (2012) បានលើកឡើងពីគោលនយោបាយផ្សេងៗដែលពាក់ព័ន្ធនឹងការបង្កើនរយៈពេលកំណើន។ ទីមួយ ពួកគេរកឃើញថា ប្រទេសដែលមានការរីកចម្រើនលឿន មានកំណើនមិនថេរទេ ហើយចំណុចនេះស៊ីសង្វាក់ទៅនឹង កំណើននៃប្រទេសដែលមានអតិផរណាខ្ពស់ មានលទ្ធភាពខ្ពស់ក្នុងការមានសេដ្ឋកិច្ចធ្លាក់ចុះ[៤៥]។ ទីពីរ ពួកគេរកឃើញថា ប្រទេសដែលមានសមភាព មានស្ថាប័នប្រជាធិបតេយ្យ មានការនាំចេញច្រើន និងមានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចរឹងមាំ មានលទ្ធភាពខ្ពស់ក្នុងការរក្សាបាននូវកំណើនរយៈពេលវែង។ កម្ពុជាទទួលបានចំណាត់ថ្នាក់ល្អលើផ្នែកជាច្រើន ដូចជា សមភាពសេដ្ឋកិច្ច (មេគុណ Gini ទាបក្នុងរង្វង់ 0.31) ការនាំចេញច្រើន (អត្រាវិនិយោគផ្ទាល់ពីបរទេសខ្ពស់ និងកំណើនការនាំចេញដ៏រឹងមាំ) និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ អញ្ញត្តិនៃនយោបាយក៏សំខាន់ផងដែរ។ Berg, Ostry និង Zettelmeyer (2012) រកឃើញថា បញ្ហាដោយសារតែអំណាចផ្នែកនីតិប្រតិបត្តិ និងការប្រកួតប្រជែងនយោបាយហាក់ដូចជាពាក់ព័ន្ធនឹងកំណើនដែលមានស្ថិរភាព ចំណែកការគ្រប់គ្រងប្រទេសជាគ្រួសារពាក់ព័ន្ធនឹងកំណើនដែលមិនសូវមានស្ថិរភាព។

**រូប S26 ៖ សហរដ្ឋអាមេរិក ៖ ផសស ពិតសម្រាប់មនុស្សម្នាក់ៗ**




*ប្រភព* ៖ Jones (2016)

**រូប S27 ៖ កម្រិត ផសស សម្រាប់មនុស្សម្នាក់ៗនៅកម្ពុជា**




*ប្រភព* ៖ PWT9

[៤៥] តុល្យភាពគណនីចរន្ត និងអត្រាប្រាក់សន្សំកាន់តែខ្ពស់ ពេលខ្លះ ក៏ពាក់ព័ន្ធនឹងកំណើនរយៈពេលយូរផងដែរ។

**ប្រអប់ S1**

## បទពិសោធន៍ក្នុងតំបន់[១]

ប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងថៃ ជាប្រទេសបីក្នុងចំណោមប្រទេសទាំង 8 នៅអាស៊ីបូព៌ាដែលមានកំណើនសេដ្ឋកិច្ចលឿននៅអំឡុងឆ្នាំ 1960 និង 1990 ហើយគេហៅកំណើននេះថាជា “ភាពអស្ចារ្យនៃអាស៊ីបូព៌ា”។ ការវិនិយោគកម្រិតខ្ពស់ ជាពិសេសក្នុងវិស័យឯកជន រួមជាមួយនឹងធនធានមនុស្សខ្ពស់ និងមានចំនួនកើនឡើង ដោយសារអត្រាខ្ពស់នៃការបញ្ចប់ការសិក្សាកម្រិតបឋមសិក្សា និងមធ្យមសិក្សា គឺជាគន្លឹះនៃភាពជោគជ័យរបស់ប្រទេសទាំងនេះ។ រដ្ឋាភិបាលប្រទេសទាំងនេះបានចំណាយថវិកាច្រើនលើការអប់រំកម្រិតទាបជាមុន ដោយផ្តល់ការអប់រំបឋមសិក្សាគ្រប់គ្នា និងបង្កើនការអប់រំកម្រិតមធ្យមសិក្សា។ ចំណែកថវិកាអប់រំជាង 3 ភាគ 4 ផ្តោតលើបឋមសិក្សា និងមធ្យមសិក្សា។ ទន្ទឹមនឹងនេះ ការប្រែប្រួលផ្នែកប្រជាសាស្ត្រយ៉ាងលឿនបានជួយសម្រួលដល់កិច្ចខិតខំប្រឹងប្រែងទាំងនេះ។ ការថយចុះនៃអត្រាបង្កកំណើត និងកំណើនសេដ្ឋកិច្ចលឿន មានន័យថា សូម្បីតែការវិនិយោគលើវិស័យអប់រំជាចំណែកនៃ ផសស មានអត្រាថេរ ក៏មានធនធានច្រើនសម្រាប់កុមារម្នាក់ៗដែរ។ រដ្ឋាភិបាលបានកម្រិតហិរញ្ញប្បទានសាធារណៈលើការអប់រំក្រោយមធ្យមសិក្សា ដែលផ្តោតជាសំខាន់លើជំនាញបច្ចេកទេស។

ប្រទេសម៉ាឡេស៊ី និងថៃ បានប្រើប្រាស់ការជំនួសការនាំចូល និងការលើកទឹកចិត្តការនាំចេញយ៉ាងច្រើន ទន្ទឹមនឹងការងាកចេញពីការនាំចេញផ្អែកលើធនធានទៅជាការនាំចេញផ្អែកលើកម្មន្តសាល។ គោលនយោបាយអត្រាប្តូរប្រាក់ត្រូវបានធ្វើសេរីភាវូបនីយកម្ម ហើយរូបិយវត្ថុត្រូវបានទម្លាក់ថ្លៃជាញឹកញាប់ដើម្បីជំរុញកំណើននាំចេញ។ ជារួមគោលនយោបាយទាំងនេះធ្វើឲ្យវិស័យឧស្សាហកម្មប្រឈមមុខនឹងការប្រកួតប្រជែងអន្តរជាតិ និងធ្វើឲ្យតម្លៃក្នុងស្រុកប្រហាក់ប្រហែលគ្នានឹងតម្លៃអន្តរជាតិជាងនៅប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត។ ក្រោមគោលនយោបាយសេដ្ឋកិច្ចថ្មីរបស់ម៉ាឡេស៊ីនៅឆ្នាំ 1971 ការជំរុញការនាំចេញសំខាន់ៗ ដូចជា ការបន្ថយអត្រាពន្ធលើប្រាក់ចំណូលដែលពាក់ព័ន្ធនឹងដំណើរការនាំចេញ និងវត្ថុធាតុដើមក្នុងស្រុក ការអនុគ្រោះពន្ធសម្រាប់ការចំណាយលើការជំរុញការនាំចេញ និងការបន្ថយថ្លៃរបស់ក្រុមហ៊ុននាំចេញជាង 20 ភាគរយនៃផលិតផលនាំចេញរបស់ខ្លួន។ គោលនយោបាយឥណទានបានជំរុញការនាំចេញ តាមរយៈការធានា និងការបញ្ចុះតម្លៃដោយស្វ័យប្រវត្តិលើហិរញ្ញប្បទានការនាំចេញ ដែលទទួលបានអត្រាការប្រាក់ទាប។ តំបន់កែច្នៃនាំចេញ តំបន់ពាណិជ្ជកម្មសេរី និងឃ្លាំងកម្មន្តសាលដែលទទួលបានអាជ្ញាប័ណ្ណ ដែលអនុញ្ញាតឲ្យនាំចូលវត្ថុធាតុដើមដោយមិនជាប់ពន្ធ ដើម្បីធ្វើការផ្គុំ ឬកែច្នៃសម្រាប់ការនាំចេញ មានសារៈសំខាន់ណាស់សម្រាប់ការបញ្ចូលគ្នាដោយជោគជ័យនៃការជំនួសការនាំចូល និងការជំរុញការនាំចេញ។ នៅឆ្នាំ 1980 ការនាំចេញផលិតផលកម្មន្តសាលប្រមាណ 70 ភាគរយ ចេញមកពីតំបន់កែច្នៃសម្រាប់ការនាំចេញ ជាពិសេសក្រុមហ៊ុនគ្រប់គ្រងដោយបរទេស។

**រូប SB1 ៖ ការចំណាយរបស់រដ្ឋាភិបាលលើវិស័យអប់រំ**

(% នៃ ផសស)




*ប្រភព* ៖ WDI និង ADB

នៅទសវត្សរ៍ឆ្នាំ 1970 ប្រទេសថៃបានអនុវត្តយុទ្ធសាស្ត្រជំនួសការនាំចូល ដូចប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងៗទៀត តាមរយៈការបង្កើនពន្ធនាំចូលលើទំនិញប្រើប្រាស់ដល់ 30 ទៅ 55 ភាគរយ។ មូលធន និងទំនិញពាក់កណ្តាលសម្រេច មានពន្ធទាប។ វាយនភណ្ឌ ឱសថ និងគ្រឿងបង្គុំយានយន្តទទួលបានការអនុគ្រោះពិសេស។ ការនាំចូលយានជំនិះត្រូវបានហាមឃាត់ជាច្រើនលើកច្រើនសា។ លក្ខខណ្ឌនៃការប្រើប្រាស់ធនធានក្នុងស្រុក បានបង្កើនថ្លៃផលិតកម្មក្នុងវិស័យផ្គុំតម្លើង ហើយក៏មានការផ្តល់ឧបត្ថម្ភធនដល់ក្រុមហ៊ុនផលិតវត្ថុធាតុដើមដែរ។ វិបត្តិប្រេងលើកទីពីរបានធ្វើឲ្យសេដ្ឋកិច្ចថៃធ្លាក់ចុះ ដែលមានគោលនយោបាយជំនួសការនាំចូលនៅទសវត្សរ៍ឆ្នាំ 1970។ នៅឆ្នាំ 1981 គោលនយោបាយពាណិជ្ជកម្មរបស់ប្រទេសថៃផ្តោតលើការជំរុញការនាំចេញ។ ឥណទានដោយស្វ័យប្រវត្តិ និងមានលក្ខណៈជាសម្បទាន គឺជាចំណុចសំខាន់មួយទៀតក្នុងយុទ្ធសាស្ត្រជំរុញការនាំចេញ។ ធនាគារប្រទេសថៃបានបង្កើនការផ្តល់ហិរញ្ញប្បទាន តាមរយៈធនាគារពាណិជ្ជសម្រាប់វិស័យសេដ្ឋកិច្ចសំខាន់ៗ។ ជាផ្នែកមួយនៃយុទ្ធសាស្ត្រជំរុញការនាំចេញ ធនាគារប្រទេសថៃបានកែសម្រួលវិធានស្តីពីការចុះថ្លៃរបស់ខ្លួនដោយផ្តោតកាន់តែខ្លាំងលើក្រុមហ៊ុននាំចេញខ្នាតតូច និងថ្មីៗ និងសកម្មភាពប្រកបដោយផលិតភាពផ្សេងៗទៀត។

ការផ្លាស់ប្តូរផ្នែកគោលនយោបាយទាំងនេះបានផ្តល់លទ្ធផលយ៉ាងធំធេង។ នៅឆ្នាំ 1986 កម្មន្តសាលធុនស្រាលមានចំនួន 30.6 ភាគរយនៃការនាំចេញសរុបរបស់ប្រទេសថៃដែលមានកំណើន។ វិស័យសំខាន់ៗរួមមាន សម្លៀកបំពាក់ ស្បែកជើង ផ្កាសិប្បនិម្មិត គ្រឿងអលង្ការ និងសៀគ្វីអគ្គិសនី។ ការវិនិយោគផ្ទាល់ពីបរទេសមានតួនាទីសំខាន់ក្នុងការជំរុញការនាំចេញ ព្រោះថា ក្រុមហ៊ុនមកពីប្រទេសអភិវឌ្ឍន៍នៅអាស៊ីបានផ្លាស់ទីតាំងផលិតកម្មផ្នែកកម្មន្តសាលដែលត្រូវការកម្លាំងពលកម្មច្រើន ទៅក្រៅប្រទេសខ្លួន។

---

១ រៀបរៀងដោយ ភឹម រុនស៊ីណារិទ្ធ ទីប្រឹក្សាធនាគារពិភពលោក។

ប្រអប់ S2

## ការជំរុញការសន្សំប្រាក់[១]

ប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងថៃ បានបង្កើនអត្រាប្រាក់សន្សំ និងការវិនិយោគតាមរយៈគោលនយោបាយសំខាន់ៗ និងការអន្តរាគមន៍ផ្សេងៗ។ គោលនយោបាយសំខាន់ៗពីរបានផ្ដល់ជាមូលដ្ឋានសម្រាប់អត្រាប្រាក់សន្សំខ្ពស់ និងកើនឡើង។ ទីមួយ តាមរយៈការបញ្ចៀសអតិផរណា ប្រទេសទាំងនេះបានបញ្ចៀសការប្រែប្រួលអត្រាការប្រាក់ពិតលើប្រាក់បញ្ញើ និងធានាថា អត្រាទាំងនេះមានភាពវិជ្ជមាន។ ជាលទ្ធផល ប្រទេសទាំងនេះបានផ្ដល់អត្រាការប្រាក់ពិតកាន់តែខ្ពស់លើប្រាក់បញ្ញើក្នុងប្រព័ន្ធហិរញ្ញវត្ថុ ជាងប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងៗទៀត។ ទីពីរ ប្រទេសទាំងនេះធានាបានសន្តិសុខរបស់ធនាគារ និងផ្ដល់ភាពងាយស្រួលដល់អ្នកសន្សំប្រាក់ខ្នាតតូច និងនៅទីជនបទ។

ប្រទេសម៉ាឡេស៊ីបានជំរុញការសន្សំប្រាក់ទូទាំងប្រទេស តាមរយៈការបង្កើតប្រព័ន្ធសន្សំប្រាក់តាមប្រៃសណីយ៍។ ប្រព័ន្ធទាំងនេះបានទាក់ទាញអ្នកសន្សំប្រាក់ខ្នាតតូចយ៉ាងច្រើន ដោយផ្ដល់សន្តិសុខ និងលទ្ធភាពសមស្របដល់ពួកគេ។ រដ្ឋាភិបាលម៉ាឡេស៊ីបានប្រើប្រាស់ផែនការប្រាក់សោធនជាកាតព្វកិច្ច ដើម្បីជំរុញការសន្សំប្រាក់ក្នុងប្រទេស[២]។ ផែនការនេះមានហេតុផលពីរ។ ទីមួយ ប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើនមិនសូវមានទីផ្សារធនលាភឯកជន ហើយទីផ្សារមួយចំនួនតូចដែលមានស្រាប់ ដំណើរការតិចតួច។ ឧ. មិនសូវមានធនលាភសន្ទស្សន៍ (indexed annuities) ឡើយ ហើយជាញឹកញាប់ ធនលាភគ្មានសន្ទស្សន៍ (nonindexed annuities) មានតម្លៃមិនទាក់ទាញ ដោយសារតែការចំណាយខ្ពស់លើប្រតិបត្តិការខ្ពស់ និងការជ្រើសរើសមិនបានល្អ។ ទីពីរ សូម្បីតែនៅពេលដែលមានធនលាភក្ដី ក៏ប្រជាជនមិនសន្សំប្រាក់គ្រប់គ្រាន់សម្រាប់ពេលចាស់ជរារបស់ខ្លួនដែរ ហើយរដ្ឋាភិបាលបានជួយដល់មនុស្សចាស់ដែលមិនអាចទ្រទ្រង់ជីវភាពខ្លួនឯងបាន។ ដើម្បីបញ្ចៀសបញ្ហាអ្នកមិនបង់ប្រាក់នេះ រដ្ឋាភិបាលបានតម្រូវឲ្យពលរដ្ឋយ៉ាងហោចណាស់មានកម្រិតប្រាក់សន្សំអប្បបរមាសម្រាប់ពេលចូលនិវត្តន៍។

ប្រទេសថៃបានបង្កើតធនាគារប្រាក់សន្សំរដ្ឋាភិបាលនៅឆ្នាំ 1913 ដែលជំរុញការសន្សំប្រាក់ក្នុងចំណោមប្រជាជនថៃ ដោយផ្ដោតជាពិសេសលើកុមារ និងសិស្សនិស្សិត។ ដើម្បីបង្កើនទំនុកចិត្តរបស់ប្រជាជនលើធនាគារនេះ រាជរដ្ឋាភិបាលប្រទេសថៃបានផ្ដល់ការធានាដល់គណនីប្រាក់សន្សំរបស់ធនាគារនេះ។ ជាមួយនឹងអាណត្តិកំណត់នេះ ធនាគារនេះបានផ្ដល់ជម្រើសនៃការសន្សំប្រាក់ជាច្រើន តាមរយៈយុទ្ធនាការជាច្រើនក្នុងការជំរុញការសន្សំប្រាក់។ ធនាគារនេះបានចូលរួមចំណែកឲ្យមានទម្លាប់សន្សំប្រាក់ក្នុងប្រទេស។ រាជរដ្ឋាភិបាលប្រទេសថៃបានដាក់ចេញនូវបទប្បញ្ញត្តិមួយចំនួន ដើម្បីបង្កើនលទ្ធភាពសងរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ដែលបានជួយបង្កើនទាំង អត្រាប្រាក់សន្សំ និងប្រសិទ្ធផលនៃការបែងចែកធនធាន។ រាជរដ្ឋាភិបាលថៃបានអនុវត្តបទប្បញ្ញត្តិបង្ការនៅទសវត្សរ៍ឆ្នាំ 1980 ក្នុងទម្រង់ជាលក្ខខណ្ឌតម្រូវឲ្យមានទុនគ្រប់គ្រាន់ លក្ខខណ្ឌនៃការដាក់របស់ធានា និងការរឹតត្បិតការផ្ដល់កម្ចី និងការត្រួតពិនិត្យផ្ទាល់ដោយធនាគារជាតិ។ ការរឹតត្បិតលើការផ្ដល់កម្ចីអាចជាគោលបំណងគោលនយោបាយដ៏សំខាន់មួយ ក្នុងការទប់ស្កាត់ការផ្ដល់កម្ចីដោយប្រថុយប្រថាន ដែលក្លាយជាប្រភពចម្បងនៃវិបត្តិហិរញ្ញវត្ថុនៅប្រទេសថៃ និងក្នុងបណ្ដាប្រទេសផ្សេងៗទៀតនៅអាស៊ីបូព៌ាកាលពីទសវត្សរ៍ឆ្នាំ 1980។

ប្រទេសថៃក៏ធ្វើតាមប្រទេសនៅអាស៊ីបូព៌ាផ្សេងៗទៀតដែរ ដោយដាក់កំណត់របបប្រាក់សន្សំជាកាតព្វកិច្ច ក្រោយពីមានវិបត្តិហិរញ្ញវត្ថុអាស៊ីនៅឆ្នាំ 1997។ របបនេះមានសសរស្ដម្ភបី។ សសរស្ដម្ភទីមួយសម្រាប់និយោជិតក្នុងវិស័យឯកជន សសរស្ដម្ភទីពីរសម្រាប់មន្ត្រីរដ្ឋាភិបាលដែលទទួលបានការបំពេញបន្ថែមដោយមូលនិធិបម្រុងទុក (សសរស្ដម្ភទីបី)។ មូលនិធិបម្រុងទុកត្រូវបានផ្ដល់ដោយសាជីវកម្ម និងសហគ្រាសរដ្ឋ ទៅឲ្យនិយោជិត។ នៅក្នុងសសរស្ដម្ភទីបី ភាគទានរបស់និយោជិតត្រូវមានយ៉ាងហោចណាស់ 3 ភាគរយនៃប្រាក់ឈ្នួល ប៉ុន្តែ មិនត្រូវលើស 15 ភាគរយឡើយ។ ភាគទានរបស់និយោជកមិនត្រូវតិចជាងភាគទានរបស់និយោជិតឡើយ។ និយោជិតទទួលបានប្រាក់បំណាច់នៅពេលពួកគេលាឈប់ពីការងារ ឬចូលនិវត្តន៍។ ជាទូទៅ មូលនិធិនេះត្រូវបានគ្រប់គ្រងរបស់គ្រឹះស្ថានហិរញ្ញវត្ថុសំខាន់ៗ ដែលទទួលបានអាជ្ញាប័ណ្ណពីក្រសួងហិរញ្ញវត្ថុ។ ក្រៅពីមូលនិធិបម្រុងទុកនេះ ប្រទេសថៃមានមូលនិធិសង្គហសម្រាប់ពេលចូលនិវត្តន៍ ដែលស្រដៀងនឹងគណនីចូលនិវត្តន៍បុគ្គលរបស់សហរដ្ឋអាមេរិក។ បុគ្គលម្នាក់អាចបង្កើតគណនីផ្ទាល់ខ្លួនជាមួយគ្រឹះស្ថានហិរញ្ញវត្ថុដែលទទួលបានសិទ្ធិដំណើរការប្រព័ន្ធនេះ។ ភាគទាននេះជាប់ពន្ធទៅតាមកម្រិតកំណត់។ មូលនិធិសង្គហសម្រាប់ពេលចូលនិវត្តន៍ ត្រូវបានអនុវត្តក្នុងប្រទេសថៃនៅអំឡុងខែ មីនា ឆ្នាំ 2001 ដើម្បីផ្ដល់មធ្យោបាយសន្សំប្រាក់ដោយស្ម័គ្រចិត្តសម្រាប់ពេលចូលនិវត្តន៍សម្រាប់និយោជិតដែលមិនស្ថិតក្នុងមូលនិធិបម្រុងទុក ឬចង់បង់ភាគទានបន្ថែម។ វិនិយោគិនមានសេរីភាពច្រើនក្នុងការបែងចែកទ្រព្យមូលនិធិ។ ប៉ុន្តែ ការដកប្រាក់ធ្វើបានសម្រាប់តែអ្នកដែលមានអាយុ 55 ឆ្នាំប៉ុណ្ណោះ។

**តារាង S2.1 ៖ ប្រាក់សន្សំក្នុងវិស័យឯកជន និងវិស័យសាធារណៈ** (% ផសស)

| ប្រទេស | ប្រាក់សន្សំក្នុងវិស័យសាធារណៈ | ប្រាក់សន្សំក្នុងវិស័យឯកជន |
|---|---|---|
| **ម៉ាឡេស៊ី** | | |
| 1980-85 | 3.2 | 18.7 |
| 1981-90 | 10.3 | 19.1 |
| **ថៃ** | | |
| 1980-85 | 14.3 | 4.7 |
| 1986-87 | 8.6 | 14.6 |
| **ឥណ្ឌូនេស៊ី** | | |
| 1981-88 | 7.7 | 14.0 |

*ប្រភព* ៖ "ភាពអស្ចារ្យនៃអាស៊ីបូព៌ា" ធនាគារពិភពលោក

១ រៀបរៀងដោយ ភឹម រុនស៊ីណារិទ្ធ ទីប្រឹក្សាធនាគារពិភពលោក។
២ "ទីផ្សារហិរញ្ញវត្ថុ គោលនយោបាយសាធារណៈ និងភាពអស្ចារ្យនៃអាស៊ីបូព៌ា" Joseph Stiglitz និង Marilou Uy ធនាគារពិភពលោក វ៉ាស៊ីនតោន ឌីស៊ី ឆ្នាំ 1996។

## IV. ជម្រើសគោលនយោបាយ

លទ្ធផលនៃលំនាំកំណើនរយៈពេលវែងបង្ហាញថា កម្ពុជានឹងមិនអាចសម្រេចបានគោលដៅ ក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ 2030 ឡើយ ទោះបីជាមានការវិនិយោគច្រើនក្តី ប៉ុន្តែ មានឱកាសសម្រាប់កម្ពុជាសម្រេចបានគោលដៅក្លាយជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ 2050 ដោយមានការជំរុញការវិនិយោគយ៉ាងច្រើន។ តើអ្នកតាក់តែងគោលនយោបាយកម្ពុជាគួរធ្វើអ្វីខ្លះ?

**ទីមួយ កម្ពុជាគួរពិចារណាពន្យារពេលក្នុងការសម្រេចគោលដៅក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ 2030 ទៅឆ្នាំ 2035** (រូប S28) **ព្រោះគោលដៅឆ្នាំ 2030 ប្រហែលជាមិនអាចសម្រេចបានឡើយ ដោយហេតុថា សូម្បីតែខ្លាសេដ្ឋកិច្ចនៅអាស៊ីក៏មិនអាចសម្រេចបានគោលដៅនេះនៅពេលដែលប្រទេសទាំងនោះមានកម្រិតអភិវឌ្ឍន៍ប្រហាក់ប្រហែលនឹងកម្ពុជា[៤៦]។** លំនាំខាងលើបង្ហាញថា សូម្បីតែមានកំណើនផលិតភាពសរុបយ៉ាងលឿន និងកំណើនធនធានមនុស្ស និងកំណើនការវិនិយោគយ៉ាងច្រើនប្រហាក់ប្រហែលនឹងកម្រិតវិនិយោគរបស់សាធារណរដ្ឋកូរ៉េក្តី ក៏កម្ពុជានៅតែមិនអាចសម្រេចបានគោលដៅក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ 2030 បានដែរ។ នេះមិនមែនជារឿងចម្លែង និងគួរឲ្យព្រួយបារម្ភឡើយ ព្រោះថា សូម្បីតែប្រទេសកូរ៉េ និងម៉ាឡេស៊ី ដែលមានកំណើនលឿននោះ ក៏មិនអាចសម្រេចបានគោលដៅនេះបានដែរ។ កំណើនចំណូលសម្រាប់មនុស្សម្នាក់ៗត្រូវមានអត្រាជាមធ្យម 9.3 ភាគរយ ក្នុងរយៈពេល 13 ឆ្នាំ ហើយនេះជាគោលដៅដែលគ្មានប្រទេសណាអាចសម្រេចបានឡើយ។ ផ្ទុយទៅវិញ កម្ពុជាអាចសម្រេចបានគោលដៅក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ 2035 ដោយកម្ពុជាត្រូវមានកំណើនចំណូលសម្រាប់មនុស្សម្នាក់ៗចំនួន 6.6 ភាគរយ។ ដោយសារតែកំណើនចំណូលសម្រាប់មនុស្សម្នាក់ៗក្នុងរយៈពេល 5 ឆ្នាំចុងក្រោយមានចំនួន 5.2 ភាគរយ នេះជាគោលដៅខ្ពស់ពេក និងជាគោលដៅដែលមិនសម្រេចបានបើតាមលំនាំ "ទិន្នន័យគោលធម្មតា"។ ប៉ុន្តែ គោលដៅនេះអាចសម្រេចបាន ប្រសិនបើកម្ពុជាអាចបង្កើនអត្រាវិនិយោគ (រូប S28) ដូចពិភាក្សាបន្ថែមទៀតខាងក្រោម។

**ការខិតខំធ្វើឲ្យមានកំណើនលឿនពេកអាចធ្វើឲ្យមានអតុល្យភាព ដែលអាចគំរាមកំហែងដល់ស្ថិរភាពកំណើន[៤៧]។** មូលហេតុមួយទៀតក្នុងការពន្យារពេលសម្រាប់ការសម្រេចគោលដៅក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ពីឆ្នាំ 2030 ទៅឆ្នាំ 2035 នោះគឺដើម្បីធានាថា កម្ពុជាមិនមានកំណើនសេដ្ឋកិច្ចខ្ពស់ និងមានអតិផរណាខ្ពស់នៅពេលខិតខំសម្រេចគោលដៅនោះ។ ការខិតខំសម្រេចបានគោលដៅកំណើនខ្ពស់ពេកអាចធ្វើឲ្យមានគោលនយោបាយដែលជំរុញកំណើនរយៈពេលខ្លី ប៉ុន្តែគំរាមកំហែងដល់កំណើនរយៈពេលវែង។ ចំពោះម៉ាក្រូសេដ្ឋកិច្ច អាចមានឱនភាពគណនីចរន្ត និងការលែងមានលំហូរមូលធនដោយសារតែការវិនិយោគច្រើនលើសកម្រិត។ ជាជម្រើសមួយទៀត គោលនយោបាយដែលបង្កើតឡើងដើម្បីបង្កើនការវិនិយោគរបស់ក្រុមហ៊ុនតាមរយៈកម្ចីច្រើន អាចធ្វើឲ្យមានកំណើនឥណទានច្រើនលើសលប់ និងវិបត្តិវិស័យធនាគារ។ បញ្ហាទាំងអស់នេះបានប៉ះពាល់ដល់ប្រទេសជិតខាងរបស់កម្ពុជាកាលពីពេលមុន ដែលបានបង្កផលអវិជ្ជមានយ៉ាងច្រើន។ ចំពោះមីក្រូសេដ្ឋកិច្ច គុណភាពនៃការវិនិយោគអាចថយចុះ ដោយសារតែគម្រោងវិនិយោគត្រូវបានអនុម័តក្នុងគោលដៅបង្កើនកំណើន មិនមែនដើម្បីបង្កើតផលចំណេញពីទីផ្សារទេ។

**ទីពីរ កម្ពុជាគួរខិតខំរក្សាអត្រាកំណើនធនធានមនុស្ស និងកំណើនផលិតភាពសរុប។** ផ្អែកតាមលំនាំខាងលើ កំណើនយ៉ាងលឿននៃធនធានមនុស្សសម្រាប់កម្មករនិយោជិតម្នាក់ និងផលិតភាពសរុប បានធ្វើឲ្យមានអត្រាកំណើនប្រមាណ 7 ភាគរយក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ កំណើនធនធានមនុស្ស និងផលិតភាពសរុបនេះ មានសារៈសំខាន់ក្នុងការរក្សាភាពប្រកួតប្រជែង ព្រោះថា (ក) កំណើនប្រាក់ឈ្នួលកាត់បន្ថយភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងនាមជាប្រទេសដែលមានប្រាក់ឈ្នួលទាប និង (ខ) ការកើនឡើងនៃប្រាក់ចំណូល មានន័យថា កម្ពុជាលែងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានការអនុគ្រោះផ្នែកពាណិជ្ជកម្ម ដែលត្រូវផ្តល់ឲ្យតែប្រទេសដែលមានការអភិវឌ្ឍតិចតួចបំផុតប៉ុណ្ណោះ។

**ការរក្សាអត្រាកំណើន តម្រូវឲ្យមានកំណែទម្រង់បន្ថែមទៀតព្រោះថា កម្ពុជាសម្រេចបានផលចំណេញយ៉ាងងាយស្រួលរួចហើយនោះ។** លើសពីនេះទៀត ដូចបានពិភាក្សារួចហើយ

**រូប S28 ៖ កម្រិតចំណូលម្នាក់ៗនៅកម្ពុជា**

(ធៀបនឹងអត្រាវិនិយោគ 28.5 ភាគរយពីឆ្នាំ 2030)




*ប្រភព* ៖ លំនាំកំណើនរបស់ក្រុមធនាគារពិភពលោក

---

៤៦ អនុសាសន៍នេះផ្អែកលើកម្រិតចំណូលសរុបសម្រាប់មនុស្សម្នាក់ៗនាពេលបច្ចុប្បន្ន។ ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនបានកែលម្អវិធីសាស្ត្រក្នុងការគណនាផសស និងប្រាក់ចំណូលជាតិសរុប ដែលធ្វើឲ្យមានការបង្កើនបរិមាណទាំងនេះ។ ក្នុងករណីនោះ គោលដៅក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ 2030 ប្រហែលជាអាចសម្រេចបានជាងមុន។

៤៧ អតុល្យភាពដែលកម្ពុជាអាចជួបប្រទះ ប្រសិនបើកម្ពុជាព្យាយាមសម្រេចកំណើនលឿនពេក រួមមាន ឱនភាពសារពើពន្ធដែលគ្មាននិរន្តរភាព និងបំណុលខាងក្រៅ អស្ថិរភាពវិស័យហិរញ្ញវត្ថុ និងអតិផរណាកើនខ្ពស់លឿន។

ស្ថានភាពសកលលោកត្រូវបានរំពឹងនឹងមិនសូវអំណោយផលដល់កំណើនទីផ្សារ និងប្រទេសកំពុងអភិវឌ្ឍន៍ដែលងើបឡើងទេ (សូមមើលប្រអប់ 1 ៖ ទស្សនវិស័យសេដ្ឋកិច្ចសកល និងតំបន់) ហើយកម្ពុជាក៏ប្រឈមមុខនឹងស្ថានភាពនេះដែរ។ អត្រាកំណើនលឿននៃធនធានមនុស្ស និងផលិតភាពសរុបនៅកម្ពុជាក្នុងរយៈពេលមួយទសវត្សរ៍កន្លងមក ជាចំណុចវិជ្ជមាន ប៉ុន្តែ អត្រាកំណើនទាំងនេះផ្អែកលើមូលដ្ឋានទាប ដែលបានទទួលផលចំណេញដោយងាយស្រួល។ ឧទាហរណ៍ ការចាកចេញរបស់កម្មករពីការងារកសិកម្មទៅក្នុងការងាររោងចក្រកាត់ដេរ ធ្វើឲ្យមានកំណើនផលិតភាពខ្ពស់ ប៉ុន្តែ ចំណុចនេះជាករណីលើកលែងទេ។ ការបង្កើនផលិតភាពរបស់រោងចក្រកាត់ដេរនៅពេលបច្ចុប្បន្នកាន់តែលំបាក។ បញ្ហានេះក៏ដូចគ្នាចំពោះបញ្ហាធនធានមនុស្សផងដែរ។ ការផ្តល់ការអប់រំមូលដ្ឋានអាចផ្តល់ផលចំណេញច្រើន ពីមូលដ្ឋានទាបនេះ ប៉ុន្តែ ការរីកចម្រើននាពេលអនាគតកាន់តែមានការលំបាកទៀត។

**ក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ ការបង្កើនធនធានមនុស្សតាមរយៈការបង្កើនលទ្ធភាពទទួលបានការអប់រំ និងការអប់រំដែលមានគុណភាព ជាពិសេសនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាគឺជាការចាំបាច់។** លទ្ធផលនៃការសម្រេចបានការអប់រំបឋមសិក្សាសម្រាប់ទាំងអស់គ្នានាពេលបច្ចុប្បន្ន ជួបប្រទះបញ្ហាដោយសារតែលទ្ធផលសិក្សាមិនល្អនៅកម្រិតបឋមសិក្សា[៤៨]។ ជាការចាំបាច់ត្រូវដោះស្រាយបញ្ហា លទ្ធផលសិក្សាមិនល្អដែលបណ្តាលមកពីបញ្ហាខ្វះគ្រូបង្រៀន និងខ្វះគ្រូដែលមានគុណភាព (ធៀបនឹងប្រទេសជិតខាង) ម៉ោងសិក្សាតិច និងការពន្យារពេលក្នុងការចូលរៀនរបស់កុមារ ដោយសារអត្រាចុះឈ្មោះចូលរៀនរបស់កុមារតូចនៅទាប។ អត្រាទាបនៃការបញ្ចប់មធ្យមសិក្សា (47.4 ភាគរយនៅឆ្នាំ 2016) គឺជាអត្រាទាបបំផុតក្នុងតំបន់។ ធនធានមនុស្សរឹងមាំគឺជាកត្តាសំខាន់ក្នុងការធ្វើឲ្យទទួលបានឱកាសការងារល្អប្រសើរក្នុងវិស័យក្រៅពីកសិកម្ម និងសម្រួលដល់ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើតការងារ (សូមមើលប្រអប់ S1 សម្រាប់បទពិសោធន៍ក្នុងតំបន់)។

**ការរក្សាកំណើនផលិតភាពសរុប នឹងតម្រូវឲ្យមានការបន្តកែប្រែរចនាសម្ព័ន្ធ និងកំណែទម្រង់ថែមទៀតដើម្បីបង្កើនគុណភាពបរិយាកាសវិនិយោគ[៤៩]។** ក្រៅពីការកែប្រែរចនាសម្ព័ន្ធក្នុងវិស័យនានា (ការចាកចេញរបស់កម្លាំងពលកម្មពីវិស័យកសិកម្មទៅវិស័យកម្មន្តសាល និងសេវាកម្ម) កំណើនផលិតភាពសរុបក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវបានជំរុញដោយការបែងចែកមូលធន និងកម្លាំងពលកម្មឡើងវិញ ដើម្បីឲ្យមានក្រុមហ៊ុនដែលមានប្រសិទ្ធភាពជាងមុនក្នុងវិស័យនានា។ លទ្ធភាពទទួលបានឥណទានដែលជំរុញដោយនយោបាយ បទប្បញ្ញត្តិគ្មានប្រសិទ្ធភាព និងការចំណាយច្រើនលើការអនុវត្តកិច្ចសន្យា អាចធ្វើឲ្យមានការបែងចែកធនធានមិនបានល្អ។ ឧទាហរណ៍ Hsieh និង Klenow (2009) រកឃើញថា ការកាត់បន្ថយការបែងចែកធនធានមិនបានល្អក្នុងប្រទេសចិន និងឥណ្ឌា ឲ្យដល់កម្រិតរបស់សហរដ្ឋអាមេរិក បង្កើនផលិតភាពសរុបផ្នែកកម្មន្តសាលរហូតដល់ពី 30 ទៅ 50 ភាគរយក្នុងប្រទេសចិន និងពី 40 ទៅ 60 ភាគរយក្នុងប្រទេសឥណ្ឌា។ មានសក្តានុពលយ៉ាងច្រើនក្នុងការកែលម្អបរិយាកាសធុរកិច្ចរបស់កម្ពុជា។ កម្ពុជាឈរនៅលំដាប់ទី 138 ក្នុងចំណោមប្រទេស 190 ក្នុងចំណាត់ថ្នាក់នៅក្នុងរបាយការណ៍ស្តីពីការធ្វើធុរកិច្ច នៅឆ្នាំ 2019 ដោយថយចុះពីលំដាប់ទី 135 (2018) និងលំដាប់ទី 131 (2017)។ ខណៈដែលកម្ពុជានាំមុខឡាវ (លំដាប់ទី 154) កម្ពុជានៅដាច់ឆ្ងាយពីប្រទេសក្នុងតំបន់ដូចជា ឥណ្ឌូនេស៊ី (លំដាប់ទី 73) វៀតណាម (លំដាប់ទី 69) និងថៃ (លំដាប់ទី 27)[៥០]។ ក្នុងការវាយតម្លៃទៅលើបរិយាកាសវិនិយោគចុងក្រោយ (សូមមើលប្រអប់ 2) ដែលបង្ហាញពីវឌ្ឍនភាពយ៉ាងច្រើន ការវាយតម្លៃនេះសន្និដ្ឋានថា បរិយាកាសវិនិយោគបច្ចុប្បន្នរាំងស្ទះដល់ការបង្កើនផលិតភាព ពិពិធកម្ម និងការអភិវឌ្ឍភាពសកម្មរបស់វិស័យឯកជនក្នុងប្រទេស។

**ទីបី កម្ពុជាត្រូវបង្កើនអត្រាវិនិយោគ។ រូប S28 បង្ហាញថាចាំបាច់ត្រូវបង្កើនអត្រាវិនិយោគឲ្យបាន 28.5 ភាគរយនៃ ផសស នៅឆ្នាំ 2030 (ដូចប្រទេសម៉ាឡេស៊ី) ដើម្បីឲ្យកម្ពុជាសម្រេចបានគោលដៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ 2035 និងក្លាយជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ 2050។** លំនាំផ្សេងៗក្នុងរូប S28 ស្រដៀងគ្នានឹងលំនាំខាងលើដែលប្រើប្រាស់ទិន្នន័យគោលធម្មតា (មិនមែនទិន្នន័យគោលអភិរក្ស ដែលការវិនិយោគមិនសូវមានប្រសិទ្ធភាពសម្រាប់កំណើនទេ)។ ប៉ុន្តែ នៅពេលនេះ (ក) យើងគណនាកំណើនការវិនិយោគនៅឆ្នាំ 2030 ដើម្បីសម្រេចបានគោលដៅកំណើន (មិនជាការធ្វើតាមបទពិសោធន៍របស់ប្រទេសដទៃទេ) និង (ខ) គោលដៅក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ 2035 កាន់តែមានភាពងាយស្រួលក្នុងការសម្រេចបាន។ ចាប់ផ្តើមពីអត្រាវិនិយោគ 22 ភាគរយនៃ ផសស បច្ចុប្បន្ននេះ កម្ពុជាត្រូវមានអត្រាកំណើនការវិនិយោគឲ្យបាន 6.5 ភាគរយពិន្ទុ។ ដើម្បីឲ្យស្របទៅនឹងបរិបទនេះ អត្រាវិនិយោគក៏បានកើនឡើងប្រមាណ 6.5 ភាគរយពិន្ទុចាប់ពីពាក់កណ្តាលទៅចុងទសវត្សរ៍ឆ្នាំ 1990 រហូតដល់ដើមទៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ 2000 ដែលបង្ហាញថា នេះជាកំណើនដែលអាចសម្រេចបាន (រូប S4)។

៤៨ “កម្ពុជាឆ្នាំ 2017៖ ការរក្សាកំណើនរឹងមាំសម្រាប់ជាប្រយោជន៍ដល់ប្រជាជនទាំងអស់គ្នា៖ ការវិភាគប្រទេសជាប្រព័ន្ធ” ធនាគារពិភពលោក វ៉ាស៊ីនតោន ឌីស៊ី ឆ្នាំ 2017។

៤៩ ការកើនឡើងនៃគុណភាព និងបរិមាណនៃការវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈ អាចជួយបង្កើនកំណើនផលិតភាពសរុប។ អត្រាការវិនិយោគក្នុងវិស័យសាធារណៈបច្ចុប្បន្នគឺ 7.5 ភាគរយនៃ ផសស ដែលជាអត្រាខ្ពស់សម្រាប់ប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប ទោះបីជាវាជារឿងធម្មតាសម្រាប់ប្រទេសដែលមានប្រាក់ចំណូលទាបក្តី ( Devadas និង Pennings 2018)។ ដូច្នេះ កម្ពុជាប្រហែលជាត្រូវផ្តោតលើការបង្កើនគុណភាពហេដ្ឋារចនាសម្ព័ន្ធសាធារណៈ តាមរយៈការបង្កើនគុណភាពផ្លូវថ្នល់ ការកាត់បន្ថយការបាត់បង់អគ្គិសនីដោយសារការតភ្ជាប់ និងការកាត់បន្ថយការបាត់បង់ទឹក។ សន្ទស្សន៍ស្តីពីប្រសិទ្ធភាពនៃហេដ្ឋារចនាសម្ព័ន្ធនៅក្នុងឯកសាររបស់ Devadas និង Pennings (2018) ប្រមាណ 0.67 បង្ហាញថា កម្ពុជាត្រូវកែលម្អចំណុចជាច្រើន។

៥០ http://www.doingbusiness.org/content/dam/doingBusiness/country/c/cambodia/KHM.pdf.

នេះក៏ជាលំនាំដែលបានអនុវត្តដោយប្រទេសម៉ាឡេស៊ី (រូប S10)។ កំណែទម្រង់លើបរិយាកាសវិនិយោគ និងអាជីវកម្ម អាចជំរុញឲ្យក្រុមហ៊ុនបង្កើនការវិនិយោគរបស់ខ្លួន។ ក្រៅពីការជំរុញប្រសិទ្ធផល បរិយាកាសវិនិយោគល្អក៏នឹងទាក់ទាញការវិនិយោគកាន់តែច្រើន។ ក្រុមហ៊ុននឹងវិនិយោគបន្ថែមទៀត ប្រសិនបើក្រុមហ៊ុនយល់ថានឹងមានការអនុវត្តកិច្ចសន្យារបស់ពួកគេ មានក្របខណ្ឌគោលនយោបាយដែលអាចព្យាករបាន និងមានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ ការប្រកួតប្រជែងខ្លាំងក៏អាចជំរុញការវិនិយោគរបស់ក្រុមហ៊ុនថ្មីៗផងដែរ (មើលប្រអប់ 2)។

**ចុងក្រោយ កម្ពុជានឹងត្រូវបង្កើនអត្រាប្រាក់សន្សំឲ្យបានប្រមាណ 10 ភាគរយពិន្ទុនៃ ផសស ដើម្បីផ្តល់ហិរញ្ញប្បទានដល់កំណើនការវិនិយោគដែលចាំបាច់ក្នុងការសម្រេចគោលដៅកំណើន និងកាត់បន្ថយការពឹងផ្អែកលើប្រាក់សន្សំពីបរទេស[៥១]។** កំណើនប្រាក់សន្សំដែលតម្រូវឲ្យមានមានកម្រិតទាបជាងអត្រាកំណើនខាងលើក្នុងរូប S 25 ដែលយើងសន្មតថា កម្ពុជាអនុវត្តតាមលំនាំការវិនិយោគរបស់កូរ៉េ ប៉ុន្តែ នៅតែមានភាពខុសគ្នាខ្លាំង។ អត្រាប្រមាណ 6 ភាគរយពិន្ទុបានមកពីការបង្កើនការវិនិយោគដែលតម្រូវឲ្យមានដើម្បីសម្រេចគោលដៅកំណើន។ ចាំបាច់ត្រូវមានអត្រាប្រាក់សន្សំបន្ថែម 4 ភាគរយពិន្ទុនៃ ផសស ទៀត ដើម្បីកាត់បន្ថយការពឹងផ្អែកទៅលើប្រាក់សន្សំពីបរទេស និងកាត់បន្ថយតុល្យភាពគណនីចរន្តដែលជាមធ្យមរយៈពេលវែងមានប្រមាណ 5 ភាគរយនៃ ផសស (ដូចបានពិភាក្សាខាងលើ)។ កម្ពុជាប្រហែលជាគ្មានជម្រើសអ្វីផ្សេងឡើយ។ នៅពេលមានកំណើនប្រាក់ចំណូល កម្ពុជានឹងបាត់បង់ការអនុគ្រោះពន្ធទៅទីផ្សារផ្សេងៗ ដែលជាចំណុចទាក់ទាញចំពោះការវិនិយោគផ្ទាល់ពីបរទេសយ៉ាងច្រើនក្នុងវិស័យកាត់ដេរ (វិស័យនេះក៏នឹងលែងសូវមានភាពប្រកួតប្រជែងដែរដោយសារតែកំណើនប្រាក់ឈ្នួលទៅតាមការអភិវឌ្ឍក្នុងប្រទេស)។ ចុងក្រោយ ការវិនិយោគផ្ទាល់ពីបរទេសជាប្រាក់ដុល្លារដែលមានបរិមាណតិចតួច មានភាគរយខ្ពស់ធៀបនឹង ផសស ព្រោះថា ផសសបច្ចុប្បន្ន នៅមានទំហំតូចនៅឡើយ។ នៅពេលដែល ផសស កើនឡើង 10 ដងក្នុងរយៈពេល 32 ឆ្នាំខាងមុខ (ផ្អែកតាមលំនាំនេះ) តម្លៃពិតនៃលំហូរមូលធនជាប្រាក់ដុល្លារ ក៏នឹងត្រូវកើនឡើង 10 ដងដែរ ដើម្បីរក្សាចំណែកប្រាក់នេះនៅក្នុង ផសស ហើយកំណើននៃការវិនិយោគនេះអាចជាអ្វីដែលវិនិយោគិនអន្តរជាតិមិនចង់ផ្តល់។

**កម្ពុជាអាចពឹងផ្អែកលើបទពិសោធន៍របស់ប្រទេសនានាក្នុងការស្វែងរកវិធីបង្កើនប្រាក់សន្សំ។** ប្រទេសមួយចំនួនក្នុងតំបន់បានបង្កើនប្រាក់សន្សំរបស់ខ្លួនដោយជោគជ័យតាមមធ្យោបាយផ្សេងៗ (សូមមើលប្រអប់ S2 និងរូប S24)។ ប្រព័ន្ធឌីជីថលសម្រាប់ការប្រមូលផ្តុំហិរញ្ញវត្ថុ និងការអភិវឌ្ឍទីផ្សារមូលធន និងទីផ្សារបំណុលក្នុងស្រុក នៅខណៈពេលមានការលើកទឹកចិត្តឲ្យដាក់ប្រាក់បញ្ញើ និងប្រាក់សន្សំជារូបិយវត្ថុជាតិ នឹងជួយគាំទ្រទាំងការវិនិយោគច្រើន និងបដិដុល្លាររូបនីយកម្មជាបណ្តើរៗ។ បច្ចុប្បន្ន ឆន្ទៈរបស់គ្រួសារ និងក្រុមហ៊ុនបច្ចុប្បន្នក្នុងការដាក់ប្រាក់បញ្ញើក្នុងវិស័យធនាគារក្នុងស្រុក ក៏អាស្រ័យទៅតាមការយល់ឃើញអំពីហានិភ័យរបស់ពួកគេ។ ដូច្នេះ ការណែនាំបទប្បញ្ញត្តិរឹងមាំ និងការធានាដល់ប្រាក់បញ្ញើ នឹងបង្កើនទំនុកចិត្តលើធនាគារ[៥២]។ ឧទាហរណ៍ ប្រទេសម៉ាឡេស៊ីបានជំរុញការសន្សំប្រាក់ក្នុងប្រទេសតាមរយៈការបង្កើតប្រព័ន្ធសន្សំប្រាក់តាមប្រៃសណីយ៍ ដូចបានលើកឡើងខាងលើ ចំណែកប្រទេសថៃបានបង្កើតធនាគារប្រាក់សន្សំក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល និងចេញបទប្បញ្ញត្តិមួយចំនួនដើម្បីបង្កើនលទ្ធភាពផ្តល់ប្រាក់របស់គ្រឹះស្ថានហិរញ្ញវត្ថុ ដែលអាចជួយទាំងការបង្កើនអត្រាសន្សំប្រាក់ និងប្រសិទ្ធផលនៃការបែងចែកធនធាន។




៥១ “កម្ពុជាឆ្នាំ 2017៖ ការរក្សាកំណើនរឹងមាំសម្រាប់ជាប្រយោជន៍ដល់ប្រជាជនទាំងអស់គ្នា៖ ការវិភាគប្រទេសជាប្រព័ន្ធ” ធនាគារពិភពលោក វ៉ាស៊ីនតោន ឌីស៊ី ឆ្នាំ 2017។

៥២ ចំណុចនេះនឹងជួយឲ្យសម្រេចបានអត្រាប្តូរប្រាក់ដែលមានភាពបត់បែន និងមានម្ចាស់ការលើគោលនយោបាយរូបិយវត្ថុ។ ក្នុងរយៈពេលមធ្យមខាងមុខ វិធានការណ៍ទីផ្សារដែលផ្តោតលើការជំរុញការប្រើប្រាស់ប្រាក់រៀលកម្ពុជា រួមនឹងការអភិវឌ្ឍទីផ្សារមូលធន និងប័ណ្ណបំណុល អាចបង្កើតជាប្រភពមូលនិធិរយៈពេលវែងសម្រាប់វិស័យអាជីវកម្ម និងផ្តល់ជម្រើសដល់ការវិនិយោគលើវិស័យសំណង់ និងអចលនទ្រព្យ។

# ឧបសម្ព័ន្ធ ៖ ការពិពណ៌នាអំពីលំនាំកំណើនរយៈពេលវែង

លំនាំកំណើនរយៈពេលវែងគឺជាឧបករណ៍កម្មវិធី Excel ដែលផ្អែកលើកំណើន Solow-Swan ដ៏ល្បីល្បាញ ប៉ុន្តែ ត្រូវបានកែសម្រួលដើម្បីធ្វើការវិភាគទៅលើកំណើនក្នុងប្រទេសកំពុងអភិវឌ្ឍន៍[៥៣] (ឧបករណ៍កម្មវិធី Excel និងឯកសារទាំងអស់នេះ អាចទាញយកដោយមិនគិតថ្លៃតាមរយៈគេហទំព័រ www.worldbank.org/LTGM)។ កត្តាជំរុញកំណើនសំខាន់ៗរួមមាន ការវិនិយោគ ប្រាក់សន្សំ និងផលិតភាព ប៉ុន្តែ លំនាំនេះបានបញ្ចូលកត្តាផ្សេងៗទៀតសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ និងកំពុងងើបឡើង ដូចជា ធនធានមនុស្ស ប្រជាសាស្ត្រ និងការចូលរួមក្នុងទីផ្សារការងារ (ជាពិសេសសម្រាប់ស្ត្រី)។ បច្ចុប្បន្ន លំនាំកំណើនគោលនេះត្រូវបានពង្រីកបន្ថែមដើម្បីធ្វើការវិភាគទៅលើផលប៉ះពាល់នៃកំណើន (និងវិសមភាព) លើភាពក្រីក្រ ដោយផ្អែកលើការប៉ាន់ស្មានធម្មតាទៅលើរបាយប្រាក់ចំណូល។

មានលទ្ធផលសំខាន់ៗពីរចេញពីលំនាំកំណើននេះ។ ទីមួយ កំណើនផ្អែកលើការវិនិយោគគ្មាននិរន្តរភាពរយៈពេលវែងទេ ព្រោះថាមូលធនកើនឡើងលឿនជាងផល ដែលធ្វើឲ្យមានកំណើនផលធៀបនៃមូលធន និងផល និងកាត់បន្ថយប្រសិទ្ធភាពនៃការវិនិយោគលើកំណើន។ ការបង្កើនកត្តាជំរុញកំណើនផ្សេងៗទៀត ដូចជា ផលិតភាពសរុប ធនធានមនុស្ស និងការចូលរួមក្នុងទីផ្សារការងារ ជួយរក្សាផលធៀបនៃមូលធន និងផល តាមរយៈការបង្កើនផល ដែលធ្វើឲ្យកំណើនមាននិរន្តរភាព។ ទីពីរ ការវិនិយោគច្រើនតម្រូវឲ្យមានការផ្តល់ហិរញ្ញប្បទានដោយប្រាក់សន្សំក្នុងស្រុក និងពីបរទេស។ ដោយសារតែប្រាក់សន្សំពីបរទេសអាចប្រែប្រួល ការវិនិយោគច្រើនក្នុងរយៈពេលយូរ ជាធម្មតា តម្រូវឲ្យមានប្រាក់សន្សំក្នុងស្រុកច្រើន។

សេដ្ឋកិច្ចនៃលំនាំកំណើននេះរួមមានវិស័យមួយដែលបង្កើត ផសស ដោយប្រើប្រាស់មូលធនរូបវ័ន្ត ($K_t$) និងកម្លាំងពលកម្មដែលមានប្រសិទ្ធភាព ($h_t L_t$)។ $A_t$ តំណាងឲ្យផលិតភាពសរុប ដែលកំណត់ពីប្រសិទ្ធភាពនៃសេដ្ឋកិច្ចទាំងមូល។

(1) $$Y_t = A_t K_t^{1-\beta} (h_t L_t)^{\beta}$$

នៅពេលដែល ß ជាចំណែកដុលនៃកម្លាំងពលកម្មធៀបនឹងប្រាក់ចំណូល ហើយកម្លាំងពលកម្មដែលមានប្រសិទ្ធភាព ក្លាយជាធនធានមនុស្សសម្រាប់កម្មករនិយោជិតម្នាក់ ($h_t$) និងចំនួនកម្មករនិយោជិត ($L_t$) ដូច្នេះ ចំនួនកម្មករនិយោជិតសរុប គឺ ៖

(2) $$L_t = \rho_t \omega_t N_t$$

នៅពេលដែល $\rho_t$ ជាអត្រានៃការចូលរួម $\omega_t$ ជាផលធៀបនៃចំនួនប្រជាជនគ្រប់អាយុធ្វើការ និងចំនួនប្រជាជនសរុប ហើយ $N_t$ ជាចំនួនប្រជាជនសរុប។

មូលធនរូបវ័ន្តនៅអំឡុងពេលបន្ទាប់ ($K_{t+1}$) ស្មើនឹងមូលធនមិនធ្លាក់ថ្លៃ $(1-\delta)K_t$ និងការវិនិយោគថ្មី ($I_t$) ៖

(3) $$K_{t+1} = (1-\delta)K_t + I_t$$

ការវិនិយោគទទួលបានហិរញ្ញប្បទានពីប្រាក់សន្សំក្នុងប្រទេស ($S_t$) ឬប្រាក់សន្សំពីបរទេស តាមរយៈឱនភាពគណនីយចរន្ត ($CAD_t$) ៖

(4) $$I_t/Y_t = S_t/Y_t + CAD_t/Y_t$$

[៥៣] លំនាំកំណើនដែលផ្អែកលើស្នាដៃរបស់ Hevai និង Loayza (2012)។

ការប្រែប្រួលនៃប្រាក់សន្សំពីបរទេស អាចក្លាយជាការវិនិយោគផ្ទាល់ពីបរទេសក្នុងតំបន់ និងការប្រែប្រួលនៃបំណុលខាងក្រៅសរុប ($D_t$) ៖

(5) $$\frac{I_t}{Y_t} = \frac{S_t}{Y_t} + \frac{FDI_t}{Y_t} + \frac{D_t}{Y_t} - \frac{D_{t-1}/Y_{t-1}}{\left(1+g_{y,t}^{pc}\right)\left(1+g_{N,t}\right)}$$

តាមរយៈការបញ្ចូលកត្តាទាំងនេះ លំនាំកំណើននេះអាចគណនាកំណើនដែលទទួលបានពីឧបសគ្គរាំងការវិនិយោគ (លំនាំទី 1) ឬឧបសគ្គរាំងការសន្សំប្រាក់ (លំនាំទី 3) ឬក៏អាចគណនាការវិនិយោគដែលចាំបាច់ដើម្បីសម្រេចបានគោលដៅកំណើន (លំនាំទី 2)។ លំនាំកំណើនេះក៏អាចគណនាការប្រែប្រួលនៃអត្រាភាពក្រីក្រ នៅពេលកំណើន ផសស សម្រាប់មនុស្សម្នាក់ រុញច្រានរបាយប្រាក់ចំណូលទៅខាងស្តាំ។

(6) $$\boldsymbol{g_{y,t+1}} \approx g_{A,t+1} + \beta(g_{h,t+1} + g_{\omega,t+1} + g_{N,t+1} + g_{\rho,t+1}) + \left[\frac{1-\beta}{K_t/Y_t}\right]\frac{I_t}{Y_t} - (1-\beta)\delta.$$

កំណើន ផសស ជាញឹកញាប់ ($g_{y,t+1}$) ដោយប្រើប្រាស់ការប៉ាន់ស្មាន log-linear អាចក្លាយជាកំណើនផ្សេងៗ (សមីការទី 6)។ នៅទីនេះ $g_{x,t+1}$ ជាអត្រាកំណើននៃកត្តា x ពី t ទៅជា t+1។ សមីការ 7 ជារូបមន្តសមមូលនៃកំណើន ផសស សម្រាប់មនុស្សម្នាក់ៗ ($\boldsymbol{g_{y,t+1}^{pc}} = \boldsymbol{g_{y,t+1}} - g_{N,t+1}$) ដែលការខុសគ្នាសំខាន់ៗគឺថា កំណើនប្រជាជនបង្កើនកំណើន ផសស ជាញឹកញាប់ ប៉ុន្តែ បន្ថយកំណើន ផសស សម្រាប់មនុស្សម្នាក់ៗ ៖

(7) $$\boldsymbol{g_{y,t+1}^{pc}} \approx g_{A,t+1} + \beta(g_{h,t+1} + g_{\omega,t+1} + g_{\rho,t+1}) + \left[\frac{1-\beta}{K_t/Y_t}\right]\frac{I_t}{Y_t} - (1-\beta)(\delta + g_{N,t+1})$$

$(1-\beta)/(K_t/Y_t)$ គឺជាកំណើនផលនៃមូលធន (MPK) ឬចំណុចផ្ទុយពីកំណើននៃអត្រាមូលធន និងផល (mICOR) ដែលកំណត់ពីប្រសិទ្ធភាពនៃការវិនិយោគក្នុងការជំរុញកំណើន។ ឧទាហរណ៍ កំណើននៃ $(K_t/Y_t)$ ពីការវិនិយោគច្រើនលើសលប់ នឹងបន្ថយកំណើនផលនៃមូលធនកម្រិតទាប (MPK) និងបង្កើន mICOR។

# ប្រទេសកម្ពុជា៖ សូចនាករសំខាន់ៗ

| | 2015 | 2016 | 2017 | 2018e | 2019f | 2020f |
|---|---|---|---|---|---|---|
| **លទ្ធផល និងកំណើនសេដ្ឋកិច្ច** | | | | | | |
| ផសស ពិត (% ប្រែប្រួល ធៀបនឹងឆ្នាំមុន) | 7.0 | 6.9 | 7.0 | 7.1 | 6.8 | 6.8 |
| តម្រូវការក្នុងស្រុក (% ប្រែប្រួល ធៀបនឹងឆ្នាំមុន) | 8.0 | 9.9 | 7.8 | 11.2 | 9.7 | 8.5 |
| ផសស សម្រាប់មនុស្សម្នាក់ៗ (US$ ណូមីណល) | 1,171.0 | 1,264.9 | 1,372.6 | 1,451.6 | 1,563.9 | 1,701.0 |
| **រូបិយវត្ថុ និងតម្លៃ** | | | | | | |
| អតិផរណា តម្លៃទំនិញប្រើប្រាស់ (% ប្រចាំឆ្នាំ រយៈពេលមធ្យម) | 1.7 | 3.5 | 3.1 | 3.2 | 3.3 | 3.0 |
| រូបិយវត្ថុទូលាយ (M2) (% នៃ ផសស) | 66.6 | 70.9 | 79.6 | 87.0 | 94.0 | 101.0 |
| ឥណទានក្នុងស្រុកទៅវិស័យឯកជន (% នៃ ផសស) | 62.7 | 69.5 | 74.7 | 82.7 | 86.8 | 89.9 |
| អត្រាប្តូរប្រាក់ណូមីណល (រូបិយវត្ថុក្នុងស្រុកធៀបនឹងដុល្លារអាមេរិក) | 4,025 | 4,058 | 4,062 | 4,067 | 4,087 | 4,063 |
| សន្ទស្សន៍អត្រាប្តូរប្រាក់ពិត (២០១០=១០០) | 103.6 | 105.1 | 103.7 | 103.7 | 103.9 | 103.9 |
| អត្រាការប្រាក់រយៈពេលខ្លី (% ក្នុងមួយឆ្នាំ) | 11.6 | 11.8 | 11.4 | 11.4 | 11.7 | 11.8 |
| **សារពើពន្ធ** | | | | | | |
| ចំណូល (% នៃ ផសស) | 19.5 | 20.7 | 21.5 | 20.4 | 19.8 | 19.4 |
| ការចំណាយ (% នៃ ផសស) | 21.3 | 22.1 | 23.1 | 24.6 | 23.9 | 23.7 |
| សមតុល្យសារពើពន្ធសរុប (% នៃ ផសស) | -1.9 | -1.4 | -1.6 | -4.2 | -4.1 | -4.3 |
| សមតុល្យសារពើពន្ធចម្បង (% នៃ ផសស) | -1.6 | -1.0 | -1.2 | -3.8 | -3.7 | -3.9 |
| បំណុលទូទៅរបស់រដ្ឋាភិបាល (% នៃផសស) | 31.3 | 32.4 | 33.9 | 36.2 | 37.0 | 37.5 |
| **គណនីក្រៅប្រទេស** | | | | | | |
| កំណើនការនាំចេញ ទំនិញដឹកត្រឹមផែ (ណូមីណល គិតជាដុល្លារ ភាគរយប្រចាំឆ្នាំ) | 7.5 | 9.0 | 9.4 | 14.7 | 13.0 | 13.3 |
| កំណើនការនាំចូល ទំនិញដឹកដល់អ្នកទិញ (ណូមីណល គិតជាដុល្លារ ភាគរយប្រចាំឆ្នាំ) | 7.6 | 9.0 | 7.8 | 14.5 | 11.4 | 10.9 |
| ការនាំចេញទំនិញ (% នៃ ផសស) | 45.4 | 45.5 | 45.3 | 48.4 | 50.0 | 50.9 |
| ការនាំចូលទំនិញ (% នៃផសស) | 57.3 | 56.9 | 55.7 | 59.8 | 61.2 | 61.3 |

| | | | | | | |
|---|---|---|---|---|---|---|
| សេវាកម្ម សុទ្ធ (% នៃ ផសស) | 7.5 | 7.0 | 7.0 | 7.9 | 8.6 | 9.3 |
| សមតុល្យគណនីចរន្ត (គិតជាលានដុល្លារ បច្ចុប្បន្ន) 1/ | -2,007.0 | -2,041.4 | -2,160.6 | -2,432.2 | -2,637.6 | -2,813.6 |
| សមតុល្យគណនីចរន្ត (% នៃ ផសស) | -11.0 | -10.2 | -9.8 | -10.3 | -10.2 | -9.9 |
| ការវិនិយោគទុនផ្ទាល់ពីបរទេស (សុទ្ធ គិតជាលានដុល្លារបច្ចុប្បន្ន) | 1,668.8 | 2,164.4 | 2,381.0 | 2,582.0 | 2,739.3 | 2,964.9 |
| ការវិនិយោគទុនផ្ទាល់ពីបរទេស លំហូរសុទ្ធ (% នៃ ផសស) | 9.1 | 10.8 | 10.8 | 10.9 | 10.6 | 10.4 |
| ប្រាក់បម្រុងរូបិយវត្ថុបរទេស ដុល (គិតជាលានដុល្លារ បច្ចុប្បន្ន) | 5,672.1 | 6,730.8 | 8,757.9 | 9,081.9 | 9,536.0 | 10,012.8 |
| (ចំនួនខែនៃការនាំចូលទំនិញ និងសេវាកម្ម) | 5.2 | 5.7 | 6.8 | 6.6 | 6.3 | 5.9 |
| សម្គាល់ ៖ ផសស ណូមីណាល (គិតជាលានដុល្លារ បច្ចុប្បន្ន) | 18,241.7 | 20,020.2 | 22,059.2 | 23,680.3 | 25,883.3 | 28,550.3 |

*ប្រភព* ៖ អាជ្ញាធរកម្ពុជា មូលនិធិរូបិយវត្ថុអន្តរជាតិ និងការប៉ាន់ប្រមាណ និងការព្យាករណ៍របស់បុគ្គលិកធនាគារពិភពលោក។

*e* = ការប៉ាន់ប្រមាណ f= ការទស្សន៍ទាយ p = ការព្យាករណ៍

*1/* មិនរួមបញ្ចូលការផ្ទេរទេ។

# ឯកសារយោង

Barrot, D. 2016. “Long-Term Growth Model (LTGM): Reference Note on Data Issues.” Internal Note. World Bank, Washington, DC.

Berg, A., J. Ostry, and J. Zettelmeyer. 2012. “What makes growth sustained?” *Journal of Development Economics (29) 149-166.*

Devadas, S., and S. Pennings. 2018. “Assessing the Effect of Public Capital on Growth: An Extension of the World Bank Long-Term Growth Model.” Policy Research Working Paper 8604, World Bank, Washington, DC.

Hevia, C., and N. Loayza. 2012. “Savings and Growth in Egypt.” *Middle East Development Journal* [៤១១ជ។]

Hsieh, Chang-Tai, and P. Klenow. “Misallocation and Manufacturing TFP in China and India.” *The Quarterly Journal of Economics* 124 (4): 1403-1448.

Jeong, H. 2017. “Korea’s Growth Experience and the Long-Term Growth Model.” Policy Research Working Paper 8240, World Bank, Washington, DC.

Jones, B., and B. Olken. 2008. “The Anatomy of Start-stop Growth.” *Review of Economic and Statistics* 90 (3): 582-587.

Jones, C. 2016. “The Facts of Economic Growth.” *Handbook of Macroeconomics* Vol. 2A, Chapter 1: 3-69.

Stiglitz, Joseph, and Marilou Uy. 1996. “Financial Markets, Public Policy, and the East Asian Miracle.” World Bank, Washington, DC.

Thiumsak, Tun, and Athapol Ruangkanjanases. 2016. “Factors Influencing International Visitors to Revisit Bangkok, Thailand.” *Journal of Economics, Business and Management* 4 (3): March. http://www.joebm.com/vol4/394-E00008.pdf.

World Bank. 2017. “2017 Cambodia - Sustaining Strong Growth for the Benefit of All: A Systematic Country Diagnostic.” World Bank, Washington, DC.

World Bank. 2018. *East Asia Pacific Economic Update, October 2018: Navigating Uncertainty.* Washington, DC: World Bank.

# ឯកសារយោងបន្ថែម

Annual Reports (2013-17), Ministry of Agriculture, Forestry and Fisheries

Annual Reports (2016-17), National Bank of Cambodia

Balance of Payment Statistics (2018), National Bank of Cambodia

Banking Supervision Reports (2016-17), National Bank of Cambodia

Budget Law (2018), Royal Government of Cambodia

Cambodia Doing Business Ranking (2018), World Bank

Cambodia Enterprise Survey (2016), World Bank

Cambodia Future Jobs (2018), the World Bank

Cambodia Industrial Development Policy (2015-25), Royal Government of Cambodia

Cambodia Investment Climate Assessment (2018), World Bank

*Cambodia Public Debt Statistical Bulletin*, Volume 5, March 2018, Ministry of Economy and Finance

Cambodia Public Expenditure Review (2018), World Bank

Cambodia Socioeconomic Surveys (2004-16), National Institute of Statistics, Ministry of Planning

Cambodia Systematic Country Diagnostic (2017), World Bank

Cambodia Tourism Statistics (2017-18), Ministry of Tourism

Cambodian National Accounts Statistics (2017), National Institute of Statistics, Ministry of Planning

*East Asia and Pacific Economic Update* (October 2018), World Bank

*Global Economic Prospects* (2018), World Bank

IMF Article IV Staff Report (2017), International Monetary Fund

Logistic Performance Index (2016), World Bank

Mid-year report, June 2018, National Bank of Cambodia

*Monetary Statistic Bulletin* (2018), National Bank of Cambodia

National Strategic Development Plan (2014-18), Ministry of Planning

Rectangular Strategy, Royal Government of Cambodia, September 2018

*World Development Report 2019: The Changing Nature of Work*, World Bank

ក្រុមធនាគារពិភពលោក

**ធនាគារពិភពលោក**
ប្រចាំនៅប្រទេសកម្ពុជា
អគារ Exchange Square
ជាន់ទី 10 IBRD និងជាន់ទី 11 IFC
ផ្លូវលេខ 51-61 និងផ្លូវលេខ 102-106
សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ
ភ្នំពេញ ប្រទេសកម្ពុជា
គេហទំព័រ: www.worldbank.org/cambodia